Formation, Dialogue, Cooperation

# អ្នកនាំសារ
# The Messenger

កាសែតចេញផ្សាយប្រចាំខែ ឆ្នាំទី១០ សម្រាប់ខែកញ្ញា ឆ្នាំ២០១៧ លក់តម្លៃ ១០០០រៀល

លេខ ១០៥



## សម្រាប់ពិធីកាន់បិណ្ឌ និងភ្ជុំបិណ្ឌខាងមុខនេះណា ក៏ចំណាយមិនតិចដែរ!

ថតដោយ រិទ្ធី

Formation, Dailouge, Cooperation

ការិយាល័យផ្សព្វផ្សាយព័ត៌មានកាតូលិក

ផ្ទះលេខ ២៥ ផ្លូវលេខ ២៤២ សង្កាត់ បឹងព្រលិត ខណ្ឌ ៧ មករា រាជធានីភ្នំពេញ

Tel/Fax : (855) 23 224 120

Email : csccambodia@gmail.com / Website : www.catholiccambodia.org

Email : catholicphnompenh@gmail.com / Website : www.catholicphnompenh.org

https://www.facebook.com/CatholicCambodia / https://www.facebook.com/CatholicPhnomPenh

ចាងហ្វាង : លោក លី សុវណ្ណា

សេចក្ដីប្រកាសលេខ: ១០១ ព.ម.ប្រ.ក/ ០៥-កុម្ភៈ-២០១៤

# ទីផ្សារបន្លែសរីរាង្គ កាន់តែមានប្រជាប្រិយភាព បន្ទាប់ពីមានការហូរចូលបន្លែដែលមានជាតិគីមី



ថតដោយ រិទ្ធី

នៅលើសួនច្បារសាធារណៈដែលមិនទាន់សង់រួចស្ថិតនៅចំពីមុខផ្សារកំពង់ស្ពឺស្ថិតក្នុងក្រុងច្បារមន ខេត្តកំពង់ស្ពឺ តូបលក់បន្លែសរីរាង្គមួយ បានទាក់ទាញស្ត្រីមេផ្ទះ និងអ្នកធ្វើដំណើរតាមផ្លូវជាតិលេខ៤ឲ្យចូលមកទិញបន្លែសរីរាង្គស្រស់ៗ ដែលគេទើបយកពីកន្លែងដាំដុះរបស់កសិករនៅក្នុងខេត្តនេះ។

តូបតូចៗទាំងនេះ បានចាប់ដាក់ឲ្យដំណើរការកាលពីថ្ងៃអាទិត្យសប្តាហ៍កន្លងទៅ និងកំពុងបន្តដំណើរការជារៀងរាល់ចុងសប្តាហ៍ ដើម្បីផ្គត់ផ្គង់ដល់អ្នកនិយមទទួលទានបន្លែ ដែលមិនប្រើសារធាតុគីមីសម្រាប់ការដាំដុះ។

អ្នកស្រី សុខ ស្រីអូន វ័យ៣០ឆ្នាំ បានថ្លែងថា អ្នកស្រីបានទិញបន្លែសរីរាង្គនេះ ពីតូបទាំងនេះ។ ការទទួលទានបន្លែសរីរាង្គមិនត្រឹមតែធ្វើឲ្យសុខភាពល្អប្រសើរនោះទេ តែថែមទាំងបានជួយដល់ប្រជាកសិករខ្មែរដាំដុះដំណាំប្រភេទនេះទៀតផង។

"មានចំណេញមួយ គឺជាផលិតផលក្នុងស្រុក ផ្តល់កម្រៃដល់ប្រជាជនក្នុងស្រុក ហើយលើកកម្ពស់ជីវភាពកសិករ ពីព្រោះបើសិនជាគាត់ដាំ ឈ្មួញគាត់ទៅទិញគឺមានតម្លៃថោកហើយបើសិនជា គាត់យកមកដាក់លក់ផ្ទាល់តម្លៃគាត់គឺ ប្រហែលនៅក្នុងទីផ្សារ។"

អ្នកស្រី សុខ ស្រីអូន មានការបារម្ភចំពោះបន្លែដែលដាក់លក់នៅក្នុងទីផ្សារទូទៅ ដោយសារបន្លែទាំងនោះ ត្រូវបានរក្សាទុកក្នុងរយៈពេលយូរថ្ងៃ និងអាចមានប្រើសារធាតុគីមី។

"ភាគច្រើនបន្លែដែលយើងឃើញនៅផ្សារយើងនេះ ភាគច្រើនដឹកមកពីប្រទេសក្រៅអចឹងគុណភាពវាយូរ។ បើសិនជាគាត់អត់ដាក់គីមី ក៏យូរដែរ យូរថ្ងៃ។ បើយើងគ្រាន់តែដឹក អចឹងបន្លែវាអស់គុណភាពហើយ។ បើយើងឥឡូវនេះ យើងបេះភ្លាមយកមកលក់ភ្លាម បន្លែមានគុណភាព"។

យោងតាមរបាយការណ៍ ពី CEDAC បានបង្ហាញថា ប្រទេសកម្ពុជា បានពឹងផ្អែកលើការនាំចូលបន្លែពីប្រទេសក្បែរខាងប្រមាណ ៥០ភាគរយ។ កសិករខ្មែរអាចផលិតបានបន្លែ ៥០ភាគរយទៀតសម្រាប់ការផ្គត់ផ្គង់ក្នុងស្រុក។ បន្លែសរីរាង្គដែលកសិករខ្មែរផលិតបាន គឺមានចំណែកតែ៥ភាគរយប៉ុណ្ណោះនៃផលិតកម្មបន្លែក្នុងស្រុកប្រមាណ៥០ភាគរយនេះ។

អ្នកទទួលទានបន្លែនាពេលបច្ចុប្បន្នតែងតែមានការអ៊ូរទាំ អំពីផលប៉ះពាល់ដល់សុខភាពដែលបង្កមកពីការទទួលទានបន្លែដែលប្រើសារធាតុគីមី ឬថ្នាំពុល។ អ្នកទទួលទានបន្លែធម្មតាមួយចំនួន បានឲ្យដឹងពីបញ្ហាឈឺក្រពះ និងការចុះថយកម្លាំង ដោយសារការទទួលទានបន្លែផលិតក្នុងស្រុក ឬបន្លែនាំចូលពីប្រទេសក្បែរខាង ដែលមានប្រើសារធាតុគីមី។

លោក សំ ពុទ្ធិ វុទ្ធី ជាអាជីវករ បានឲ្យដឹងថា ប្រជាពលរដ្ឋខ្មែរកាន់តែច្រើនផ្តោតការចាប់អារម្មណ៍ទៅលើការទទួលទានបន្លែសរីរាង្គ ដោយហេតុថា ពួកគេបានយល់ដឹងពីគុណប្រយោជន៍របស់បន្លែសរីរាង្គចំពោះសុខភាព។

"សម្រាប់ខ្ញុំ ខ្ញុំគិតថា ថ្ងៃនេះ គឺមានមានភាពភ្ញាក់ផ្អើលមែនទែន ពីព្រោះកន្លងមកនៅពេលដែលយើងធ្លាប់ទៅទស្សនកិច្ចសិក្សា នៅកន្លែងផ្សេង ថ្ងៃបើកដំបូងអត់សូវមានអតិថិជនទេ។ ប៉ុន្តែសម្រាប់យើងនៅនេះ យើងបើកថ្ងៃដំបូង គឺមានអតិថិជនច្រើន។ អចឹងខ្ញុំជឿជាក់ថា ទៅថ្ងៃ ទៅថ្ងៃបន្តទៀត គឺមានអតិថិជននៃការគាំទ្រកាន់តែច្រើន ព្រោះយើងផ្អែកទៅលើទីមួយការយល់ដឹងរបស់អតិថិជន ដែលគាត់យល់ដឹងលើអ្វីដែលជាអត្ថប្រយោជន៍បន្លែសរីរាង្គ ឬក៏ផលិតផលធម្មជាតិ"។

នៅគ្រាដែលតម្រូវការកសិផលធម្មជាតិកំពុងកើនឡើង អ្នកជំនាញកសិកម្មបានព្យាយាមកំណត់នូវបទដ្ឋានបន្លែសរីរាង្គសម្រាប់ទប់ស្កាត់ការក្លែងបន្លំដោយឈ្មួញទុច្ចរិត។ ផ្សារសម្រាប់ផ្គត់ផ្គង់កសិផលធម្មជាតិនេះ នឹងត្រូវបង្កើតនៅខេត្តតាកែវ។

លោកសំ ពុទ្ធិ វុទ្ធី ក្រុមសង្គមស៊ីវិលដែលធ្វើការលើវិស័យកសិកម្ម បានធ្វើការរួមគ្នាក្នុងការកំណត់ស្តង់ដាសម្រាប់បន្លែសរីរាង្គចាប់តាំងពីដំណើរនៃការផលិត និងការដាក់លក់ផលិតផលនៅក្នុងទីផ្សារ។

លោកមានប្រសាសន៍ថា សកម្មភាពនេះ ធ្វើឡើងបានបង្ហាញពីការយកចិត្តទុកដាក់របស់ រាជរដ្ឋាភិបាលកម្ពុជា ទៅលើផលិតផលក្នុងស្រុក ផលិតដោយប្រជាកសិករខ្មែរនឹងការលើកស្ទួយសេដ្ឋកិច្ចជនបទបន្ថែមទៀត។

"គាត់(រាជរដ្ឋាភិបាល)បានខិតខំធ្វើជាគំរូ អាចធ្វើថា ជាសកម្មភាពមួយថាការផលិតកសិកម្មសរីរាង្គ គឺអាចបន្តបាន ឬក៏អាចអនុវត្តន៍បាន នៅក្នុងប្រទេសកម្ពុជាយើង សម្រាប់ឲ្យកសិករមានផលចំណេញ ក៏ដូចជាអ្នកបរិភោគ អ្នកហូបហ្នឹងគឺ មានសុវត្ថិភាពចំណីអាហារអចឹង។ ហើយ អចឹងអង្គការសង្គមស៊ីវិល គឺខិតខំធ្វើយ៉ាងណាដើម្បីអនុវត្តនូវស្តង់ដាហ្នឹងហើយ និងជំរុញនូវការផលិតស្បៀង ប្រកបដោយសុវត្ថិភាពនេះ"។

បន្ថែមពីនេះប្រភពពីមន្ត្រីនៃអគ្គនាយកដ្ឋានកសិកម្មរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានមានប្រសាសន៍ថា មន្ត្រីកសិកម្មរបស់រដ្ឋាភិបាល កំពុងធ្វើកិច្ចការកំណត់ស្តង់ដារបន្លែសរីរាង្គនេះ ជាមួយមន្ត្រីកសិកម្មនៅក្នុងប្រទេសសមាជិកសមាគមអាស៊ានទាំង១០ប្រទេស។

លោកមានប្រសាសន៍ថា ស្តង់ដារនឹងបានជាប្រយោជន៍ដល់កសិករដាំដំណាំសរីរាង្គនៅទូទាំងសមាគមអាស៊ាន។

"តាមពិតទៅ យើងចង់ជម្រាបជូនថា រដ្ឋាភិបាលស្ថិតនៅក្នុងដំណាក់កាលមួយកំពុងតែរៀបចំផលិតផលសរីរាង្គស្តង់ដារនេះ។ បានន័យថា យើងអត់មានអនុម័តជា ស្តង់ដារសរីរាង្គនៅឡើយទេ។ អ្វីដែលយើងកំពុងតែរៀបនេះគឺ យើងរៀបរួមគ្នាជាមួយនឹងអាស៊ានទាំង១០។ យើងមិនធ្វើតែម្នាក់ឯងទេ"។

រដ្ឋាភិបាលកម្ពុជា បានផ្តល់ថវិកាចំនួន៤៦លានដុល្លារអាមេរិក ដល់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ សម្រាប់ជំរុញកំណើនក្នុងវិស័យកសិកម្មឲ្យបានក្នុងរង្វង់៥% ក្នុងមួយឆ្នាំ។ នេះបើយោងទៅតាមឯកសារនៃកញ្ចប់ថវិកាជាតិសម្រាប់ឆ្នាំ២០១៦ ដែលត្រូវបានចេញផ្សាយជាសាធារណៈដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

មន្ត្រីជំនាញផ្នែកសេដ្ឋកិច្ចនៃឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ ធ្លាប់ឲ្យដឹងថា រដ្ឋាភិបាល គ្រោងចំណាយ២០លានដុល្លារអាមេរិក ទៅលើផលិតកម្មពូជស្រូវ និងបន្លែពីឆ្នាំ២០១៦ ដល់ឆ្នាំ ២០១៨ខាងមុខ។

អ្នកស្រី តន់ ធីតា អ្នកដាំបន្លែសរីរាង្គនៅក្នុងខេត្តកំពង់ស្ពឺ បានមានប្រសាសន៍ថា កសិករដាំដំណាំសរីរាង្គនៅខេត្តកំពង់ស្ពឺពិតជាមានការសារទរចំពោះដំណើរការនៃការរៀបចំខាងលើនេះ ដើម្បីជួយដល់កសិករ អាចទទួលបានផលចំណេញខ្ពស់បន្ថែមលើការធ្វើកសិកម្មតាមបែបប្រពៃណីកាលពីមុនមកនោះ។

ប្រជាពលរដ្ឋខ្មែរនាពេលបច្ចុប្បន្ន ត្រូវការបន្លែជាង៤០០តោន សម្រាប់ការបរិភោគក្នុងមួយថ្ងៃៗ។អ្នកជំនាញកសិកម្មថ្លែងថា កម្ពុជាត្រូវធ្វើការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធនៃប្រព័ន្ធធារាសាស្ត្របន្ថែមទៀត សម្រាប់ការដាំដុះបន្លែធម្មតា និងបន្លែសរីរាង្គ ដើម្បីកាត់បន្ថយការនាំចូលពីប្រទេសក្បែរខាង ជាពិសេសនោះ គឺប្រទេសវៀតណាម៕

ដោយ ផល សុផានិត

# ពលរដ្ឋខ្មែរចាប់ផ្តើមទទួលស្គាល់និងប្រើប្រាស់ប្រព័ន្ធទូទាត់ដ៏ស្វ័យប្រវត្តិ

ក្រៅពីកាត អេធីអ៊ឹម (ATM) នៅមានសេវាកម្មវីសាកាត (Visa Card) ក្រេឌីតកាត (Credit Card) ភេ ញូញៀន (Pay Union) ហើយថ្មីៗនេះ គឺមានពលរដ្ឋមួយចំនួនបានឈានទៅរហូតដល់ការប្រើប្រាស់ អេប (App) នៅក្នុងកម្មវិធីទូរស័ព្ទឆ្លាតវៃរបស់ពួកគេថែមទៀត។

លោក ហេង ឫទ្ធីស័ក ជាប្រជាពលរដ្ឋវ័យកណ្តាលមួយរូបបានថ្លែងថា ឥឡូវនេះ កម្រិតជីវភាពពលរដ្ឋគឺមានការប្រែប្រួល រីឯអ្នកដែលផ្តល់សេវាកម្មក៏បានខិតខំអភិវឌ្ឍន៍សេវាកម្មរបស់ពួកគេដើម្បី ផ្តល់ជម្រើសកាន់តែប្រសើរកាន់តែងាយស្រួលដល់ពលរដ្ឋ នៅក្នុងការចំណាយដោយមិនចាំបាច់ មានសាច់ប្រាក់ (លុយ)នៅក្នុងខោប៉ៅក៏បាន ។

លោកបានថ្លែងថា វាពិតជាមោទនភាពមែនទែនដែលសង្គមខ្មែរយើងអាចឈានទៅលឿនដល់ថ្នាក់នេះ ដោយសារតែពីមុន ទាល់តែមានលុយបានអាចចូលទិញ ចូលទៅញ៉ាំអាហារ ចូលស្នាក់នៅសណ្ឋាគារ ចូលចាក់សាំងបាន ប៉ុន្តែឥឡូវលោកនិងពលរដ្ឋមួយចំនួនអាចទៅណាមកណាដោយមិនចាំបាច់មានលុយជាប់ខ្លួនក៏បានដែរ។

តាមការអះអាងថា របស់លោកឫទ្ធីស័ក បានឲ្យដឹងថា ឥឡូវនេះ នៅតាមហាងទំនិញធំៗ គឺសុទ្ធ តែមានសេវាកម្មនៃការទូទាត់ដ៏ងាយស្រួលខាងលើទាំងអស់ ហើយបច្ចុប្បន្ននេះ សេវាកម្មមួយ ដែលលោកកំពុងតែចាប់អារម្មណ៍ គឺប្រើប្រាស់នូវ អេប មួយដែលមិត្តភិក្តបានណែនាំដោយ ទាញវាចេញពី កម្មវិធីក្នុងទូរស័ព្ទដៃ គឺផាយ ភេ (Pi Pay)។ លោកបានបន្តថា អេបនេះ មិនទាន់ទូលំទូលាយទេ ប៉ុន្តែវាពិតជាអស្ចារ្យ ងាយស្រួល ជាពិសេសគឺទទួលបានការបញ្ចុះតម្លៃស្តែងៗតែម្តង នៅពេលយើងទៅទទួលទាន ទៅទិញនំ ទៅមើលកុន និងទទួលសេវាកម្មមួយចំនួន ។

លោក ឫទ្ធីស័ក បានបញ្ជាក់ថា "សេវាកម្មនេះពិតជាចាប់អារម្មណ៍មែនចំណេញទៀត ដោយសារតែហាងនំ ភោជនីយដ្ឋាន កន្លែងកំសាន្ត ខ្លះបញ្ចុះតម្លៃរហូតដល់ទៅ៥០ ភាគរយឯណោះ។ វាជួយសន្សំសំចៃមែនទែន"។

លោកស្រី ឈាង ឡានីន ជាស្ត្រីមេផ្ទះមួយរូប ក៏បានអះអាងដោយភ្ញាក់ផ្អើលផងដែរទៅលើការ ចំណាយតាមអេបថ្មី ដែលហៅថា ផាយ ភេ នេះ។

លោកស្រីបានបញ្ជាក់ថា "ដំបូងខ្ញុំមិនជឿទេពេលមិត្តភិក្តគេណែនាំ តែពេលសាកទៅគឺមែន"។ លោកស្រីបានបញ្ជាក់ទៀតថា "កាលពីចុងសប្តាហ៍មុននេះ ខ្ញុំនាំគ្រួសារទៅញ៉ាំភីហ្សានិងទិញនំ នៅហាងមួយគឺខ្ញុំអាចកាត់បន្ថយការចំណាយដល់ទៅ៥០ ភាគរយ"។

លោកស្រីបានបន្តថា រាល់ដង សម្រាប់ឈុតសាច់មាន់បំពងនិង ភីហ្សា យ៉ាងហោចណាស់ក៏អស់ ២០ទៅ៣០ ដុល្លារដែរ តែសប្តាហ៍កន្លងទៅគឺអស់ត្រឹមតែជាង ១០ដុល្លារ ប៉ុណ្ណោះ ។

តាមការរៀបរាប់របស់លោកស្រី ការចំណាយតាម អេប នេះដំបូងវាដូចជារញ៉េរញ៉ៃបន្តិចដែរ ប៉ុន្តែ ការរញ៉េរញ៉ៃនេះ វាអាចទទួលបាន ពេលដែលវាបញ្ចុះថ្លៃច្រើនបែបនេះ។ លោកស្រីបានបញ្ជាក់ថា "រកឯណាបានលុយ ២០ ទៅ៣០ ដុល្លារនៅក្នុងមួយថ្ងៃ តែបើចំណាយវិញគឺស្រួល ដូច្នេះបើមានសេវាកម្ម បែបនេះ គួរតែសាកល្បង ដោយសារវាជួយសន្សំសំចៃច្រើន"។

ដើម្បីប្រើប្រាស់សេវាកម្មនេះ លោកស្រីបានចែករំលែកថា ដំបូង គឺត្រូវទាញកម្មវិធីផាយ ភេ នេះ ពីទូរស័ព្ទវៃឆ្លាតរបស់យើងម្នាក់ៗ ហើយតម្លើងវានៅក្នុងទូរស័ព្ទដៃ បន្ទាប់មកត្រូវចុះឈ្មោះដើម្បី ទទួលការប្រើប្រាស់បន្ទាប់មក គឺទៅជួបភ្នាក់ងារ ដើម្បីដាក់លុយរបស់យើង ចូលទៅក្នុងគណនី ផាយ ភេ នេះ ដោយ យើងអាចបើកគណនីទាំងលុយរៀល និងលុយដុល្លារ ឬទាំងពីរក៏បាន។ រួចហើយយើងអាចចាប់ផ្តើមប្រើប្រាស់សេវាកម្មនេះបានហើយ ។

ដ៏រីញការប្រើប្រាស់សេវាកម្ម នេះ លោកឫទ្ធីស័ក បានអះអាងថា ដំបូងអីចឹងវាអាចជាការចាប់ផ្តើម ទើបយើងជាអតិថិជនអាចទទួលការបញ្ចុះតម្លៃខ្ពស់ហើយច្រើនបែបនេះ ដើម្បីឃោសនាសេវាកម្មរបស់គេ ដូច្នេះបើយើងអាចដឹងសេវាកម្មនេះបានលឿន នោះយើងអាចចំណេញ តែទោះយ៉ាងណា ខ្ញុំជឿថា នៅតែទទួលបានការបញ្ចុះតម្លៃអីចឹង គ្រាន់តែការបញ្ចុះនេះវាថយចុះវិញ។

លោកបានបញ្ជាក់ថា "ឥឡូវនេះ សង្គមយើងវិវត្តន៍លឿនណាស់ បើយើងឆ្លាតគួរស្វែងយល់ អំពីសេវាកម្មអីចឹងៗដើម្បីទទួលអត្ថប្រយោជន៍"។ លោកបានបន្តថា កម្មវិធីអីចឹងៗនិងបែបហ្នឹងយើងអាចទទួលបានអត្ថប្រយោជន៍ច្រើនពីវានៅពេលចាប់ផ្តើមដំបូងបែបនេះ។

លោកស្រី ឡានីន បាននិយាយថា ការប្រើប្រាស់តាមប្រព័ន្ធទូរទាត់បែបនេះ គឺមិនខាតទេ ប៉ុន្តែប្រសិនបើកម្មវិធី វាអស់ពេលលែងមានការផ្សព្វផ្សាយ និងការបញ្ចុះតម្លៃចាំយើងប្រែប្រួលក៏មិនជាការខាតបង់អីដែរ។

លោកស្រី ក៏បានចែករំលែកអំពីរបៀបនៃការកាត់បន្ថយនិងសន្សំសំចៃថា យើងជាស្ត្រីមេផ្ទះបើទោះ បីជាមិនបានរកចំណូលចូលគ្រួសារតែបើយើងចេះសន្សំសំចៃ គឺជាការជួយកាត់បន្ថយការចំណាយ មួយ។ លោកស្រីបានបន្តថា ព័ត៌មានបែបនេះ យើងដឹងតាមមិត្តភិក្ត តាមព័ត៌មាន តាមហ្វេសបុក តាមការស្តាប់វិទ្យុ មើលទូរទស្សន៍ អានកាសែត រកមើលការលក់បញ្ចុះតម្លៃ និង ការផ្សព្វផ្សាយ សេវាកម្មថ្មីៗបែបនេះ ។

លោកស្រីបានបញ្ជាក់ថា "មើលហ្វេសបុក... កុំមើលរឿងអត់បានការច្រើនពេក រៀនចេះមើលព័ត៌មានដែលមានប្រយោជន៍វិញល្អជាង"។

គួររំលឹកថា ផាយ ភេ គឺជាកម្មវិធីទូទាត់គ្មានសាច់ប្រាក់តាមទូរស័ព្ទស្មាតហ្វូន និងជាក្រុមហ៊ុនផ្ទេរប្រាក់ ឌីជីថលមួយ ដែលទើបតែផ្តល់សេវាកម្មនេះ នៅកម្ពុជាបានជាងមួយខែប៉ុណ្ណោះ។ បើតាមតួរលេខដែលក្រុមហ៊ុននេះបានចែករំលែកតាមសារព័ត៌មាន គឺថា អេប ដែលជាកម្មវិធីទូទាត់តាមទូរស័ព្ទស្មាតហ្វូននេះត្រូវបានទាញយកមកប្រើចំនួន ៣០.០០០ ដង និងបានទូទាត់ប្រតិបត្តិការជាង ១០០.០០០ ដង នៅក្នុងទីតាំងហាងសរុបចំនួនប្រមាណជា១៥០ កន្លែង នៅទូទាំងរាជធានីភ្នំពេញ។

កម្មវិធីនេះកំពុងស្ថិតនៅក្នុងដំណាក់កាលសាកល្បង ប៉ុន្តែទោះបីជាយ៉ាងណា សេវាកម្មទូរទាត់ដ៏ងាយស្រួលបែបនេះ អាចនឹងមាននៅហាងជាង ៣០០ កន្លែងត្រឹមចុងខែខណៈដែល ផាយ ភេ បានចុះហត្ថលេខាលើកិច្ចព្រមព្រៀងជាមួយក្រុមហ៊ុនជាង ១.៤០០ហើយ ដើម្បីប្រើប្រាស់សេវានេះ។

*ដោយ អរិយបុត្រ*



ថតដោយ រិទ្ធី

# គ.ជ.ប អំពាវនាវឲ្យពលរដ្ឋខ្មែរទៅចុះឈ្មោះបោះឆ្នោត និងពិនិត្យបញ្ជីឈ្មោះឡើងវិញ

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (គ.ជ.ប) បានអំពាវនាវយ៉ាងទទូចដល់ប្រជាពលរដ្ឋខ្មែរដែលគ្រប់អាយុបោះឆ្នោត ហើយកំពុងបំពេញបេសកកម្ម បម្រើការងារ ឬសិក្សានៅក្រៅប្រទេស មេត្តារួសរាន់ត្រឡប់មកចុះឈ្មោះបោះឆ្នោតថ្មី ឆ្នាំ២០១៧ ដើម្បីទទួលបានសិទ្ធិពេញលេញក្នុងការចូលរួមបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៦ នៃរដ្ឋសភា នាពេលខាងមុខ។ នេះបើតាមសេចក្តីអំពាវនាវរបស់ គ.ជ.ប កាលពីថ្ងៃទី៣១ ខែសីហា ឆ្នាំ២០១៧នេះ។

ការចុះឈ្មោះបោះឆ្នោតថ្មី ឆ្នាំ២០១៧ មានរយៈពេល៧០ថ្ងៃ ដែលនឹងចាប់ផ្តើមឡើងពីថ្ងៃទី០១ ខែកញ្ញា រហូតដល់ថ្ងៃទី០៩ ខែវិច្ឆិកា ខាងមុខ។ សម្រាប់ប្រជាពលរដ្ឋដែលបានចុះឈ្មោះបោះឆ្នោតជ្រើសតាំងក្រុមប្រឹក្សាឃុំសង្កាត់កាលពីឆ្នាំ២០១៦ ត្រូវទៅពិនិត្យមើលឈ្មោះសារឡើងវិញ។ ការធ្វើបច្ចុប្បន្នភាពបញ្ជីបោះឆ្នោត ឆ្នាំ២០១៦ និងការចុះឈ្មោះបោះឆ្នោតថ្មី ឆ្នាំ២០១៧ មានតែនៅការិយាល័យបោះឆ្នោតដែលតាំងនៅក្នុងសាលាឃុំ-សង្កាត់នីមួយៗ និងនៅតាមភូមិមួយចំនួនតែប៉ុណ្ណោះ ពោលគឺគ្មាននៅកន្លែងណាផ្សេងឡើយ ដូចជាស្ថានទូតកម្ពុជាប្រចាំនៅបរទេស ឬនៅតាមព្រំដែនជាដើម។

សម្រាប់ប្រជាពលរដ្ឋខ្មែរគ្រប់រូប ដែលទៅពិនិត្យឈ្មោះ និងចុះឈ្មោះបោះឆ្នោតថ្មី នៅតាមឃុំ សង្កាត់ ក្នុងមូលដ្ឋានរបស់ខ្លួន ត្រូវភ្ជាប់មកជាមួយនូវអត្តសញ្ញាណបណ្ណ ឬសំបុត្រកំណើត ឬបណ្ណគ្រួសារ ឬសៀវភៅគ្រួសារ។ ក្នុងខណៈដែលសាមីខ្លួនរស់នៅបណ្តោះអាសន្ន ក្រៅពីមូលដ្ឋានឃុំសង្កាត់ខ្លួន ត្រូវសុំលិខិតបញ្ជាក់ទីលំនៅពីមន្ត្រីនគរបាលក្នុងមូលដ្ឋានដែលខ្លួនស្នាក់នៅ ដោយមកជាមួយសាក្សីម្នាក់ដែលមានសិទ្ធិបោះឆ្នោតក្នុងមូលដ្ឋាននោះ ទើបមន្ត្រីចុះឈ្មោះបោះឆ្នោត អាចចុះឈ្មោះបោះឆ្នោតជូនបាន។ អ្នកដែលមានសិទ្ធិចុះឈ្មោះបោះឆ្នោតថ្មី គឺមានថ្ងៃកំណើតថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០០០។

គ.ជ.ប បានបញ្ជាក់ថា ការមានឈ្មោះក្នុងបញ្ជីបោះឆ្នោតថ្មី ឆ្នាំ២០១៧ ពិតជាមានសារៈសំខាន់ណាស់ គឺដើម្បីបានចុះបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រនីតិកាលទី៦ នៃរដ្ឋសភា ដែលនឹងប្រព្រឹត្តទៅនាថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០១៨ ខាងមុខ។ បើគ្មានឈ្មោះក្នុងបញ្ជីបោះឆ្នោត ឆ្នាំ២០១៧ ទេនោះ នឹងពុំអាចបោះឆ្នោតបានឡើយ។

បើតាមក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បច្ចុប្បន្នពលករ និងកម្មសិក្សាការីកម្ពុជា ដែលចេញទៅបម្រើការងារនៅក្រៅប្រទេស មានចំនួន ១,០៥០,០០០នាក់។ ក្រៅពីនេះ នៅមានប្រជាពលរដ្ឋ និងសិស្សនិស្សិតជាច្រើននាក់ទៀត ។

គួរបញ្ជាក់ថា កន្លងមក គ.ជ.ប បានប៉ាន់ស្មាននូវចំនួនប្រជាពលរដ្ឋកម្ពុជាសរុបទាំងអស់មានចំនួន ១៥,៨៨៣,២៥០នាក់ ក្នុងនោះមានប្រជាពលរដ្ឋដែលមានអាយុ១៨ឆ្នាំឡើង មានចំនួន ៩,៧៨៨,២៣៩ នាក់ ប៉ុន្តែប្រជាពលរដ្ឋដែលបានចុះឈ្មោះបោះឆ្នោត កាលពីឆ្នាំ២០១៦ មានចំនួន ៧,៨៦៥,០៣៣នាក់ ខណៈប្រជាពលរដ្ឋដែលត្រូវចុះឈ្មោះបោះឆ្នោតថ្មី ឆ្នាំ២០១៧នេះ មានចំនួន ១,៤១២,១៤៩នាក់ ៕

*ដោយ ឡុង សម្ផស្ស*






# យុវជនត្រូវបានប្រាប់ឲ្យនៅឆ្ងាយពីនយោបាយខណៈកំដៅនយោបាយកំពុងតែកើនឡើង

បើតាមការអះអាងរបស់បណ្ដាយុវជន និងយុវនារីមួយចំនួន ដែលកំពុងតែសិក្សា ក្ដី និងកំពុងតែស្ថិត នៅក្នុងវ័យការងារក្ដី ត្រូវបានអាណាព្យាបាលរបស់ពួកគេផ្ដល់ យោបល់ឲ្យនៅឆ្ងាយពីឆាកនយោបាយ ជាពិសេស គឺក្រោយពេលដែលមានការ ចាប់ខ្លួនប្រធានគណបក្សប្រឆាំង។ នេះ ជាការអះអាងរបស់ក្រុមយុវជនប្រាប់អ្នក នាំសារនៅ ក្រោយសភាពការណ៍នយោបាយនៅកម្ពុជាកំពុងតែក្ដៅខ្លាំង។

យុវជនមួយរូប ដែលកំពុងតែឈប់នៅ តាមដងផ្លូវទទួលទានភេសជ្ជៈនៅផ្លូវប៉ាស្ទ័រ បានបដិសេធនៅក្នុងការនិយាយ និង បញ្ចេញយោបល់ពាក់ព័ន្ធនឹងសភាពការណ៍ នយោបាយ ដោយអះអាងថា អាណាព្យាបាលរបស់ខ្លួនផ្ដាំឲ្យខ្លួនកុំនិយាយអ្វីដែល ពាក់ព័ន្ធនឹងសភាពការណ៍នយោបាយ។

បើមើលទំនង យុវជនមួយរូបនេះក៏ជា យុវជនមួយរូបដែលចូលចិត្តអានចូលចិត្ត តាមដាន និងសិក្សាស្វែងយល់ពីសភាព ការណ៍នៅក្នុងប្រទេសដែរ ដោយសារតែ នៅក្នុងដៃរបស់គេ ឃើញមានកាន់កាសែត ឌឹ ឃែមបូឌា ដេលី លេខចុងក្រោយចេញ កាលពីថ្ងៃទី០៤ ខែកញ្ញា ឆ្នាំ២០១៧។

យុវជនរូបនោះបានឲ្យដឹងថា "សូម ទោស! ប៉ាម៉ាក់ខ្ញុំ អត់ឲ្យនិយាយ អត់ឲ្យ បញ្ចេញយោបល់ ឬលេងហ្វេសបុកអីអំពី នយោបាយទេ"។

លោក រុន វណ្ណារិទ្ធ ដែលបានអះអាងថា មានអាយុ ៣០ឆ្នាំ ហើយកំពុងតែបម្រើការងារនៅក្នុងក្រុមហ៊ុនឯកជនមួយក៏បានបដិសេធនៅក្នុងការនិយាយបញ្ចេញយោបល់ ពាក់ព័ន្ធនឹងសភាពការណ៍ នយោបាយថ្មីៗ នៅក្នុងប្រទេសកម្ពុជាផងដែរ។

លោកបានថ្លែងថា បើជាការចែករំលែក អំពីបទពិសោធន៍ការងារ ពីរឿងផ្សេងៗ គឺលោកអាចចូលរួមបាន ប៉ុន្តែសូមទោស សម្រាប់រឿងនយោបាយ។

លោកបានបញ្ជាក់ថា "ខ្ញុំខ្ជិលពាក់ព័ន្ធ នឹងរឿងនយោបាយ ពីព្រោះអាណិតប្រពន្ធ កូន ម៉ែ ឪ ដែលពួកគាត់បានផ្ដែផ្ដាំមកតែ រហូតថា កុំធ្វេចធ្វាចរឿងនយោបាយ ដោយសារតែវាអត់ចំណេញ"។

វណ្ណារិទ្ធបានឲ្យដឹងថា លោកបានដឹង ថា ឥឡូវសភាពការណ៍នយោបាយនៅ កម្ពុជាកំពុងតែដើរដល់ណា ប៉ុន្តែនោះគឺជា រឿងរបស់អ្នកនយោបាយ អ្វីដែលសំខាន់គឺ យើងត្រូវធ្វើការរកស៊ី ចិញ្ចឹម ប្រពន្ធកូន និង ផ្គត់ផ្គង់អាណាព្យាបាលទៅ គឺបានហើយ។

ជុំវិញការវិវត្តនៃសភាពការណ៍នយោបាយនៅក្នុងស្រុកពេលថ្មីៗនេះ យុវនិស្សិត សេក បញ្ញា មិនបានបញ្ចេញយោបល់អ្វីទេ ដោយគ្រាន់តែនិយាយដោយខ្លីថា និយាយ រឿងទាំងអស់នេះអត់ចំណេញទេ។

បញ្ញា បានបញ្ជាក់ថា "ប៉ាម៉ាក់ខ្ញុំផ្ដាំ ហើយផ្ដាំទៀតថារឿងនយោបាយគ្រាន់តែ តាមដានឲ្យដឹងបាន តែកុំប៉ប៉ាច់ប៉ប៉ោច ពីព្រោះវាមិនចំណេញ"។

យុវនារី វង្ស ទេពី ដែលជាយុវនិស្សិត មួយរូប ក៏បានបដិសេធនិយាយរឿងនយោបាយដែរ ពេលដែលអ្នកយកព័ត៌មានអ្នក នាំសារសាកសួរកញ្ញា អំពីរឿងសភាព ការណ៍នយោបាយកំពុងតែកើតឡើង។

ទេពី បានឲ្យដឹងថា សូមទោសបើឲ្យ នាងខ្ញុំនិយាយបញ្ចេញយោបាលរឿងរៀន រឿងសង្គមផ្សេងៗ មិនអីទេ ប៉ុន្តែសូមទាស រឿងនយោបាយ។

ទេពីបានបញ្ជាក់ថា "ខ្ញុំសូមទោស រឿង នយោបាយស្មុគស្មាញណាស់ ខ្ញុំតាមមិន ទាន់ទេ អីចឹងវា ពិតជាពិបាកនិយាយណាស់ ហើយប៉ាម៉ាក់ខ្ញុំគាត់ក៏មិនសប្បាយចិត្តពេល ខ្ញុំនិយាយរឿងនេះដែរ។ សូមទោស !"។

គួររំលឹកថាសភាពការណ៍នយោបាយ នៅកម្ពុជានាពេលថ្មីៗនេះកំពុងតែមាន កំដៅក្ដៅខ្លាំង ដោយ លោក កឹម សុខា ប្រធានគណបក្សសង្គ្រោះជាតិ ដែលជា គណបក្សប្រឆាំងមួយមានអសនៈនៅក្នុង សភាបានត្រូវចាប់ខ្លួន។

លោក កឹម សុខា ត្រូវបានសមត្ថកិច្ច កម្ពុជាចាប់ខ្លួនកាលពីម៉ោង ១២ និង៣៥ នាទីរំលងអធ្រាត្រ ឈានចូលថ្ងៃទី០៣ ខែកញ្ញានេះ នៅឯគេហដ្ឋានរបស់លោក នៅក្រោមបទចោទប្រកាន់ថា ក្បត់ជាតិ ដោយគប់គិតនឹងបរទេស ដើម្បីប៉ុនប៉ងផ្ដួលរំលំរដ្ឋាភិបាលស្របច្បាប់របស់កម្ពុជា។ បន្ទាប់ពីការចាប់ខ្លួន មានសេចក្ដីថ្លែងការណ៍ របស់ស្ថានទូតមួយចំនួនអន្តរាគមន៍សុំឲ្យ មានការដោះលែងលោក កឹម សុខា ប៉ុន្តែ ប្រមុខរាជរដ្ឋាភិបាលកម្ពុជាបានចាត់ទុក សេចក្ដីថ្លែងការណ៍របស់បរទេសពាក់ព័ន្ធ នឹងការចាប់ខ្លួន លោក កឹម សុខា ថាគឺគ្រាន់ តែជាការការពារអាយ៉ងរបស់ខ្លួនឲ្យរួចផុត ពីការចោទប្រកាន់តែប៉ុណ្ណោះ។

សម្ដេចតេជោនាយករដ្ឋមន្ត្រីបានថ្លែង បែបនេះជាការតបតចំពោះប្រទេសមួយ ចំនួនដែលបានចេញសេចក្ដីថ្លែងការណ៍ ការពារលោក កឹម សុខា ដែលត្រូវបាន ចោទប្រកាន់ថាមានទោសក្បត់ជាតិ។

សម្ដេចតេជោនាយករដ្ឋមន្ត្រីបានថ្លែង នៅក្នុងពីធីសម្ពោធដាក់ឲ្យប្រើប្រាស់នូវវិហារ ឥស្លាមដើមមៀក ស្ថិតក្នុងសង្កាត់សំបួរមាស ក្រុងកំពង់ចាម ខេត្តកំពង់ចាម កាលពី ថ្ងៃទី៤ ខែកញ្ញា ឆ្នាំ២០១៧ ថា "សូមផ្ដាំ ផ្ញើរទៅអ្នកដែលបានធ្វើសេចក្ដីថ្លែងការណ៍ ដើម្បីការពារនូវជននេះវាគ្រាន់តែជាការ ការពារអាយ៉ងរបស់ខ្លួន ឲ្យរួចផុតពីការ ចោទប្រកាន់តែប៉ុណ្ណោះ។ សូមគោរព អធិបតេយ្យភាពរបស់កម្ពុជា មិនត្រូវប្រើ ប្រាស់វិធីផ្ដួលរំលំតាមរយៈរបស់ដែលហៅ ថា បដិវត្តន៍ពណ៌ទេ"។

សម្ដេចតេជោនាយករដ្ឋមន្ត្រីបានអះ អាងថា ការឈានដល់ការចាប់ខ្លួនលោក កឹម សុខា នេះ គឺធ្វើឡើងក្រោយពេលដែល មានការផ្សព្វផ្សាយវីដេអូក្លីបមួយចុះផ្សាយ កាលពីថ្ងៃទី០៩ ធ្នូ២០១៣របស់បណ្ដាញ CBN ឬ(Cambodian Broadcasting Network) ដែលមានទីតាំងនៅប្រទេស អូស្ត្រាលី និងភស្តុតាងផ្សេងៗទៀត ដែល បានបង្ហាញពីផែនការសម្ងាត់នៃការគប់គិតរវាងប្រធានគណបក្សសង្គ្រោះជាតិ និងបក្សពួកជាមួយបរទេសដើម្បីផ្ដួលរំលំ រដ្ឋាភិបាលស្របច្បាប់។

នៅក្នុងឃ្លីបវីដេអូ ដែលបានផ្សាយនៅ លើ បណ្ដាញ CBN លោក កឹម សុខា បាន សារភាពយ៉ាង ច្បាស់ៗថា លោកត្រូវបាន សហរដ្ឋអាមេរិកហៅឲ្យទៅរៀនយុទ្ធសាស្ត្រ នេះមួយឆ្នាំម្ដងតាំងពីឆ្នាំ២០០២ មកម្ល៉េះ... គេថាចង់ផ្ដួលរំលំរដ្ឋាភិបាលត្រូវចាប់ផ្ដើម ពីក្រោមទៅមុន ហើយគេបានឲ្យគំរូតាម ប្រទេសយូហ្គោស្លាវី ក្នុងការផ្ដួលរំលំ លោក មីឡូសូវិច..។ លោកបន្តថាការធ្វើរបស់ លោកនេះ គឺមិនមែនធ្វើដោយចិត្តឯងនោះ ទេគឺអាមេរិកជាអ្នកជួយ និងមានអ្នកជំនាញ សាស្ត្រាចារ្យមកពីអាមេរិក និងកាណាដា ជាអ្នកផ្ដល់យុទ្ធសាស្ត្រទៀត ហើយបើ លោកធ្វើប៉ុណ្ណឹងហើយនៅតែមិនជោគជ័យ ទៀត ...មានតែបន្ត ។

វីដេអូនេះត្រូវបានរដ្ឋាភិបាលអះអាង ថា ជាភស្តុតាងមួយសំខាន់ឈានដល់ ការចាប់ខ្លួនលោក កឹម សុខា ព្រោះលោក កឹម សុខា បានទទួលបានការបណ្ដុះបណ្ដាលពីអាមេរិកដើម្បីធ្វើការផ្លាស់ប្ដូររបប ដឹកនាំនៅកម្ពុជា។ ចំណុចការនិយាយ អះអាងរបស់លោក កឹម សុខា នេះគឺល្មម គ្រប់គ្រាន់សម្រាប់ធ្វើការចោទប្រកាន់ពី ទោសក្បត់ជាតិ ដូចមានចែង និងផ្ដន្ទាទោសតាមញត្តិនៃមាត្រា៤៤៣ ក្នុងផ្នែក ទី១ ស្ដីពីសន្និដ្ឋិភាពជាមួយបរទេស គឺជា អំពើត្រូវរ៉ូវគ្នាដោយសម្ងាត់ជាមួយរដ្ឋបរទេស ឬភ្នាក់ងារបរទេស ដើម្បីបង្កើតឲ្យមានអំពើ ប្រទូស្ដរ៉ាយ ឬឲ្យមានអំពើឈ្លានពានប្រឆាំង នឹងព្រះរាជាណាចក្រកម្ពុជា។ បទល្មើស នេះត្រូវជាប់ពន្ធនាគារពី ១៥ ដល់ ៣០ ឆ្នាំ។



ថតដោយ សម្បត្តិ

*ដោយ អរិយបុត្រ*

# កម្មករ និងកម្មការិនី ត្រេកអរពេលទទួលបានការសន្យាពីនាយករដ្ឋមន្ត្រីលើចំណុចមួយចំនួន

បណ្ដាកម្មករ និងកម្មការិនីដែលបានទទួលសារពីប្រមុខរដ្ឋាភិបាលកម្ពុជានៅក្នុងយុទ្ធនាការចុះជួបកម្មកររបស់សម្ដេចតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃកម្ពុជានៅក្នុងខែសីហា កន្លងទៅនេះ បានសំដែងសុទិដ្ឋិនិយមចំពោះការ សន្យារបស់សម្ដេចនាយករដ្ឋមន្ត្រី រឿងមួយចំនួន ដូចជា ការតម្លើងប្រាក់ខែ រឿងសុខភាព រឿងប្រាក់សោធននិវត្ត និងចំណុចមួយចំនួនដែលទាក់ទងនឹងការលើកកម្ពស់សុខមាលភាពរបស់ពួកគេ។

កញ្ញា សាំង គីមអ៊ាន ជាកម្មកររោងចក្រនៅម្ដុំចោមចៅ បានថ្លែងថា នរណាមិនសប្បាយចិត្តបើយើងទទួលបានការសន្យាពីនាយករដ្ឋមន្ត្រីអំពីរឿងប្រាក់ខែ និងរឿងផ្សេងៗទាក់ទងនឹងការចូលនិវត្តន៍ និងរឿងសុខភាព ហើយមានរឿង ជិះឡានក្រុងអត់យកលុយថែមទៀត។

កញ្ញា បានបញ្ជាក់ថា "ពួកខ្ញុំសប្បាយចិត្តពេល សម្ដេចហ៊ុន សែន គាត់សន្យាតម្លើងប្រាក់ខែ រឿងសុខភាព ជាពិសេសគឺឮថា មានលុយចូលនិវត្តន៍ដូចមន្ត្រីរាជការដែរ"។ កញ្ញា បានបន្តទៀតថា ដោយឡែករឿងការជិះឡានក្រុងមិនយកលុយ កញ្ញា ក៏សប្បាយចិត្តដែរ បើទោះបីជាពេលនេះ កន្លែងដែលកញ្ញាកំពុងធ្វើការមិនមានឡានក្រុងសាធារណជំណើរការមកដល់កន្លែងក៏ដោយ ប៉ុន្តែចុងសប្ដាហ៍អី កញ្ញាក៏អាចនឹងជិះវាមកលេងផ្សារទំនើប មើលការប្រគុំតន្ត្រី ដើរលេងទីនេះទីនោះនឹងគេដែរ។

លោកស្រី ញ៉ែម សុជាតិ ជាកម្មការិនីមួយរូប ក៏បានថ្លែងទាំងទឹកមុខរីករាយថា មនុស្សយើងធំរឿងសុខភាព រឿងប្រាក់ខែ រឿងទឹករឿងភ្លើង និងថ្លៃជីវភាពនេះហើយ ប៉ុន្តែពេលសម្ដេចតេជោ លើកឡើងពីរឿងនេះវាត្រូវចិត្តលោកស្រីតែម្ដង។

លោកស្រីបានបញ្ជាក់ថា "បើវាពិតមែនខ្ញុំមិនដឹងសប្បាយចិត្តយ៉ាងណាទេ ពីព្រោះអ្វីដែលសម្ដេច ហ៊ុន សែន គាត់សន្យា គឺសុទ្ធតែត្រូវពួកខ្ញុំចង់បាន"។ លោកស្រីបានថ្លែងទៀតថា ជីវិតជាកម្មកររឿងដែលព្រួយជាងគេគឺ រឿងសុខភាពនេះហើយ ពីព្រោះប្រាក់ខែឥឡូវមិនសល់ទេ គឺគ្រាន់តែរស់ៗ ប្រសិនជាឈឺយាប់ណាស់។ លោកស្រីបានបញ្ជាក់ថា "ដូចខ្ញុំចឹង ប៉ុន្មានថ្ងៃមុនខ្ញុំរាគ ពេទ្យចាក់តែសេរ៉ូម និងវាយ(ឲ្យ)ថ្នាំមួយចំនួន ពេលគិតលុយងឹតមុខឈឹង ដោយអស់ ៤៥ម៉ឺនរៀល។ អស់លើងលុយសន្សំជាង ៣ខែ"។

កញ្ញា ជន សុផាត ជាកម្មការិនីរោងចក្រកាត់ដេរមួយរូបដែរនោះ ក៏បានសម្ដែងអំពីការរីករាយនេះផងដែរ ពេលឮអំពីសាររបស់សម្ដេចតេជោ ហ៊ុន សែន ដែលផ្សព្វផ្សាយ ប៉ុន្តែកញ្ញា ហាក់សំដែងការស្ទាក់ស្ទើរបន្តិចដោយ កញ្ញា បានលើកឡើងអំពីការព្រួយបារម្ភខ្លាចរឿងទាំងនេះបានត្រឹមតែការសន្យា។ កញ្ញាបានលើកឡើងថា កន្លងមកកញ្ញាធ្លាប់ទទួលព័ត៌មានមិនល្អជាច្រើន ពីប.ស.ស (បេឡាជាតិរបបសន្តិសុខសង្គម) រឿងទូរទាត់ថ្លៃសុខភាព និងថ្លៃធានារ៉ាប់រងហានិភ័យការងារនេះ។

កញ្ញាបានថ្លែងបញ្ជាក់ថា "ខ្ញុំមិនដែលបានជួបទេ តែគ្រាន់តែឮថា ពេលយើងជាកម្មករកាន់ប័ណ្ណប.ស.សនេះទៅពេទ្យ! ពេទ្យដូចជាគេមិនចង់មើលទេ! ពួកពេទ្យមើលទៅដូចជា រើសអើងយើងដោយសារតែយើងអត់លុយ។ ហើយបើមានគ្រោះថ្នាក់ការងារអីគឺថា ពិបាក និងស្មុគស្មាញដើម្បីទទួលបានលុយពី ប.ស.សនេះ ដូច្នេះបើសិនសម្ដេច ហ៊ុន សែន គាត់អាចដោះស្រាយអាហ្នឹងបានល្អ"។

នេះគឺជាការព្រួយបារម្ភមួយ ពីព្រោះកន្លងមក គឺមានព័ត៌មានត្អូញត្អែរជាច្រើនអំពីរឿងនៃការទូទាត់សំណង ហានិយភ័យការងារពេលកម្មករមានគ្រោះថ្នាក់ការងារ និងរឿងប្រើប្រាស់ប័ណ្ណ ប.ស.ស.នេះ ទៅកាន់មន្ទីរពេទ្យ ដើម្បីព្យាបាលជំងឺ ក៏ដូចជាពិនិត្យសុខភាព។

គួររំលឹកថា នៅក្នុងយុទ្ធនាការចុះជួបសាកសួរសុខទុក្ខកម្មករនិងកម្មការិនីកាលពីខែសីហានេះ សម្ដេចតេជោ ហ៊ុន សែន បានប្រកាសការផ្ដល់ការលើកទឹកចិត្តជាច្រើនដល់ពួកគេ។ សម្ដេចតេជោបានលើកឡើងនៅក្នុងពិធីសំណេះសំណាលជាមួយបងប្អូន កម្មករ និងកម្មការិនីជាង១៦.០០០ នាក់ នៅតំបន់សេដ្ឋកិច្ចពិសេសភ្នំពេញ នាព្រឹកថ្ងៃទី២៣ ខែសីហានេះថា ប្រាក់ខែពួកគេនឹងបង្កើនពី ១៥៣ ដុល្លារ ទៅ ១៦០ ដុល្លារនៅក្នុងមួយខែនា ឆ្នាំក្រោយ។ មិនតែប៉ុណ្ណោះ សម្ដេចតេជោ ហ៊ុន សែន ក៏បានប្រកាសឲ្យសាលារាជធានីភ្នំពេញ អនុញ្ញាតឲ្យកម្មករនិងកម្មការិនី ប្រើប្រាស់សេវាកម្មរថយន្តក្រុងដោយមិនគិតប្រាក់រយៈពេល ២ឆ្នាំ ចាប់ពីពេលនេះតទៅ។

សម្ដេចតេជោ ហ៊ុន សែន ក៏បានប្រកាសឲ្យបងប្អូនកម្មករ និងកម្មការិនីអាចប្រើប្រាស់សេវាកម្មរថយន្តក្រុងសាធារណៈដោយមិនចាំបាច់បង់ថ្លៃ រយៈពេលពីរឆ្នាំចាប់ពីពេលនេះតទៅ ហើយចាប់ពីខែមករា ឆ្នាំ២០១៨ ខាងមុខនេះតទៅ កម្មករ-កម្មការិនីទាំងអស់នឹងទទួលបានថ្លៃសេវាផ្នែកគាំពារសុខភាពដោយមិនគិតថ្លៃរាល់ការបង់វិភាគទានសម្រាប់សេវាសុខភាពនេះ គឺភាគីនិយោជកគឺជាអ្នកទទួលខុសត្រូវបង់ថ្លៃ ១០០ ភាគរយ។ ដោយឡែកចាប់ពីឆ្នាំ២០១៩ ទៅ កម្មករនិងកម្មការិនីទាំងអស់នឹងទទួលបានប្រាក់ចូលនិវត្តន៍ដូចជាមន្ត្រីរាជការរដ្ឋផងដែរ ។

សម្ដេចតេជោ ហ៊ុន សែន ក៏បានថ្លែងបញ្ជាក់ទៀតថា កម្មការិនីដែលមានផ្ទៃពោះរោងចក្រត្រូវផ្ដល់ពេលវេលាគ្រប់គ្រាន់សម្រាប់ពួកគេ ទៅពិនិត្យផ្ទៃពោះ និងផ្ដល់ប្រាក់ខែ ១២០ ភាគរយ ព្រមទាំងការសម្រាករយៈពេល៣ខែ ក្រោយឆ្លងទន្លេ ទៅតាមច្បាប់ការងារ។ សម្ដេចតេជោ បានបញ្ជាក់ថា "នេះមិនមែនជាការបោកប្រាស់នោះទេ តែគឺជាគោលនយោបាយរបស់រាជរដ្ឋាភិបាល"។

សម្ដេចតេជោនាយករដមន្ត្រីក៏បានថ្លែងទៅកាន់ក្រសួងសុខាភិបាល ឲ្យយកចិត្តទុកដាក់រៀបចំមន្ទីរពេទ្យបង្អែកដែលនៅក្បែរតំបន់រោងចក្រ ត្រូវបន្ថែមអគារ សម្ភារបរិក្ខាពេទ្យ និងគ្រូពេទ្យដើម្បីឆ្លើយតបទៅនិងសេចក្ដីត្រូវការនៃការថែទាំសុខភាពកម្មករ កម្មការិនី និងលើកទឹកចិត្តឲ្យរោងចក្រនីមួយៗបង្កើតឲ្យមានមណ្ឌលសុខភាពនៅក្នុងរោងចក្រ ដោយសម្ដេចលើកឡើងថាក៏ជាផលប្រយោជន៍របស់រោងចក្រផងដែរ ប្រសិនបើកម្មករ មានសុខភាពល្អរោងចក្រក៏ទទួលបានផលិតភាពការងារល្អ និងតំលៃខាងសីលធម៌។ ជាមួយនេះសម្ដេចក៏បានជម្រុញឲ្យតាមរោងចក្រនីមួយៗមានរថយន្តសង្គ្រោះបន្ទាន់ផងដែរ ។

គួររំលឹកថា កាលពីឆ្នាំ ១៩៩៤ កម្ពុជាមានរោងចក្រតែ ៦៣ និងកម្មករ ៨២.០០០ នាក់ រីឯតម្លៃនៃការនាំចេញ គឺត្រឹមតែ២២៧ លានដុល្លារប៉ុណ្ណោះ រហូតមកដល់ពេលបច្ចុប្បន្ននេះ ប្រទេសកម្ពុជាមានរោងចក្ររហូតដល់ទៅចំនួន ១.១០៧ និងកម្មករ ជាង ៧៤ ម៉ឺននាក់ រីឯតម្លៃការនាំចេញ គឺបានកើនឡើងរហូតដល់ទៅ ៧.៦៦៣លានដុល្លារ។ ដោយឡែកប្រាក់ខែ កម្មករនិងកម្មការិនីវិញ គឺបានកើនឡើងពី ៤២ ដុល្លា ដល់ជាង ១៥០ ដុល្លារនៅក្នុងមួយខែ នោះនៅមិនទាន់រាប់បញ្ចូននឹងប្រាក់បន្ថែមម៉ោង និងអត្ថប្រយោជន៍បន្ថែមផ្សេងៗមួយចំនួននៅឡើយទេ។

*ដោយ អរិយបុត្រ*



រូបភាពពីហ្វេសបុក សម្ដេចតេជោ ហ៊ុន សែន

# ទស្សនាទានដ៏វែងឆ្ងាយមួយនឹងនាំឲ្យសហាគមន៍មួយចំនួននៅភូមិភាគនិរតីមានប្រយោជន៍នៅពេលអនាគតដ៏ខ្លី



ថតដោយ អន ហំ

បើទោះបីជាគម្រោងខ្លះទើបតែចាប់ផ្តើមផុះពន្លក ខ្លះមិនទាន់ដំណើរការបានពេញលេញ គម្រោងខ្លះកំពុងដំណើរការប៉ុន្តែទស្សនាទានដ៏វែងឆ្ងាយមួយដែលមាននៅកម្ពុជាកំពុងតែធ្វើឲ្យប្រជាពលរដ្ឋកម្ពុជាជាច្រើននៅភូមិភាគនិរតី ទទួលបាននូវផលប្រយោជន៍ និងមានក្តីសង្ឃឹមប្រកបដោយសុទិដ្ឋិនិយមសម្រាប់អនាគតមួយដ៏ត្រចះត្រចង់នៅពេលអនាគត។

ក្នុងដំណើរប្រមាណជា៨០ គីឡូម៉ែត្របើយើងចេញពីអ័ក្សនៃរាជធានីភ្នំពេញនៅរមណីដ្ឋានវត្តភ្នំហើយធ្វើដំណើរឆ្ពោះមកមហាវិថីសហព័ន្ធរុស្ស៊ី ដោយកាត់តាមព្រលានយន្តហោះអន្តរជាតិភ្នំពេញ ហើយបន្តដំណើរតាមបណ្តោយផ្លូវជាតិ លេខ៣ មកជិតដល់ទីប្រជុំជនមួយនៃស្រុកត្រាំកក់ខេត្តតាកែវ ពោលគឺមុនពេលទៅដល់ផ្សារអង់តាសោមប្រមាណជា ១គីឡូម៉ែត្រងាកមកស្តាំដៃទីនោះគេនឹងឃើញមានសំណង់រាងប្លែកពីសំណង់គេហដ្ឋាន និងភូមិស្រុករបស់ ប្រជាពលរដ្ឋទីនោះ គឺវិទ្យាស្ថានសន្តប៉ូល ដែលនៅទីនោះកូនខ្មែរជាច្រើនកំពុងតែទទួលការអប់រំជាន់ខ្ពស់លើមុខជំនាញមួយចំនួន ដូចជា ព័ត៌មានវិទ្យាអក្សរសាស្ត្រអង់គ្លេស គ្រប់គ្រងទេសចរណ៍ក្សេត្រសាស្ត្រ និងសង្គមកិច្ច និងថ្នាក់បរិញ្ញាបត្ររង លើជំនាញ អភិវឌ្ឍកម្មវិធីកុំព្យូទ័រ គ្រប់គ្រងប្រព័ន្ធ និងបណ្តាញកុំព្យូទ័រ ភាសាអង់គ្លេស សណ្ឋាគារ និងបដិសណ្ឋាកិច្ច ផលិតកម្មដំណាំឈើហូបផ្លែ និងបន្លែ ជំនាញកែច្នៃចំណីអាហារ ប្រព័ន្ធកសិកម្មចម្រុះ និងវេជ្ជសាស្ត្រសត្វ។ នៅក្បែរនោះចម្ងាយប្រមាណជា១០០ ម៉ែត្រមានសំណង់មួយ ដែលកំពុងតែសាងសង់លេចចេញរូបរាង ក្រោមស្លាបត្យកម្មមួយផ្សារភ្ជាប់រវាងបរិស្ថាន វប្បធម៌ និង សង្គម ហើយមានលក្ខណៈស្តង់ដាទំនើបនៅលើដីវាលដ៏ខៀវស្រងាត់មួយ មានទំហំ ៥០០ ម៉ែត្រគុណនិង ៤០០ម៉ែត្រ ហើយអាចត្រូវបានអ្នកដំណើរឆ្ងល់ថា ទីនោះជាអ្វី? សាងសង់ដើម្បីអ្វី? មូលហេតុអ្វីបានជាគេសាងសង់ឡើងនៅទីនោះ?

ជុំវិញគម្រោងទាំងនេះ លោក អូលីវីយេ ឆ្មីតអីស្លែរ អភិបាលព្រះសហគមន៍កាតូលិកភូមិភាគភ្នំពេញបានមានប្រសាសន៍ថា នេះគឺជាសំណង់អាគារថ្មីនៃវិទ្យាល័យឯកទេសសន្ត ហ្វ្រង់ស័រ ដែលកំពុងតែផ្តល់ការសិក្សាដល់ យុវជន និងយុវនារី ខ្មែរប្រមាណជា ៦០ នាក់ លើជំនាញកសិកម្ម ហើយនៅពេលសំណង់សាលានេះសាងសង់រួចនឹងមានឯកទេសទេសចរណ៍មួយទៀត សម្រាប់ផ្តល់ការអប់រំដល់យុវជននិងយុវនារី ។

លោកបានថ្លែងថា សំណង់ នេះត្រូវបានសាងសង់ឡើង ដោយសារតែសាលាចាស់ដែលមានទីតាំងនៅភូមិចំការទៀង ឃុំគូសស្រុកត្រាំកក់ មានលក្ខណៈចង្អៀត។

លោកមានប្រសាសន៍បន្តថា នៅទីតាំងថ្មី យើងកំពុងតែរៀបចំឲ្យមានសួនកសិកម្មគំរូ ដោយមានស្រះមានវាលស្រែ ដែលនឹងឲ្យយុវសិស្សអាចដកស្រង់បទពិសោធន៍ជាក់ស្តែងលើមុខជំនាញ បន្ទាប់ពីពួកគេចំណាយពេល សិក្សាឯកទេសដែលពួកគេជ្រើសរើស ប្រមាណជា២២ម៉ោង និង១០ ម៉ោងលើមុខវិជ្ជាចំណេះដឹងទូទៅ។

នៅក្នុងបរិវេណសាលាដែលទើបតែកំពុងសាងសង់នេះនឹងមាន ដូចជាកសិដ្ឋានគំរូសម្រាប់ចិញ្ចឹមសត្វ ដាំដំណាំ និងបន្លែធ្វើស្រែ មានស្រះចិញ្ចឹមត្រីជាដើម ហើយនិងមានភោជនីយដ្ឋាន និងបន្ទប់ស្នាក់នៅសម្រាប់ជំនាញទេសចរណ៍ ក្រៅពីនោះគឺមានបន្ទប់ស្នាក់របស់សិស្សទាំងពីរភេទដាច់ពីគ្នាសាលសហស្វ័យសិក្សា បន្ទប់ទឹកអាគារសិក្សា...។ល។

លោកបានបន្តថា សាលានេះគឺសាងសង់ឡើងនៅទីតាំងមួយនៅកណ្តាលវិទ្យាល័យរដ្ឋមួយចំនួននៅក្នុងស្រុកត្រាំកក់នេះ និងជាប់វិទ្យាស្ថានសន្តប៉ូល ដើម្បីផ្តល់ការងាយស្រួលនៅក្នុងការស្វែងរកគ្រូល្អៗនិងមានសមត្ថភាព និងមានភាពងាយស្រួលដល់សិស្សនៅក្នុងសហគមន៍។

លោកអូលីវីយេបានបញ្ជាក់ថា " សព្វថ្ងៃវិទ្យាល័យឯកទេសសន្ត ហ្វ្រង់ស័រ គឺជាវិទ្យាល័យដ៏លេចធ្លោរមួយនៅក្នុងចំណោមវិទ្យាល័យឯកទេសប្រាំ នៅកម្ពុជា ហើយនៅពេលទីតាំង និងសំណង់សាលាថ្មីសាងសង់រួចនៅក្នុងពេលឆាប់ៗនេះ សាលាយើងនឹងកាន់តែលេចធ្លោរ"។

កន្លែងនោះ គឺជាទស្សនាទាននៃការចូលរួមការអភិវឌ្ឍន៍ប្រកបដោយសុទិដ្ឋិនិយមមួយសម្រាប់ប្រជាពលរដ្ឋនៅក្នុងតំបន់ ប៉ុន្តែគម្រោងការណ៍នេះមិនមែនមានតែប៉ុណ្ណឹងនោះទេ បន្ទាប់ពីគម្រោងនោះយើងអាចចេញដំណើរបន្តពីទីនោះប្រមាណជាជាង ១៥ គីឡូម៉ែត្រ តាមបណ្តោយផ្លូវជាតិលេខ៣ មកដល់ទីប្រជុំជនតូចមួយ ដែលអ្នកស្រុកគេហៅថាផ្សារឫស្សីស្រុក ស្ថិតនៅតាមបណ្តោយផ្លូវជាតិ នៅក្នុងភូមិសាស្ត្រនៃភូមិឫស្សីស្រុក ឃុំញ៉ៀងញ៉ង ស្រុកត្រាំកក់ដដែល ជាពិសេសនៅក្លោងទ្វារវត្តអង្គមេត្រី ចូលទៅចម្ងាយប្រមាណជា៤ គីឡូម៉ែត្រ គឺមានសំណង់មួយចំនួនកំពុងតែមានការដ្ឋានសាងសង់មួយចំនួន ដូចជា អាគារសាលាមេត្តេយ្យ អាគារសិល្បៈ ជាពិសេសគឺ មណ្ឌលសិប្បកម្មមួយ ដែលទីនោះអាចនឹងក្លាយមណ្ឌលទេសចរណ៍មួយដ៏មានសក្តានុពល សម្រាប់អ្នកទេសចរទាំងឡាយណាដែលធ្វើដំណើរពីភ្នំពេញទៅកម្សាន្តនៅភូមិភាគនិរតីនៅតាមរមណីដ្ឋាននានាដូចជានៅឋានសួគ៌បូកគោ រមណីដ្ឋានទឹកធ្លាក់ធម្មជាតិនានា នៅភ្នំវល្លិ ធម្មជាតិព្រមទាំងវប្បធម៌នៅខេត្តកំពត និងឆ្នេរកែប...។ នៅមជ្ឈមណ្ឌលសិប្បកម្មនេះគឺបានលេចចេញជារូបរាងសឹងតែរួចរាល់នៅតែបំពាក់សំភារៈ និងរៀបចំបន្តិចបន្តួចបន្ថែមប៉ុណ្ណោះ។ ដែលទីនោះ គឺមាន សិប្បកម្មតម្បាញសូត្រ ហូល ក្រមាកន្លែងកាត់ដេរ កន្លែងតាំងពិពរណ៌ មានឆាកសម្តែងសិល្បៈ មានកន្លែងផលិតតែពីស្លឹកគ្រៃ ពីខ្ញី និងផ្កាម្លិះ កន្លែងស្ករគ្រាប់ដូង ស្ករគ្រាប់ចេក ម្នាស់ កន្លែងផលិតសាប៊ូភោជនីយដ្ឋាន និងហាងលក់ផលិតផលនានានៅក្នុងសហគមន៍ជាផលិតផលធម្មជាតិសុទ្ធសាធ ។

លោក អូលីវីយេ បានមានប្រសាសន៍ថា កន្លែងនេះត្រូវបានរៀបចំឡើងគឺ សម្រាប់ឲ្យភ្ញៀវទេសចរដែលមកពីភ្នំពេញកាត់តាមផ្លូវនេះអាចមកលេង មកស្គាល់ផលិតផលធម្មជាតិរបស់ព្រះសហគមន៍កាតូលិករបស់យើង ហើយក៏អាចនឹងក្លាយជាកន្លែងកម្មសិក្សាសម្រាប់យុវសិស្សនៅសាលាឯកទេសនិងពីវិទ្យាស្ថានសន្តប៉ូលរបស់យើង ។

បន្ទាប់ពីចាកចេញពីទីនោះ ទីនោះភ្ញៀវទេសចរអាច និងបន្តដំណើរតាមបណ្តោយផ្លូវជាតិលេខបីទៅតាមរមណីដ្ឋាននានានៅក្នុងខេត្តកំពត និងកែប ប៉ុន្តែនៅក្នុងអនាគតដ៏ខ្លីខាងមុខនេះ សូមកុំភ្លេចបង្កើតកម្មវិធីទេសចររបស់អស់លោកទៅរមណីដ្ឋានមួយនៅរមណីដ្ឋានធម្មជាតិភ្នំវល្លិ។

នៅទីនោះភ្ញៀវទេសចរអាចនឹងចំណាយពេលមួយថ្ងៃ ចាប់ពីម៉ោង ៨ ដល់ ម៉ោង ៤រសៀល ដើម្បីដកស្រង់បទពិសោធន៍ និងរីករាយកម្សាន្តជាមួយនឹងផ្ទាំងទស្សនីភាពធម្មជាតិ និងស្នាដៃរបស់មនុស្ស នៅលើផ្ទៃដីប្រមាណជា ៧០ហិចតា។ បច្ចុប្បន្ននៅទីនោះ មានសួនបន្លែធម្មជាតិ មានចំការពោត ចំការម្រេច ចម្ការស្វាយវង្វេងពូជ ចំការផ្លែស្រកានាគ ចំការម្រុំ កសិដ្ឋានចិញ្ចឹមទាកសិដ្ឋានចិញ្ចឹមពពែ កសិដ្ឋានចិញ្ចឹមគោកសិដ្ឋានចិញ្ចឹមជ្រូក...។

លោកអូលីវីយេ មានប្រសាសន៍ថា នៅទីនេះយើងកំពុងតែរៀបចំឲ្យក្លាយជាសួនកសិកម្ម និងទេសចរណ៍ធម្មជាតិមួយសម្រាប់អ្នកទេសចរដែលចាប់អារម្មណ៍មកកម្សាន្តនៅភូមិភាគនិរតី ឲ្យពួកគេអាចទទួលយកនូវបទពិសោធន៍ និងការកម្សាន្តដ៏មានប្រយោជន៍មួយ ហើយក៏ជាកន្លែងយើងរៀបចំធ្វើជាកន្លែងកម្មសិក្សាដកស្រង់បទពិសោធន៍សម្រាប់យុវសិស្ស និងយុវនិស្សិតនៅសាលាវិទ្យាល័យឯកទេស និងវិទ្យាស្ថាន។ លោកបន្តទៀតថា នៅទីនេះអ្វីៗគឺធម្មជាតិទាំងអស់ សូម្បីតែការចិញ្ចឹមជ្រូកដោយយើងយកពោតយកផលិតផលនៅទីនេះធ្វើជាចំណីរបស់វាតែម្តង។

លោកអូលីវីយេ បញ្ជាក់ថា រាល់សកម្មភាព គម្រោងទាំងនេះគឺ ដើម្បីជួយប្រជាពលរដ្ឋក្នុងសហគមន៍ជាពិសេសអ្នកក្រីក្រតូចតាច អ្នកខ្វះលទ្ធភាព ឲ្យមានចំណេះដឹងជំនាញពិតប្រាកដ មានការងារធ្វើ ដែលអាចចិញ្ចឹមជីវិតរបស់គេបានដោយសមរម្យចូលរួមអភិវឌ្ឍសង្គមកម្ពុជាឲ្យចម្រើនឡើងថែមទៀត។

ដោយ អរិយបុត្រ

# កម្ពុជារួមដំណើរជាមួយនឹងអាស៊ានបាន ១៨ឆ្នាំហើយ



ថតដោយ សម្បត្តិ

អាស៊ានបានចាប់ផ្តើមកកើតឡើងបានចំនួន ៥០ឆ្នាំហើយ ដោយឡែកកម្ពុជាបានចូលរួមជាមួយអាស៊ានបាន១៨ឆ្នាំ ។

ក្រោយពេលដែលចាប់កំណើតឡើង កាលពីថ្ងៃទី០៨ ខែសីហា ឆ្នាំ១៩៦៧ ដោយប្រទេស ៥គឺ ឥណ្ឌូនេស៊ី ម៉ាឡេស៊ី ហ្វីលីពិន សិង្ហបុរី និង ថៃ អង្គការអន្តររដ្ឋាភិបាលតំបន់មួយនេះបានបន្តពង្រីកសមាជិកភាពរហូតដល់ទៅ ៥ទៀត ដែលមាន ប្រ៊ុយណេ ឡាវ ភូមា វៀតណាម និង កម្ពុជាជា កូន ពៅ ហើយបានបន្តរួមដំណើរគ្នារហូតដល់ឆ្លងផុតប្រវត្តិដែលមានរយៈពេល ៥០ឆ្នាំ ទាំងអស់គ្នា ប្រកបដោយមោទនភាព បើទោះបីជាកន្លងមកសមាជិកអាស៊ានបានជួបរឿងខ្វែងគំនិតគ្នាលើបញ្ហាមួយចំនួនយ៉ាងណាក៏ដោយ ប៉ុន្តែនៅតែបន្តរួមដំណើរជាមួយគ្នា រហូតដល់អាស៊ានបង្កើតបានជា សហគមន៍តែមួយវាសនាតែមួយ ។

យោងទៅតាមប្រវត្តិដែលដកស្រង់ចេញមកពីលេខាធិកាដ្ឋានអាស៊ានដែលមានមូលដ្ឋាន នៅទីក្រុង ហ្សាកាតា ប្រទេសឥណ្ឌូនេស៊ី បានឲ្យដឹងថា កម្ពុជាបានក្លាយជាមាជិករបស់ អាស៊ាននេះ តាំងតែ ពីថ្ងៃទី៣០ ខែមេសា ឆ្នាំ១៩៩៩។

ចាប់តាំងពីចូលរួមអាស៊ាន នៅឆ្នាំ ១៩៩៩ មកដល់ពេលនេះ គឺវាមានរយៈពេលជាង ១៨ ឆ្នាំហើយដូច្នេះវាមានន័យថា កម្ពុជាយើងដែលជាកូនពៅ នៃអាស៊ាននោះ ក៏ចម្រើនវ័យបាន ១៨ ឆ្នាំ ពោល គឺពេញវ័យពេញកម្លាំងល្មមអាចក្លាយជាធនធានមួយដ៏សក្តានុពលនឹងគេហើយក្រោយពេលដែលបានចំណាយពេលសិក្សាដកស្រង់បទពិសោធន៍រៀនសូត្រ ពីបងៗចាស់ៗដែល បង្កើត អាស៊ាន និងកកើតក៏ដូចជាចូលអាស៊ានជាបន្តបន្ទាប់មកនោះ។

លោក សុរិន ពិនសុវណ្ណ អតីតរដ្ឋមន្ត្រីការបរទេសថៃ និងជាអតីតអគ្គលេខាធិការអាស៊ាន ដែលគេ ដឹងថា អាស៊ានបានសម្រេចនូវក្តីសុបិន្តនៅក្នុងការពង្រីកសមាជិកភាពអាស៊ានទាំង១០ បើទោះបីជាជួបបញ្ហាខ្លះឡើងខ្លះចុះ ប៉ុន្តែសមាជិកអាស៊ានទាំងអស់គឺបានបង្ហាញអំពីការស្រុះស្រួលគ្នាពិភាក្សាគ្នាអំពីបញ្ហានានា រួមទាំងបញ្ហានយោបាយ និងសន្តិសុខ ហើយអាចរក្សានូវស្ថិរភាពនិង សន្តិភាពនៅក្នុងតំបន់។

លោកបានបន្តថា ប្រជាជាតិអាស៊ានបានរួបរួមគ្នា រកឃើញនូវសមិទ្ធិផលដ៏ប្រសើរនៅក្នុង ការជួយ កែលំអរនូវស្តង់ដាជីវភាពប្រជាពលរដ្ឋនៅក្នុងតំបន់ ដែលមានចំនួន ប្រមាណជា៦២០លាននាក់ ។ សព្វថ្ងៃនេះ អាស៊ានកំពុងតែជួយឲ្យប្រជាពលរដ្ឋជាច្រើនបានអភិវឌ្ឍន៍ ជីវភាពរបស់ពួកគេ ទៅជាវណ្ណៈកណ្តាល ហើយកម្លាំងនៃការទិញរបស់ប្រជាជាតិអាស៊ាន ទាំងអស់ក៏មានការកើនឡើង ដោយអត្រាផលិតផលនៅក្នុងស្រុកសរុបរបស់អាស៊ាននៅពេលនេះ បានឈានដល់ ២,៥ ទ្រីលាន ដុល្លារ ទីផ្សារដ៏បើកចំហរដោយតម្លៃនៃទំហំពាណិជ្ជកម្មបានឡើងរហូតដល់ទៅ ២,៦ ទ្រីលាន ដុល្លារ ហើយលំហូរនៃការបណ្តាក់ទុន បរទេស គឺនៅក្នុងចន្លោះ ពី ១៣០ ទៅ១៥០ ពាន់លាន ដុល្លារជារៀងរាល់ឆ្នាំ។

លោកបានថ្លែងថា អាស៊ានមិនមែនជាប្រជាជាតិដែលឯកោនោះទេ។ បណ្តាប្រទេសនៅក្នុង អាស៊ានបានកំពុងតែ ស្វែងរកនូវឱកាសនិងបានធ្វើសមាហរណកម្មយ៉ាងសកម្ម តាមរយៈការចែករំលែកនូវការផ្លាស់ប្តូរនយោបាយ សេដ្ឋកិច្ច គោលដៅសង្គមនិងសេដ្ឋកិច្ច ការផ្លាស់ប្តូរនៅក្នុងតំបន់ និងសកល។ ចលនាទាំងនេះ គឺបានជំរុញឲ្យប្រជាជាតិអាស៊ាន ទាំងអស់សម្រេចបាននូវគោលដៅជាច្រើន នៅក្នុងដំណើរដែលមានរយៈពេល ៥០ ឆ្នាំកន្លងទៅនេះ ។

នេះជាសមិទ្ធិផលរបស់អាស៊ាន។ ចុះកម្ពុជានៅក្នុងអំឡុងពេលជិត២ទស្សវត្សរ៍នេះ កម្ពុជាសម្រេចបានសមិទ្ធិផលអ្វីខ្លះ?

សម្តេចតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជាបានថ្លែងជាសាធារណៈនៅក្នុងពិធីប្រកាសដាក់ឲ្យប្រើប្រាស់ជាផ្លូវការនូវឯកសារ ក្រមខណ្ឌគោលនយោបាយ ជាតិគាំ ពារសង្គម ២០១៦-២០២៥ ថា ក្នុងអំឡុងពេលប្រមាណ ២ ទស្សវត្សរ៍កន្លងទៅ សេដ្ឋកិច្ចកម្ពុជា សម្រេចបាននូវកំណើនក្នុងអត្រាជាមធ្យម ប្រមាណ ៧,៧។ អត្រានៃភាពក្រីក្រត្រូវបានកាត់បន្ថយពីប្រមាណ៥៣% នៅឆ្នាំ២០០៤ មកប្រមាណ ១៣,៥% នៅឆ្នាំ ២០១៤។ លើសពីនេះ ផ្លែផ្កានៃកំណើនសេដ្ឋកិច្ចក៏ត្រូវបានបែងចែកក្នុងលក្ខណៈកាន់តែមានសមធម៌ ដែលត្រូវបានឆ្លុះបញ្ចាំងតាមរយៈការថយចុះនៃមេគុណវិសមភាពនៃការប្រើប្រាស់ពី០,៤១ នៅឆ្នាំ ២០០៧ មកនៅត្រឹម ០,២៩ នៅឆ្នាំ ២០១២ ជាមួយនឹងការរំពឹងថា តួលេខនេះនឹងបន្តថយចុះថែមទៀតក្នុងឆ្នាំបន្តបន្ទាប់។

សម្តេចតេជោ ហ៊ុន សែន បានថ្លែងថារាជរដ្ឋាភិបាលកម្ពុជាមានចក្ខុវិស័យវែងឆ្ងាយក្នុងការប្រែក្លាយឋានៈរបស់កម្ពុជាពីប្រទេសមានចំណូលមធ្យមកម្រិតទាបនាពេលបច្ចុប្បន្ន ឱ្យទៅជាប្រទេសមានចំណូលមធ្យមកម្រិតខ្ពស់ នៅឆ្នាំ២០៣០ និងទៅជាប្រទេសមានចំណូលខ្ពស់នៅឆ្នាំ ២០៥០។

កន្លងមកនៅក្នុងបរិបទអាស៊ានសម្តេចតេជោ ហ៊ុន សែន ធ្លាប់បានថ្លែងថា ក្នុងនាមជាសមាជិកមួយប្រកបដោយស្មារតីទទួលខុសត្រូវនៅក្នុងតំបន់ កម្ពុជាត្រៀមខ្លួនជាស្រេច ដើម្បីរួមចំណែកជាមួយដៃគូពាក់ព័ន្ធទាំងអស់ ក្នុងការធ្វើកិច្ចការចាំបាច់នានាសំដៅឈានទៅសម្រេចឱ្យបាននូវ "ចក្ខុវិស័យអាស៊ាន២០២៥ ឆ្ពោះទៅមុខទាំងអស់គ្នា" ដើម្បីសន្តិភាព សន្តិសុខ ស្ថិរភាព និងវិបុលភាពយូរអង្វែងសម្រាប់ប្រជាជាតិទាំងអស់នៅក្នុងតំបន់។

សម្តេចបានថ្លែងថា កម្ពុជាជាសេដ្ឋកិច្ចតូចតែបើកចំហ ដូច្នេះ នេះគឺជាមូលហេតុចម្បងដែលនាំឱ្យយើងផ្តល់សារៈសំខាន់ខ្ពស់ទៅលើការធ្វើសមាហរណកម្ម និងការតភ្ជាប់ក្នុងតំបន់។ ជាលទ្ធផលកម្ពុជាត្រូវបានចាត់ទុកថា ជាសេដ្ឋកិច្ចមួយក្នុងចំណោមសេដ្ឋកិច្ចដែលលូតលាស់ថ្មី ហើយក៏ត្រូវបានចាត់ទុកជាប្រទេសរងគ្រោះដោយសង្គ្រាម ដែលមានភាពជោគជ័យជាងគេដោយផ្អែកលើអត្រាកំណើនសេដ្ឋកិច្ចរឹងមាំជាមធ្យម ៧,៦% ប្រចាំឆ្នាំក្នុងចន្លោះពីឆ្នាំ១៩៩៤ ដល់២០១៦ ហើយរក្សាបាននូវស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច មានអត្រាអតិផរណាដែលអាចគ្រប់គ្រងបាន មានការគ្រប់គ្រងបំណុល សាធារណៈល្អប្រសើរ សម្រេចបាននូវការកាត់បន្ថយភាពក្រីក្រឆាប់រហ័ស ព្រមទាំងទទួលបាននូវកំណើននៃផលិតផលក្នុងស្រុកសរុបសម្រាប់មនុស្សម្នាក់ៗ ៤,៥ ដង ពី ២៨៨ ដុល្លារ នៅឆ្នាំ ២០០០ មកដល់ ១៣០២ ដុល្លារ នៅឆ្នាំ ២០១៦។ ជាការពិត ពាណិជ្ជកម្មបានដើរតួនាទីយ៉ាងសំខាន់ក្នុងការរីកលូតលាស់នៃសេដ្ឋកិច្ចកម្ពុជាក្នុងពេលកន្លងមក។

សម្តេចតេជោ ក៏បានថ្លែងបន្តថា ការចូលរួមក្នុងសហគមន៍សេដ្ឋកិច្ចអាស៊ាន និងអង្គការពាណិជ្ជកម្មពិភពលោកបានជួយជំរុញការតភ្ជាប់កម្ពុជានៅនឹងខ្សែចង្វាក់តម្លៃ និងខ្សែចង្វាក់ផលិតកម្ម នៅក្នុងតំបន់ និងពិភពលោក។ សម្រាប់រយៈពេលមធ្យមខាងមុខ កំណើនសេដ្ឋកិច្ចរបស់កម្ពុជាត្រូវបានព្យាករថា នឹងបន្តភាពរឹងមាំរបស់ខ្លួន នៅក្នុងរង្វង់ ៧,០% ក្នុងមួយឆ្នាំ។

ដោយ អរិយបុត្រ

# អត្តពលិកកម្ពុជារកបាន១៧មេដាយពីការប្រកួតស៊ីហ្គេមនៅម៉ាឡេស៊ី

គណៈកម្មការជាតិអូឡាំពិកកម្ពុជាបានប្រកាសកាលពីថ្ងៃទី២៩ ខែសីហា ឆ្នាំ ២០១៧ ថា អត្តពលិកកម្ពុជាដែលត្រូវបានបញ្ជូនទៅចូលរួមការប្រកួតកីឡាស៊ីហ្គេមលើកទី២៩ នៅប្រទេសម៉ាឡេស៊ីនាឆ្នាំនេះអាចរកមេដាយត្រឡប់មកមាតុភូមិវិញសរុបចំនួន ១៧ មេដាយ។

ប្រភពដដែលបានប្រកាស ថា អត្តពលិកកម្ពុជាអាចរកបាន មេដាយមាសសរុបចំនួន ៣ មេដាយប្រាក់២ និងមេដាយសំរិទ្ធចំនួន ១២។ ប្រភពដដែលបានបញ្ជាក់ថា "ជាមួយនឹងមេដាយដែលរកបាន ព្រះរាជាណាចក្រកម្ពុជា អាចឈរនៅលេខរៀងទី ៨ នៅក្នុងចំណោមប្រទេស ១១ ដែលបានចូលរួមប្រកួតកីឡា ស៊ីហ្គេមឆ្នាំនេះ"។

ប្រភពដដែលបានបន្តថា អ្នកដែលរកបានមេដាយមាសទីបី ដែលជាមេដាយមាស ចុងក្រោយគេ សម្រាប់កម្ពុជានោះ គឺវីរកីឡាការនី ស៊ន សៀវម៉ី អតីតម្ចាស់មេដាយមាស លើវិញ្ញាសារកីឡាតៃក្វាន់ដូអាស៊ី កាលពីឆ្នាំ២០១៤ នៅក្នុងការប្រកួតនៅប្រទេសកូរ៉េខាងត្បូង។

ប្រភពដដែលបានបន្តថា សម្រាប់កីឡាករដែលដណ្តើមមេដាយមាសដែរនោះ គឺកីឡាករ ឃឹម ឌីម៉ា លើវិញ្ញាសារប្រដាល់គុនខ្មែរ និងកីឡាការនី ប៉ែតង់ជាគូ ដែលបានទៅ លើកីឡាការនី កែ ឡេង និង អ៊ុក ស្រីមុំ ។

ជុំវិញស្នាដៃរបស់អត្តពលិកខ្មែរលើកនេះ សម្តេចតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជាក៏បានចែករំលែកការអបអរតាមបណ្តាញសង្គមផ្លូវការរបស់សម្តេចផ្ទាល់ផងដែរ។ សម្តេចតេជោហ៊ុន សែន បានបញ្ជាក់ថា "ខ្ញុំសូមអបអរសាទរដល់កីឡាប្រដាល់គុនខ្មែរ ឃឹម ឌីម៉ា ដែលទើបបានទទួលមេដាយមាសបន្ទាប់ពីបាន ប្រកួតឈ្នះកីឡាករថៃ និងកីឡាការិនី ស៊ន សៀវម៉ី ដែលបានប្រកួតឈ្នះកីឡាការិនីប្រទេសហ្វីលីពីន នៅក្នុងការប្រកួតកីឡាស៊ីហ្គេម (Sea Games) លើកទី២៩ ដែលកំពុងប្រព្រឹត្តទៅនៅប្រទេសម៉ាឡេស៊ី នៅថ្ងៃនេះ"។

សម្តេចតេជោ ហ៊ុន សែន បានបន្តទៀតថា នេះជាមោទនភាពជាតិយើងទាំងមូល ហើយខ្ញុំក៏សូមជូនពរដល់កីឡាករកីឡាការិនីក្នុងផ្នែកវិញ្ញាសារ ដទៃទៀតទទួលបានជោគជ័យដូចគ្នានៅក្នុងការប្រកួតស៊ីហ្គេមនៅប្រទេសម៉ាឡេស៊ី៕

# កម្ពុជាចុះហត្ថលេខាលើកិច្ចព្រមព្រៀងក្របខ័ណ្ឌស្តីពីកិច្ចសម្រួលពាណិជ្ជកម្មឆ្លងកាត់ព្រំដែនរបស់អ.ស.ប

ប្រទេសកម្ពុជាបានក្លាយជាប្រទេសហត្ថលេខីថ្មីមួយលើកិច្ចព្រមព្រៀងក្របខ័ណ្ឌ ស្តីពីកិច្ចសម្រួលពាណិជ្ជកម្មឆ្លងកាត់ព្រំដែនដោយពុំប្រើប្រាស់ក្រដាសស្នាមសម្រាប់តំបន់អាស៊ីប៉ាស៊ីហ្វិក កាលពីព្រឹកថ្ងៃទី២៩ ខែសីហា ឆ្នាំ២០១៧ រួមជាមួយនឹងប្រទេសចិន និងបង់ក្លាដេស។ នេះបើតាមការអះអាងរបស់ក្រសួងពាណិជ្ជកម្មតាមសេចក្តីប្រកាសមួយ នៅលើបណ្តាញសង្គម។

ប្រភពដដែលបានបន្តថា កិច្ចព្រមព្រៀងនេះត្រូវបានចុះនៅទីស្នាក់ការកណ្តាលនៃគណៈកម្មាធិការសេដ្ឋកិច្ច និងសង្គមសម្រាប់អាស៊ី-ប៉ាស៊ីហ្វិករបស់អង្គការសហប្រជាជាតិ (UNESCAP) នៅទីក្រុងបាងកក ប្រទេសថៃ ដោយ លោក ប៉ាន សូរស័ក្តិ រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម។

ប្រភពដដែលបានបញ្ជាក់ថា នេះគឺជាកិច្ចព្រមព្រៀងមួយដែលកម្ពុជាចុះ ក្នុងគោលបំណងជំរុញការធ្វើពាណិជ្ជកម្មរវាងប្រទេសជាសមាជិក តាមរយៈការប្រើប្រាស់ឯកសារនាំចេញ-នាំចូល ជាទម្រង់អេឡិចត្រូនិកដោយមិនចាំបាច់ប្រើក្រដាសស្នាម និងកំណត់វិធានជាមូលដ្ឋាន ព្រមទាំងបង្កើតយន្តការនានា សម្រាប់គាំទ្រដល់ការទទួលស្គាល់នូវឯកសារ និងទិន្នន័យទាក់ទងនឹងការនាំចេញ-នាំចូល ដែលកិច្ចការនេះមានលក្ខណៈប្រហាក់ប្រហែលគ្នានឹងគម្រោងបញ្ជរតែមួយអាស៊ាន និងបញ្ជរតែមួយជាតិ ផងដែរ។

ប្រភពដដែលបានបញ្ជាក់ថា ក្រោយពីចុះហត្ថលេខា ប្រទេសកម្ពុជា នឹងបន្តរៀបចំហេដ្ឋារចនាសម្ពន្ធបច្ចេកវិទ្យាព័ត៌មាន តាមក្រសួង-ស្ថាប័នពាក់ព័ន្ធ កសាងលិខិតបទដ្ឋានគតិយុត្ត និងបណ្តុះបណ្តាលធនធានមនុស្សជាបណ្តើរៗ តាមរយៈការផ្តល់ជំនួយបច្ចេកទេសពីដៃគូអភិវឌ្ឍន៍នានា ពិសេសគណៈកម្មាធិការ UNESCAP មុននឹងផ្តល់សច្ចាប័ន និងជូនដំណឹងទៅ UNESCAP អំពីការចាប់ផ្តើមអនុវត្តកិច្ចព្រមព្រៀងនេះ។

# ក្រសួងមហាផ្ទៃប្តឹងរំលាយគណបក្សនយោបាយចំនួន៩

គណបក្សនយោបាយចំនួន០៩នៅកម្ពុជា ត្រូវបានក្រសួងមហាផ្ទៃ ប្តឹងទៅតុលាការកំពូលស្នើសុំរំលាយ ដោយសារតែបានប្រព្រឹត្តល្មើសនឹងច្បាប់ស្តីពីគណបក្សនយោបាយ លើមាត្រាមួយចំនួន។

យោងទៅតាមលិខិតរបស់សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងមហាផ្ទៃ គណបក្សទាំង ៩ នោះ គឺរួមមាន គណបក្សប្រជាជាតិខ្មែរ គណបក្សពលរដ្ឋខ្មែរ គណបក្សសង្គមខ្មែរនិយម គណបក្សសង្គមថ្មី គណបក្សខ្មែរជាតិនិយម គណបក្សនាងនាគនារីខ្មែរ គណបកក្សពន្លឺសេរីភាពលោកថាច់រ៉េង គណបក្សស្ត្រីសង្គ្រោះកម្ពុជា គណបក្សសេរីបង្រួបបង្រួមជាតិ។

ប្រភពដដែលបានបន្តថា គណបក្សទាំងនោះ បានប្រព្រឹត្តល្មើសនឹងបទបញ្ញត្តមាត្រា៣១ នៃច្បាប់ស្តីពីគណបក្សនយោបាយ ដោយមិនបានផ្ញើរបាយការណ៍ប្រចាំឆ្នាំជូនមកក្រសួងមហាផ្ទៃតាមឆ្នាំនីមួយៗជាបន្តបន្ទាប់ ហើយមួយចំនួនក៏កំពុងជាប់បណ្តឹងនៅសាលាដំបូងរាជធានីភ្នំពេញផងដែរ។ ក្រៅពីនោះគណបក្សនយោបាយខាងលើ ក៏មិនបានបំពេញកាតព្វកិច្ចក្នុងការបំពេញបែបបទផ្ញើមកក្រសួងមហាផ្ទៃស្របតាមបទបញ្ញត្តដូចមានចែងនៅក្នុងមាត្រា២៦ថ្មី និងមាត្រា៤៨ថ្មី នៃច្បាប់ស្តីពីគណបក្សនយោបាយដដែល។

នៅកម្ពុជាមានគណបក្សនយោបាយមានចំនួនសរុប៧១ ក្នុងនោះគណបក្សបានបង្កើតប៉ុន្តែមិនបានចុះបញ្ជីមាន២៤គណបក្សនិងគណបក្សដែលបានចុះបញ្ជី ៤៧គណបក្ស ហើយកាលពីឆ្នាំ២០១៦ ក្រសួងមហាផ្ទៃបានសម្រេចចុះបញ្ជីគណបក្សនយោបាយចំនួន៣អនុញ្ញាតឲ្យបង្កើតគណបក្សនយោបាយចំនួន៦ និងលុបឈ្មោះគណបក្សនយោបាយចំនួន១៕

# កម្ពុជាកំពុងសិក្សាពីលទ្ធភាពបង្កបង្កើនផលស្រូវប្រភេទថ្មីពីរទៀត

កាសែតក្នុងស្រុកមួយបានធ្វើសេចក្តីរាយការណ៍ថា ក្រុមហ៊ុននាំចេញអង្ករមួយចំនួនកំពុងតែសិក្សាអំពីលទ្ធភាពបង្កបង្កើនផលដើម្បីផលិតស្រូវប្រភេទថ្មីចំនួនពីរទៀតសម្រាប់ការធ្វើពិពិធកម្មទីផ្សារ ក្នុងការនាំចេញអង្ករ។

លោក សុង សារ៉ន អគ្គនាយកក្រុមអេមរូ បានថ្លែងប្រាប់ប្រភពខាងលើថា ស្រូវថ្មីមួយនៅក្នុងចំណោមស្រូវទាំងពីរពូជ គឺមានស្រូវប្រភេទ ជប៉ុនីកា (Japonica) ដែលជាប្រភេទស្រូវផលិតជាអង្ករដែលគេសម្រាប់យកមកចំអិនធ្វើស៊ូឈី អាហារដ៏ល្បីល្បាញរបស់ជនជាតិជប៉ុន។ លោកបានបន្តថា ស្រូវប្រភេទនេះ ប្រសិនជាស្ថិតនៅក្រោមលក្ខខណ្ឌអាកាសធាតុលើស២៥អង្សារសេនៅពេលយប់ មិនអាចដាំបាននោះទេដូច្នេះវាអាចមានសក្តានុពល នៅតែខេត្តព្រះវិហារ រតនគិរី និងខេត្តមណ្ឌលគិរី ប៉ុណ្ណោះ។

ប្រភពដដែលបានបន្តថា នៅកម្ពុជាមានការសាកល្បងដាំស្រូវនេះហើយ តែមិនសូវទទួលបានទិន្នផល ដោយសារតែលក្ខខណ្ឌអាកាសធាតុ។ រហូតមកដល់ពេលនេះក្រសួងកសិកម្មបានផលិតពូជស្រូវ១០ប្រភេទសម្រាប់ដាំដុះនៅកម្ពុជា ប៉ុន្តែមានតែស្រូវបីប្រភេទប៉ុណ្ណោះដែលមានការដាំដុះមានទីផ្សារល្អ តម្លៃប្រសើរ គឺផ្ការំដួល សែនក្រអូប និងស្រូវផ្កាម្លិះ។

# សម្រាប់ពិធីកាន់បិណ្ឌ និងភ្ជុំបិណ្ឌខាងមុខនរណាក៏

ពលរដ្ឋកម្ពុជាគ្រប់គ្រួសារ គឺសុទ្ធតែត្រៀមខ្លួនរួចហើយនៅក្នុងការចំណាយសម្រាប់ពិធីបុណ្យប្រពៃណីមួយដែលនឹងមកដល់នៅចុងខែ កញ្ញាខាងមុខនេះ ដោយគ្រាន់តែការចំណាយនោះ គឺទៅតាមធន-ធានតាមលទ្ធភាពរបស់បុគ្គលម្នាក់ៗតែប៉ុណ្ណោះ។

តាមការស្ទាបស្ទង់មួយដែលអ្នកនាំសារបានធ្វើទៅលើប្រជាពលរដ្ឋប្រមាណជា ១០ នាក់ នៅក្នុងកម្រិតជីវភាព និងស្ថានភាពប្រាក់ចំណូលផ្សេងៗគ្នាពីចន្លោះថ្ងៃទី១២ ដល់២២ ខែសីហា ឆ្នាំ២០១៧ បានឲ្យដឹងថា ការចំណាយរបស់ពលរដ្ឋកម្ពុជាម្នាក់ដែលមានការងារធ្វើ នៅរាជធានីភ្នំពេញ អាចមានចាប់ពីជាង ៤០០.០០០ រៀល ឡើងទៅ ហើយ ការចំណាយនោះគឺ មាន ចាប់ពីសោហ៊ុយនៅក្នុងការធ្វើដំណើរ ការហូបចុក ការផឹកស៊ី ការជូនចាស់ៗ ញាតិសន្តាន និងការកំសាន្តផ្សេងៗ ខណៈដែលអ្នកដែលមានធនធានគឺអាចនឹងចំណាយដល់ទៅរាប់ពាន់ដុល្លារដើម្បីការចំណាយទាំងអម្បាលម៉ាន ជាពិសេសគឺលើដំណើរទេសចរណ៍ចេញទៅក្រៅប្រទេស នៅក្នុងអំឡុងពេលសម្រាកបុណ្យភ្ជុំបិណ្ឌខាងមុខនេះ។

កញ្ញា លី ស្រីណៃ ជាអ្នកធ្វើការតាមផ្ទះមួយរូបនៅរាជធានីភ្នំពេញបានឲ្យដឹងថា នាងអាចត្រូវចំណាយយ៉ាងហោចណាស់ក៏ប្រាក់ខែមួយខែដែរសម្រាប់ការចំណាយនៅពេលពិធីបុណ្យកាន់បិណ្ឌ និងភ្ជុំបិណ្ឌនៅពេលខាងមុខនេះ។

ស្រីណៃ ដែលមានប្រាក់បៀវត្សរ៍១១០ ដុល្លារនៅក្នុងមួយខែ បានថ្លែងថា នេះគឺជាការចំណាយដែល នាងបានត្រៀមសម្រាប់ចូលរួមដើម្បីការជួបជុំគ្រួសារនៅក្នុងថ្ងៃសម្រាក ដែលនៅក្នុងមួយឆ្នាំ គឺអាចមាន ២ដង គឺម្តងនៅពេលចូលឆ្នាំខ្មែរប្រពៃណីជាតិនិង ម្តងគឺនៅបុណ្យភ្ជុំបិណ្ឌនេះតែម្តងដោយម្តងៗ គឺនាងតែងតែចំណាយប្រាក់ខែមួយខែតែម្តង ហើយជួនកាលក៏អាចលើសនេះខ្លះដែរ។

ស្រីណៃបានបញ្ជាក់ថា "ខ្ញុំត្រៀមប្រាក់ខែម្តងមួយខែនេះ! ខ្ញុំត្រៀមចំណាយបែបនេះ ពីរទៅ បីឆ្នាំហើយតាំងពីខ្ញុំមានការងារធ្វើនៅភ្នំពេញមក"។

បើតាមការរៀបរាប់របស់ស្រីណៃ ការចំណាយ ប្រមាណជាជាង៤០០.០០០ រៀលនេះ មិនមែនជា ការចំណាយដែលនាងចំណាយគ្រប់គ្រាន់សម្រាប់គ្រួសារនោះទេ នៅក្នុងអំឡុងពេលសម្រាកនាពិធីបុណ្យភ្ជុំបិណ្ឌខាងមុខនោះ សូម្បីតែប្អូន និងបងរបស់នាង ដែលកំពុងតែធ្វើការនៅភ្នំពេញដូចគ្នា ក៏ពួកគេម្នាក់ៗគ្រោងចំណាយមិនតិចជាងនាងដែរ ដូច្នេះមួយគ្រួសារសម្រាប់ការចំណាយនៅក្នុងពេលសម្រាកបុណ្យប្រពៃណីជាតិម្តងៗ គឺអាចនឹងមានច្រើនពោលគឺអាចចូលដល់រាប់ម៉ឺនរៀល ឬរាប់រយដុល្លារ។

ស្រីណៃបានរៀបរាប់ថា ការចំណាយគឺអត់មានអ្វីឲ្យធំដុំទេ គឺកំប៉ិកកំប៉ុកប៉ុណ្ណោះ ប៉ុន្តែបើមិនគិត គឺអត់ដឹងលុយទៅណាអស់ឥឡូវ។ ស្រីណៃបានបន្តថា នាងត្រូវចំណាយប្រហែលជា ៧ទៅ៨ ម៉ឺនរៀល លើសោហ៊ុយឈ្នួលឡានទៅមក ចុះនៅជូនចាស់ៗលោកតាលោកយាយ ជូនក្មួយៗ អស់ប្អូនទៅដប់ម៉ឺនរៀលទៀត ក្រៅពីនេះមានទិញប៊ីយ៉ែ ទិញម្ហូបអីញ៉ាំជុំគ្នាប្អូន ទៅ ប្រាំម៉ឺនរៀនទៀត ហើយនៅការចំណាយស៊ីចុកចាក់សាំងម៉ូតូជិះដើរលេងទៅណោះទៅណោះទៀត។



ស្រីណៃបានបញ្ជាក់ថា "នេះចេះបានម្ចាស់ផ្ទះដែលខ្ញុំនៅជាមួយ គាត់ទិញនេះទិញនោះដូចជា ប៊ីចេង ទឹកត្រីទឹកស៊ីអ៊ីវ ខោអាវ នំធុង ឲ្យទ្រនាប់ដៃទេ កុំអីមិនគ្រាន់ទេលុយ៤០ ម៉ឺនរៀលអីនោះ"។

លោកស្រី អ៊ិន ចាន់ណា ដែលជានារីបម្រើការនៅរោងចក្រកាត់ដេរមួយរូប បានថ្លែងដោយប្រយោល និងប្រហាក់ប្រហែលថា សម្រាប់លោកស្រី ការចំណាយនេះមិនតិចមិនច្រើនជាង ១ លានរៀលទេ។

លោកស្រី ចាន់ណា ដែលមានស្វាមីជាអ្នករត់រ៉ឺម៉កកង់បីនៅក្នុងរាជធានីភ្នំពេញផងដែរនោះ បានរៀបរាប់បញ្ជាក់ថា "មិនតិចទេ ! លុយខំរក ខំសន្សំ ចាយតែម៉ាព្រូម៉ាភ្ជុំបិណ្ឌខាងមុខនេះគឺសឹងតែអស់លុយសន្សំ។ ស្ទិតក្រពះ ទៀតហើយគ្រួសារខ្ញុំ"។

លោកស្រីបានបន្តទៀតថា ការចំណាយនោះគឺសឹងតែមិនខុសពី ស្រីណៃ ខាងលើប៉ុន្មានទេ ប៉ុន្តែលោកស្រីសង្កត់ធ្ងន់ថា គ្រួសារលោកស្រី ច្រើនចំណាយច្រើនបន្តិចលើរឿងផឹកស៊ីហូបចុកជួបជុំបងប្អូននៅឯផ្ទះ នាស្រុកកំណើត។

លោកស្រីចាន់ណា ដែលកំពុងស្នាក់នៅផ្ទះជួលនៅរាជធានីភ្នំពេញបានបញ្ជាក់ថា

## ភ្ជុំបិណ្ឌជារដូវសម្រាកដែលពលរដ្ឋកម្ពុជាធ្វើដំណើរទេសចរណ៍ច្រើនមួយ

ភ្ជុំបិណ្ឌត្រូវបានគេដឹងថា គឺជារដូវសម្រាកដ៏ធំហើយក៏មានប្រជាពលរដ្ឋកម្ពុជាធ្វើដំណើរទេសចរណ៍ទាំងក្នុងនិងក្រៅប្រទេសដ៏ច្រើនបំផុតមួយនៅក្នុងចំណោមបុណ្យធំៗមួយចំនួនផ្សេងទៀត ដូចជា ចូលឆ្នាំខ្មែរប្រពៃណីជាតិ បុណ្យចូលឆ្នាំចិន បុណ្យអុំទូកអកអំបុកសំពះព្រះខែ និងបុណ្យចូលឆ្នាំសាកលជាដើម។

លោក ខេង ពិសិដ្ឋជាប្រជាពលរដ្ឋកម្ពុជាមួយរូប បានថ្លែងថា ជាទូទៅតាមការសង្កេតផ្ទាល់ខ្លួនរបស់លោក និង ព្រមទាំងជាបទពិសោធន៍ផ្ទាល់ខ្លួន មួយឆ្នាំពលរដ្ឋកម្ពុជាក៏ដូចជាគ្រួសាររបស់លោក គឺដើរលេងច្រើននៅក្នុងអំឡុង ពេលសម្រាកធំៗទាំងនេះ ដោយរួមទាំងបុណ្យចូលឆ្នាំចិន បើទោះបីជាមិនមែនជាថ្ងៃសម្រាកសាធារណៈពិតប្រាកដក៏ដោយ ។

លោកបានថ្លែងបញ្ជាក់ថា "ខ្ញុំជឿថា នរណាៗក៏ដើរលេងកំសាន្តដែរនៅអំឡុងពេលឈប់សម្រាកបុណ្យទាំងនេះ គ្រាន់តែទៅជិតទៅឆ្ងាយ ឬទៅបរទេស ជាពិសេសអ្នកនៅភ្នំពេញ"។

លោកស្រី ទេព សុទេពី ជាស្ត្រីមេផ្ទះវ័យ ៥៥ ឆ្នាំ មួយរូប បានថ្លែងថា ខ្មែរយើងឈប់ច្រើនមែន តែវាររប៉េះរប៉ោះ គឺមួយថ្ងៃៗដើរលេង ឬទៅណាមកណាវាមិនឆ្អែត មានតែឱកាសបុណ្យធំៗទាំងនេះទេទើបមានឱកាសច្រើនថ្ងៃ ជួបជុំគ្នាដើរលេងសប្បាយទាំងអស់គ្នា។

យោងតាមរបាយការណ៍របស់ក្រសួងទេសចរណ៍ នៅក្នុងឆ្នាំ២០១៦ កន្លងទៅ ពលរដ្ឋកម្ពុជាដែលមានធនធាន និងដើរលេងនៅក្រៅប្រទេសមានចំនួនប្រមាណជា១,៤ លាននាក់ ដោយចំណាយសរុបរហូតដល់ទៅ៦០០ លានដុល្លារ នៅក្នុងមួយឆ្នាំ ដោយគោលដៅនៃដំណើរទេសចរណ៍គឺទៅចិន អាស៊ាន ដូចជា ម៉ាឡេស៊ី សិង្ហបុរី ថៃ និងវៀតណាម ចិន ដែលរួមមាន ចិនហុងកុង ចិនដីគោក ម៉ាកាវ ជាដើម។ សម្រាប់ភ្ញៀវទេសចរដែលដើរលេងនៅក្នុងប្រទេស គឺមានប្រមាណជា ១០ លាននាក់ នៅតាមរមណីដ្ឋាននានា។

# ចំណាយមិនតិចដែរ !



ថតដោយ លីហៀង

"ខ្ញុំចេះតែចង់សន្សំសំចៃដើម្បីបានសល់លុយកាក់ខ្លះហើយ ប៉ុន្តែលោកប្តីខ្ញុំចេះតែថា ណ្ហើយបុណ្យទានម្តងម្កាលកុំរិះកុំថាំពេក ទិញនេះទិញនោះ ជួបជុំបងប្អូនទៅពេលមកផ្ទះម្តងម្កាល"។

លោកស្រីចាន់ណា បានបន្តថា ការចំណាយរឿងផឹកស៊ីនោះ គឺក្រែលដែរតើ បើម្តងអស់ប្អូនទៅ ប្រាំកេសអីណោះ នេះបានបងប្អូនគាត់ចេញមាន់ ចេញទា ចេញត្រីនោះទេ កុំអីតែតែច្រើនជាងនេះ ទៅទៀត។

សម្រាប់បងប្អូនប្រជាពលរដ្ឋកម្ពុជាដែលមានផ្ទះនៅស្រុកស្រែចំការ ការចំណាយលើការជួបជុំគ្នាហូបចុក គឺជារឿងធម្មតាដែលគាត់តែងតែធ្វើជាទម្លាប់។ ការចំណាយនេះគឺច្រើន សម្រាប់ពួកគាត់ដែលមាន ប្រាក់ចំណូលតិច ប៉ុន្តែ ទោះបីជាយ៉ាងណាក៏ដោយ នៅក្នុងពេលបច្ចុប្បន្ននេះ មានប្រជាពលរដ្ឋដែលគ្រោងចំណាយច្រើនជាងនេះរាប់សិបដង គឺមាន ដោយពួកគេគ្រោងចំណាយ ទៅដើរលេងនៅបរទេសដូចជា ទៅវៀតណាម ថៃ សិង្ហបុរី ម៉ាឡេស៊ី ហុងកុង ចិន ម៉ាកាវ អឺរ៉ុប អូស្ត្រាលី កូរ៉េ ជប៉ុន ក៏មាន ដោយការចំណាយគឺទៅតាមគោលដៅទៅតាមមធ្យោបាយនៃការធ្វើដំណើរ ប៉ុន្តែបើចេញទៅជាលក្ខណៈគ្រួសារ គឺថាមួយគ្រួសារមិនក្រោមខ្ទង់ពាន់ដុល្លារឡើយ។

ដ៏រីញចំណុចនេះ នាសិក្ខាសាលាពិគ្រោះយោបល់រវាងអ្នកផលិត និងអ្នកផ្គត់ផ្គង់ផលិតផលខ្មែរ ជាមួយនឹងអ្នកប្រើប្រាស់ និងអ្នកចែកចាយបន្ត ដែលរៀបចំដោយក្រសួងបួនគឺមាន ក្រសួងពាណិជ្ជកម្ម ក្រសួងឧស្សាហកម្ម និងសិប្បកម្ម ក្រសួងទេសចរណ៍ និងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដែលរៀបចំកាលពីពេលថ្មីៗនេះ លោកទិត ចន្ថា រដ្ឋលេខាធិការក្រសួងទេសចរណ៍ បានជំរុញឲ្យពលរដ្ឋកម្ពុជាធ្វើដំណើរទេសចរណ៍នៅក្នុងប្រទេស និងប្រើប្រាស់ផលិតផលនៅក្នុងស្រុក ដោយសារតែវានឹងជួយរួមចំណែកដល់សេដ្ឋកិច្ចនៅក្នុងស្រុក។

លោក បានថ្លែងថា ការរួមចំណែកនៃវិស័យទេសចរណ៍ ក្នុងការរក្សាលំនឹងជញ្ជីងពាណិជ្ជកម្ម ចាប់ពី ២០% ដល់ ២៥% តាមរយៈការជំរុញនាំចេញនៅនឹងកន្លែង។

លោកបញ្ជាក់ថា "នៅក្នុងឆ្នាំ២០១៦ កម្ពុជាបានទទួលភ្ញៀវទេសចរបរទេស ៥ លាននាក់ និងទេសចរក្នុងស្រុក ១០លាននាក់។ វត្តមាននៃភ្ញៀវទេសចរទាំងនេះ មិនត្រឹមតែប្រើប្រាស់ផលិតផល និងសេវាកម្មខ្មែរប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងបានស្រូបយកកម្លាំងពលកម្មប្រមាណ ៦២ម៉ឺននាក់"។

ទាក់ទិននឹងចំណុចនេះ លោក ខេង ពិសិដ្ឋ ប្រជាពលរដ្ឋមួយរូប ដែលកំពុងតែគ្រោងនឹងចំណាយលើដំណើរទេសចរណ៍ទៅក្រៅប្រទេស បានថ្លែងថា ជាការពិតតាមក្បួនសេដ្ឋកិច្ច កាលណាយើងទៅចាយលុយកន្លែងណា គឺកន្លែងនោះនឹង ទទួលអត្ថប្រយោជន៍ផ្នែកសេដ្ឋកិច្ចហើយ ប៉ុន្តែមនុស្សត្រូវការប្លែកត្រូវការអ្វីដែលថ្មីដូច្នេះការធ្វើដំណើរទេសចរណ៍ក្រៅប្រទេសអាចជាការដកស្រង់បទពិសោធន៍ អាចជាឱកាសប្រៀបធៀបគ្នារវាងគុណភាពសេវាកម្មនៅក្នុងស្រុកយើង និងសេវាកម្មនៅស្រុកគេ។

លោកបានបញ្ជាក់ថា "ខ្ញុំនោះវាឆ្អែតហើយរឿងដើរក្រៅប្រទេស ប៉ុន្តែកូនប្រពន្ធឪពុកម្តាយ ដែលពួកគាត់មិនដែល នេះគឺជាឱកាសមួយ ដើម្បីកុំឲ្យពួកគេចេះតែគិតដូចជា ករណីរឿងនិទានកង្កែបនៅតែក្នុងអណ្តូងទឹក"។

ដោយ អរិយបុត្រ

## រមណីដ្ឋាននៅកម្ពុជាជាង១ ពាន់កន្លែងកំពុងតែរង់ចាំបងប្អូនទៅលេងកំសាន្ត

ប្រជាពលរដ្ឋកម្ពុជាសូមកុំភ្លេចណា កម្ពុជាមានរមណីដ្ឋានសម្រាប់ដំណើរកម្សាន្តប្រមាណជា ជាងមួយពាន់កន្លែងកំពុងតែរង់ចាំអស់លោក-លោកស្រី នារដូវសម្រាកភ្ជុំបិណ្ឌប្រពៃណីជាតិនៅពេលខាងមុខនេះ និងពេលសម្រាកនាចុងសប្តាហ៍ ឬពេលដែលអស់លោក-លោកស្រីទំនេរពីការងារ ឬអាជីវកម្មផ្សេងៗ ។

យោងតាមរបាយការណ៍មួយរបស់ក្រសួងទេសចរណ៍ បានឲ្យដឹងថា កម្ពុជាមានកន្លែងដែលជារមណីដ្ឋានទាក់ទាញដំណើរកំសាន្តប្រមាណជា ១.៤២៩ កន្លែង នៅក្នុងនោះ គឺមាន ៣៣៥ កន្លែងដែលមានអាជ្ញាប័ណ្ណ និងចុះបញ្ជីត្រឹមត្រូវ។

ប្រភពដដែលបានបន្តថា កម្ពុជាមានសណ្ឋាគារ ប្រមាណជា ៦៤៧ កន្លែង គិតជាបន្ទប់សរុប ៣៦.២៣៦ បន្ទប់ ផ្ទះសំណាក់ចំនួន ១.៩៩៦ កន្លែង ស្មើនឹង ២៨.៨៨៥ បន្ទប់ មជ្ឈមណ្ឌលកំសាន្តសម្រាប់មនុស្សធំ ប្រមាណជា ៦៨៨កន្លែង ភោជនីយដ្ឋានចំនួន ប្រមាណជា ១.៨៨៤ កន្លែង។ ក្រៅពីនេះកម្ពុជានៅមានក្រុមហ៊ុនទេសចរប្រមាណជា ៥៨៨ ក្រុមហ៊ុន កន្លែងរមណីដ្ឋានបែបជា ទេសចរណ៍កីឡា គឺមាន ៣២ កន្លែង និងមគ្គុទេសទេសចរណ៍ចំនួនប្រមាណជា ៥.០៨៨ នាក់។

# ព្រះវិហារសន្តសិលា និងសន្តប៉ូលទទួល បងប្អូន១៩នាក់ឲ្យចូលក្នុងព្រះសហគមន៍កាតូលិក

ព្រះវិហារ សន្តសិលា និងសន្តប៉ូល នៃព្រះសហគមន៍កាតូលិកភ្នំពេញថ្មី បានរៀបចំពិធីទទួលបងប្អូនចំនួន ១៩នាក់ឲ្យចូលក្នុងព្រះសហគមន៍កាតូលិក ដើម្បីទទួលអប់រំជំនឿ ត្រៀមខ្លួនទទួលអគ្គសញ្ញាជ្រមុជទឹកក្លាយជាគ្រីស្តបរិស័ទ និងទទួលជីវិតថ្មីរួមជាមួយព្រះយេស៊ូ។

ពិធីនេះបានប្រារព្ធឡើងកាលពីថ្ងៃទី០៦ ខែសីហាកន្លងទៅ នៅព្រះវិហារសន្តសិលា និងសន្តប៉ូល ភ្នំពេញថ្មី ដែលមានលោក សិលា សួន ហង្សលី ជាបូជាចារ្យទទួលខុសត្រូវព្រះវិហារនេះជាអធិបតី និងមានគ្រីស្តបរិស័ទចូលរួមយ៉ាងច្រើនកុះករ។

កិច្ចស្វាគមន៍បងប្អូនធ្វើនៅខាងក្រៅព្រះវិហារ តាមការទទួច និងគោះទ្វារសុំចូលរបស់បងប្អូន ដោយមានគ្រូអប់រំជំនឿអមដំណើរផង។ ព្រះសហគមន៍អញ្ជើញបងប្អូនចូលខាងក្នុងព្រះវិហារ បន្ទាប់ពីបានស្តាប់ពាក្យសុំចូលព្រះសហគមន៍កាតូលិករបស់បងប្អូនជាមនុស្សពេញវ័យ ដែលពួកគេចង់ក្លាយជាគ្រីស្តបរិស័ទ។

នៅខាងក្នុងព្រះវិហារ បងប្អូនជាបេក្ខជនទាំងអស់ត្រូវបានសួរម្តងទៀតដោយលោកបូជាចារ្យអធិបតី។ ក្រោយមកបេក្ខជនបេក្ខនារី បានប្រកាសពាក្យ "ខ្ញុំសូមយកព្រះគ្រីស្តជាទីពឹង!" នៅជុំវិញព្រះឈើឆ្កាង។ "ខ្ញុំសូមយកព្រះបន្ទូលជាទីពឹង !" នៅចំពោះមុខព្រះគម្ពីរ។ "ខ្ញុំសូមយកព្រះសហគមន៍ជាទីពឹង!" ចំពោះមុខព្រះសហគមន៍ទាំងមូល។

ក្នុងធម្មទេសនាលោកបូជាចារ្យ សិលា សួន ហង្សលី បានសម្តែងក្តីកោតក្នុងនាមព្រះសហគមន៍ទទួលបងប្អូនដែលបានសម្រេចចិត្តដើរតាមព្រះយេស៊ូ។ លោកថាដើរជាមួយព្រះយេស៊ូជាឯកសិទ្ធិរបស់បងប្អូន ដែលទទួលពិធីនៅថ្ងៃនេះ។ ដើរតាមព្រះយេស៊ូ គឺនឹងមានការលំបាកជាច្រើននៅក្នុងជីវិត។ ប៉ុន្តែដោយសារព្រះយេស៊ូគង់នៅជាមួយ យើងបានធូរស្បើយក្នុងចិត្ត។ យើងពុះពារដើរតាមព្រះយេស៊ូ ជំនះឧបសគ្គនានា ដូចក្នុងគម្ពីរសារកែឡើងភ្នំជាមួយព្រះអង្គដើម្បីជួបព្រះបិតា។

លោកបូជាចារ្យបន្តថា ពេលដើរតាមព្រះយេស៊ូ ត្រូវស្តាប់ព្រះអង្គ។ ពេលអធិដ្ឋាន យើងនិយាយទៅកាន់ព្រះអង្គ ប៉ុន្តែយើងក៏ស្តាប់ព្រះបន្ទូលរបស់ព្រះ។ ពេលណាយើងស្តាប់ ទុកឲ្យព្រះបន្ទូលធ្វើការក្នុងយើង ឲ្យព្រះបន្ទូលចូលក្នុងដួងចិត្តម្នាក់ៗ ដើម្បីយើងអាចរស់នៅតាមព្រះបន្ទូល បន្តិចម្តងៗបានទៅដល់គោលដៅ ជួបព្រះជាម្ចាស់។

បងប្អូនទាំង១៩នាក់ គឺបានឈ្វេងយល់អំពីជំនឿលើព្រះយេស៊ូហើយដែរ។ ការទទួលចូលក្នុងព្រះសហគមន៍ឬជំហានទី១ ត្រៀមខ្លួនទទួលអគ្គសញ្ញាជ្រមុជទឹក។

ព្រះវិហារសន្តសិលា និងសន្តប៉ូល នៃព្រះសហគមន៍កាតូលិកភ្នំពេញថ្មី ជាព្រះសហគមន៍ថ្មីមួយក្នុងភូមិភាគភ្នំពេញ មានបងប្អូនកំពុងទទួលអប់រំជំនឿមកពីគ្រប់ទិសទី។

ដោយ លី សុវណ្ណា



ថតដោយ អេន ហំ



# លោក សួន ហង្សលី បំពេញពាក្យសន្យាជាមួយព្រះជាម្ចាស់



លោក សួន ហង្សលី ថតដោយ សម្បត្តិ

អស់រយៈកាល១៦ឆ្នាំ លោកសួន ហង្សលី បានទទួលអគ្គសញ្ញាតែងតាំងជាបូជាចារ្យកាតូលិក ហើយបានបម្រើការងារនៅក្នុងភូមិភាគភ្នំពេញ។ ចាប់ពីខែកក្កដា លោកសិលាសួនហង្សលី ត្រូវបានលោកអភិបាលព្រះសហគមន៍កាតូលិកភូមិភាគភ្នំពេញជ្រើសតាំងជាតំណាងពេញសិទ្ធិ។

លោកសួន ហង្សលី កើតក្នុងគ្រួសារគ្រីស្តបរិស័ទ ជាកូនពៅក្នុងចំណោមបងប្អូនប្រុសស្រី៤នាក់ និងបានទទួលអគ្គសញ្ញាជ្រមុជទឹកតាំងពីកុមារ។ ប៉ុន្តែលោកនិយាយថា លោកមិនស្គាល់ថា គ្រីស្តសាសនាជាអ្វីទេ ហើយចំណេះទៀតសោត ក៏មិនសូវជ្រៅជ្រះដែរ ព្រោះលោកបានឆ្លងកាត់ក្នុងសម័យសង្គ្រាម ជាពិសេសរបបប្រល័យពូជសាសន៍ប៉ុលពត។

ពេលរបបខ្មៅងងឹតដួលរលំ គ្រួសាររបស់លោកបានត្រឡប់មកកាន់ស្រុកកំណើតវិញនៅភូមិមាត់ក្រសាស់ ស្រុកល្វាឯម ខេត្តកណ្តាល។ ទោះជាយ៉ាងណាសេរីភាពនៃការគោរពបម្រើសាសនានៅតែត្បិតតែក៏អាចមានការជួបជុំគ្នាជាមួយគ្រីស្តបរិស័ទជាតិវៀតណាម ដែរ។

ក្នុងឆ្នាំ១៩៨៩ ម្តាយ ឪពុក និងម្តាយមីងតែងតែជំរុញឲ្យលោកទៅព្រះវិហារ តែលោកបដិសេធដោយលើកហេតុផលថា "នៅក្នុងស្រុកខ្មែរគឺគ្មានសាសនាណាដែលល្អជាងសាសនាព្រះពុទ្ធនោះទេ"។ ប៉ុន្តែដោយសារប្រកែកមិនឈ្នះ លោកសម្រេចចិត្តទៅព្រះវិហារលើកដំបូង ដើម្បីសាកល្បង។

លោកសួន ហង្សលីនៅពេលនោះ បានចាប់ចិត្តជាមួយព្រះបន្ទូលមួយឃ្លាដែលថា "មនុស្សមិនអាចសង្គ្រោះ(ខ្លួន)បានទេ ហើយការសង្គ្រោះគឺមកពីព្រះជាម្ចាស់"។ បន្ទាប់ពីការរិះគិត លោកបានសម្រេចចិត្តកែប្រែចិត្តគំនិត ទទួលយកជំនឿជាគ្រីស្តបរិស័ទ។

ក្រោយពេលលោកពេញវ័យ ម្តាយមីងរបស់លោក លើកសំណួរជារឿយៗថា "តើក្មួយចង់ធ្វើជាលោកសង្ឃរាជទេ?"។ ពាក្យសង្ឃរាជនេះសំដៅលើបូជាចារ្យកាតូលិកដែលកំពុងប្រើនាពេលបច្ចុប្បន្ន។ តែពេលនោះ លោកមិនយល់អត្ថន័យនៃជីវិតជាសង្ឃរាជ ឬជាបូជាចារ្យទេ។

គ្រាមួយនៅបុណ្យណូអែល លោកត្រូវរដ្ឋអំណាចចាប់ឃុំខ្លួន តែសំណាងល្អលោកត្រូវបានបងប្រុសរំដោះរួចមកវិញ ហើយបានភៀសខ្លួនទៅជំរំសាយធូប្រទេសថៃ។

នៅក្នុងជំរុំជនភៀសខ្លួន លោកគិតថា "ខ្ញុំអាចរួចផុតពីសំណួររបស់ម្តាយមីងដែលមានបំណងចង់ឲ្យធ្វើជាបូជាចារ្យ ម្យ៉ាងទៀតខ្ញុំអាចបន្តការសិក្សាខ្លះៗដើម្បីប្រកបរបរចិញ្ចឹមជីវិតបាន"។ ប៉ុន្តែសំណួរដដែលបានផុសចេញម្តងទៀតពីមាត់លោកបូជាចារ្យប៉ែកណា ឌុយប្រាវិញម្តង "តើលីចង់ធ្វើជាបូជាចារ្យមែនទេ?"។ តាមរយៈសំណួរនេះធ្វើឲ្យលោកគិតម្តងទៀត ហើយនឹកឃើញអំពីពាក្យសន្យារបស់លោកចំពោះព្រះជាម្ចាស់ក្នុងអំឡុងពេលរត់ភៀសខ្លួនមកជំរំ។ លោកបានពោលថា "ប្រសិនបើខ្ញុំចាកចេញទៅដោយមានសេចក្តីសុខនោះ ខ្ញុំនឹងចូលរួមបម្រើក្នុងព្រះវិហារ"។

នៅខែកញ្ញា ឆ្នាំ១៩៩១ លោកសួន ហង្សលី បានសម្រេចចិត្តសាកល្បងឈ្វេងយល់ជីវិតជាអ្នកបួស ដោយរស់នៅជាមួយយុវជនពីរនាក់ផ្សេងទៀត ដើម្បីរិះគិតពីការត្រាស់ហៅក្នុងជីវិតជាបូជាចារ្យកាតូលិក។

ក្រោយមកកម្ពុជាទទួលបានសន្តិភាព ព្រះសហគមន៍ក៏មានសិទ្ធិអាចបង្កើតកម្មវិធីរបស់ខ្លួនឡើងវិញ ហើយទេវវិទ្យាល័យក៏ត្រូវបានរៀបចំឡើង។ លោកនិងយុវជនខ្មែរមួយចំនួនបានធ្វើមាតុភូមិនិវត្តន៍មកប្រទេសកម្ពុជាវិញ ហើយ ចូលរៀនបួសនៅក្នុងទេវវិទ្យាល័យនៅបាត់ដំបង។

ក្នុងឆ្នាំ២០០១ លោកសួន ហង្សលី បានទទួលអគ្គសញ្ញាតែងតាំងជាបូជាចារ្យកាតូលិករួមជាមួយយុវជនខ្មែរចំនួន ៣ នាក់ទៀត។ ក្រោយពីការតែងតាំង លោកបូជាចារ្យហង្សលីត្រូវបានលោកអភិបាលភូមិភាគភ្នំពេញគឺលោក អេមីល ដេតម្បូ ចាត់អោយទៅបម្រើនៅព្រះសហគមន៍ក្នុងខេត្តកំពត និងខេត្តតាកែវរួមជាមួយលោកអូលីវីយេ ជ្មិតអ៊ីស្លែរ។

លោកបម្រើនៅទីនោះអស់រយៈពេលប្រាំឆ្នាំ។ ក្រោយមកលោកអភិបាលបានចាត់លោកឲ្យសិក្សាបន្តផ្នែកផ្លូវវិញ្ញាណ និងទេវវិទ្យារយៈពេលប្រាំបីឆ្នាំនៅប្រទេសបារាំង។

បច្ចុប្បន្នលោកបូជាចារ្យសួន ហង្សលី មានវ័យ៤៦ឆ្នាំ។ លោកទទួលបន្ទុកមើលការខុសត្រូវព្រះសគមន៍កាតូលិកមណ្ឌលកម្មភាពភ្នំពេញថ្មី និងជាតំណាងពេញសិទ្ធិ លោកអភិបាល ភូមិភាគភ្នំពេញ អូលីវីយេ ជ្មិតអ៊ីស្លែរ។

# បូជាចារ្យ នៃក្រុមបព្វជិតសហជីវិនព្រះយេស៊ូ ពីរអង្គ ថ្វាយពាក្យសច្ចានិរន្តន៍

លោកបូជាចារ្យកាតូលិកពីរអង្គ នៃក្រុមបព្វជិតសហជីវិនព្រះយេស៊ូ ដែលកំពុងបម្រើការងារ ព្រះសហគមន៍កាតូលិកនៅក្នុងភូមិភាគបាត់ដំបង បានថ្វាយពាក្យសច្ចានិរន្តន៍ កាលពីថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០១៧ ដែលជាថ្ងៃបុណ្យគោរពសន្តអ៊ីញ៉ាស់ អ្នកបង្កើតក្រុមបព្វជិតកាតូលិកដ៏ធំមួយនេះ។ ពិធីបុណ្យបានប្រព្រឹត្តទៅនៅព្រះវិហារព្រះជាម្ចាស់លើកព្រះនាងម៉ារីឡើងស្ថានបរមសុខនៃព្រះសហគមន៍កាតូលិកក្រុងបាត់ដំបង។


ថតដោយ រិទ្ធិរដ្ឋ

បព្វជិតពីររូបដែលថ្វាយពាក្យសច្ចានិរន្តន៍នៅពេលនោះគឺ លោកបូជាចារ្យ ស្ទេផានុស ជាបូជាចារ្យទទួលខុសត្រូវព្រះសហគមន៍កាតូលិកក្រុងបាត់ដំបង និងលោកបូជាចារ្យ ម៉ានុច កុមារឯកា ជាបូជាចរ្យទទួលខុសត្រូវព្រះវិហារសន្តអន់ដ្រេនៃព្រះសហគមន៍កាតូលិក ភូមិនិគម ខេត្តបាត់ដំបង ។

ពិធីបុណ្យចាប់ផ្តើម ដោយរបាំបាចផ្កាជូនពរលោកទាំងពីរ។ បន្ទាប់មកមានក្បួនដង្ហែ លោកទាំងពីរយ៉ាងអធឹកអធមចេញផ្ទះលោកអភិបាល គីគេ ឆ្ពោះទៅកាន់ព្រះវិហារព្រះជាម្ចាស់លើកព្រះនាងម៉ារីឡើងស្ថានបរមសុខ មានចំងាយជាង ២០០ ម៉ែត្រ ដោយមានក្រុមភ្លេងឆៃយ៉ាំនាំមុខក្បួន និងមានទុងនានាមានសញ្ញាឈើឆ្កាង ទានជ័យព្រះគម្ពីរជាដើម។

ក្នុងពិធីនេះមានការអញ្ជើញចូលរួមពីសំណាក់លោកអភិបាល គីគេ ហ្វីការេដ្ជូ លោក អូ អ៊ុនដុន ប្រធានក្រុមបព្វជិតសហ-ជីវិនព្រះយេស៊ូ នៅកម្ពុជាព្រមទាំងលោកបូជាចារ្យ ចំនួន២១អង្គ បងប្រុស បងស្រី និងបងប្អូនគ្រីស្តបរិស័ទ ដែលមកពីព្រះសហគមន៍ផ្សេងៗគ្នា ដូចជាព្រះសហ-គមន៍សន្តយ៉ូហាន ក្រុងសៀមរាប ព្រះសហគមន៍សន្តអន់ដ្រេ ភូមិនិគម ព្រះសហគមន៍សន្តយ៉ូសែប ភូមិតាហែន និងព្រះសហគមន៍ផ្សេងៗទៀត ក្នុងភូមិភាគបាត់ដំបងយ៉ាងច្រើនកុះករ។

លោកបូជាចារ្យ ស្ទេផានុស បានមានប្រសាសន៍ក្នុងធម្មទេសនាថា "អ្វីដែលខ្ញុំចាប់អារម្មណ៍នោះគឺជីវិត"។ ដោយលោកពន្យល់បញ្ជាក់ថា "ប្រសិនបើយើងចង់ក្លាយជាសាវ័កព្រះយេស៊ូ យើងត្រូវការលះបង់ជីវិត ដើម្បីយើងបានជីវិតវិញ។ បន្ទាប់មកលោកបូជាចារ្យស្ទេផានុស បានរៀបរាប់ពីកុមារភាព រហូតដល់ក្លាយជាបូជាចារ្យ។ ព្រោះការអធិដ្ឋានរបស់លោកផ្ទាល់ និងពាក្យអធិដ្ឋានរបស់ម្តាយឪពុករបស់លោក ទើបលោកមានកម្លាំងបន្តឆ្លើយតបចំពោះព្រះជាម្ចាស់ក្នុងជីវិតជាបូជាចារ្យ ។

បន្ទាប់ពីធម្មទេសនារួចបព្វជិតទាំងពីរ គឺលោកស្ទេផានុស និងលោកម៉ានុច កុមារឯកា បានធ្វើពិធីថ្វាយពាក្យសច្ចានិរន្តន៍ នៅចំពោះមុខព្រះកាយព្រះលោហិតព្រះគ្រីស្តចំពោះប្រធានក្រុមបព្វជិតផ្ទាល់ និងនៅចំពោះមុខព្រះសហគមន៍ទាំងមូល។

ក្នុងពិធីដ៏អធឹកអធមនេះដែរ លោកបូជាចារ្យ ម៉ានុច កុមារឯកា បូជាចារ្យទទួលខុសត្រូវព្រះសហគមន៍ សន្ត អន់ ដ្រេ ភូមិនិគម ជាបព្វជិតមួយរូបបានថ្វាយពាក្យសច្ចានិរន្តន៍ បានរៀបរាប់ពីជីវិតរស់នៅជាអ្នកបួសអស់រយៈពេល ២៧ឆ្នាំ ជីវិតជាបូជាចារ្យរយៈពេល១៤ឆ្នាំ។ លោកបន្តថា លោកពិតជាមានអំណរសប្បាយជាខ្លាំង ដែលលោកបានថ្វាយពាក្យសច្ចា នៅក្នុងក្រុមគ្រួសារបព្វជិតកាតូលិក សហជីវិនព្រះយេស៊ូ ដោយយកសន្តអ៊ីញ៉ាស់ ដែលជាអ្នកបង្កើតក្រុមនេះជាគំរូ។

លោកបូជាចារ្យ ម៉ានុច កុមារឯកា មានដើមកំណើតនៅប្រទេសឥណ្ឌា លោកបានទទួលអគ្គសញ្ញាតែងតាំងជាបូជាចារ្យក្នុងឆ្នាំ ២០០៤។ លោកមកដល់ប្រទេសកម្ពុជា ក្នុងឆ្នាំ២០០៥។ ចំណែកលោកបូជាចារ្យ ស្ទេផានុស មានដើមកំណើតនៅប្រទេសឥណ្ឌូណេស៊ី លោកទទួល អគ្គសញ្ញាតែងតាំងជាបូជាចារ្យក្នុងឆ្នាំ២០០៥ ហើយលោកមកដល់ប្រទេសកម្ពុជា ក្នុងឆ្នាំ ២០០៩។ *ដោយ ឃៀប អេងវិជ្ជណា*

# បុណ្យព្រះជាម្ចាស់លើកព្រះនាងម៉ារីឡើងស្ថានបរមសុខ

កាលពីថ្ងៃទី១៣ ខែសីហា ឆ្នាំ២០១៧ នៅព្រះសហគមន៍កាតូលិកបាត់ដំបង បានប្រារព្ធពិធីបុណ្យ ព្រះជាម្ចាស់លើកព្រះនាងម៉ារីឡើងស្ថានបរមសុខ ដែលជាបុណ្យយ៉ាងឱឡារិកនៃព្រះសហគមន៍ កាតូលិកបាត់ដំបង ដោយមានក្បួនដង្ហែចេញពីគេហដ្ឋាន អ្នកស្រី ជឹម ប៉ូរ៉ា ដោយមានក្រុមឆៃយ៉ាំ នាំមុខធ្វើដំណើរជុំវិញភូមិ ឆ្ពោះទៅកាន់ព្រះវិហារ ដើម្បីថ្វាយអភិបូជា។

នៅក្នុងពីធីបុណ្យនោះមានការចូលរួមពីសំណាក់ លោកអភិបាល គីគេ ព្រមទាំងលោកបូជាចារ្យ ៤អង្គទៀតផង ហើយក្នុងនោះដែរក៏មានវត្តមានគ្រីស្តបរិស័ទ ជាច្រើនកុះករ។

ក្នុងឱកាសនោះ លោកបូជាចារ្យ ស្ទេផានុស បានសម្តែងធម្មទេសនាយ៉ាងពីរោះ ដោយលោកបានមានប្រសាសន៍ថា "អ្វីដែលខ្ញុំចាប់អារម្មណ៍នៅក្នុងព្រះគម្ពីរថ្ងៃនេះគឺ ព្រះនាងម៉ារីទុកនូវអ្វីដែលគាត់បានទទួលនេះ ថ្វាយឡើងទៅព្រះជាម្ចាស់" បន្ទាប់មកលោកបូជាចារ្យបន្តថា ពេលនោះនាងម៉ារីបានថ្លែងថា "ព្រលឹងខ្ញុំសូមលើកតម្កើងព្រះជាម្ចាស់ ព្រះដ៏មានឫទ្ធានុភាពដែលបានសម្តែងការអស្ចារ្យចំពោះរូបខ្ញុំ"។

លោកបូជាចារ្យ ស្ទេផានុស បន្តទៀតថា "យើងអាចរៀនពីព្រះនាងម៉ារីដោយយកព្រះនាងជាគំរូ" ដោយចេះបន្ទាបខ្លួន ចេះលះបង់ ចេះជួយអ្នកដទៃ និងចេះស្រលាញ់អ្នកដទៃ ដោយចិត្តសុភាពរាបសា ដើម្បីលើកតម្កើងព្រះជាម្ចាស់។

ជាចុងក្រោយនៃពិធីបុណ្យនេះ គ្រីស្ត-បរិស័ទទាំងអស់បានឡើងទទួលព្រះពរពីលោកអភិបាល គីគេ ដែលជាព្រះពរក្នុងបុណ្យ ព្រះជាម្ចាស់លើកព្រះនាងម៉ារីឡើងស្ថានបរមសុខ។ *ដោយ ឃៀប អេងវិជ្ជណា*


ថតដោយ រិទ្ធិរដ្ឋ

# ការសម្តែងធម៌មេត្តាករុណាជាកូនសោរដើម្បីប្រកាសដំណឹងល្អ

ព្រះវិហារសន្តសិលា និងសន្តប៉ូលនៃមណ្ឌលសកម្មភាពភ្នំពេញថ្មី បានរួមសហការជាមួយសហគមន៍ដែលជាអង្គការក្រៅរដ្ឋាភិបាលមានអង្គការ SOS Cambodian and Kids បានរៀបចំការកម្មវិធីសប្បុរសធម៌ ដោយមានទទួលពិនិត្យ និងព្យាបាលជំងឺជូនប្រជាពលរដ្ឋ ដោយឥតគិតថ្លៃ ចំនួនជាងមួយពាន់នាក់។ កម្មវិធីនេះធ្វើឡើងចំនួនពីរថ្ងៃ គឺពីថ្ងៃទី១២ ដល់ថ្ងៃទី១៣ សីហា ២០១៦ នៅព្រះវិហារសន្តសិលា និងសន្តប៉ូល នៃមណ្ឌលសកម្មភាពព្រះសហគមន៍កាតូលិកភ្នំពេញថ្មី។


ថតដោយ សុធីរិទ្ធ

តាមប្រសាសន៍របស់លោកសួន ហង្សលី ជាតំណាងពេញសិទ្ធិនៃលោកអភិបាលភូមិភាគភ្នំពេញ និងជាបូជាចារ្យទទួលខុសត្រូវមណ្ឌលសកម្មភាពភ្នំពេញថ្មី បានឲ្យដឹងថា "ខ្ញុំពេញចិត្តនិងសប្បាយចិត្តព្រោះថាកម្មវិធីនេះបានជួយដល់បងប្អូនជាច្រើនដែលកំពុងតែមានបញ្ហាខាងសុខភាព និងគ្មានថវិកាគ្រប់គ្រាន់ក្នុងការព្យាបាល"។ លោកបញ្ជាក់ទៀតថា សម្រាប់យើងដែលជាគ្រីស្តបរិស័ទ និងជាព្រះសហគមន៍កាតូលិក អ្វីដែលសំខាន់ គឺការប្រកាសដំណឹងល្អតាមរយៈការសម្តែងធម៌មេត្តាករុណា។ កម្មវិធីក៏ជាឱកាសមួយដើម្បីឲ្យបងប្អូនប្រជាពលរដ្ឋនៅជុំវិញនេះបានចូលរួម និងស្គាល់ព្រះសហគមន៍ផងដែរ។

រីឯលោកវេជ្ជបណ្ឌិត ឡោ គឹមសុង (Dr. LOR Kim Song) ប្រធានក្រុមគ្រូពេទ្យស្ម័គ្រចិត្តបានមានប្រសាសន៍ថា "ក្នុងរយៈពេលជិតដប់ឆ្នាំដែល SOS Cambodian and Kids បានបំពេញបេសកកម្មជួយពិនិត្យ និងព្យាបាលជំងឺ ដោយឥតគិតថ្លៃ ខ្ញុំឃើញថានៅទីនេះជាលើកជាកន្លែងដែលល្អជាងគេ ព្រោះថាព្រះសហគមន៍ដែលខ្ញុំបានស្គាល់តាមរយៈលោកបូជាចារ្យលី បានខិតខំអស់ពីសមត្ថភាពក្នុងការទទួលស្វាគមន៍អ្នកជំងឺ ហើយមានទីធ្លាធំទូលាយ មានដំបូល និងកៅអីគ្រប់គ្រាន់ដែលអាចឲ្យអ្នកជំងឺរង់ចាំមានភាពងាយស្រួល មិនខ្លាចក្តៅ មិនខ្លាចភ្លៀង ។" លោកបន្តថា កាលពីមុនក្រុមយើងធ្លាប់បានទៅធ្វើសកម្មភាពនៅកន្លែងផ្សេងៗ គឺមិនដែលបានកន្លែងល្អដូចនៅក្នុងព្រះសហគមន៍នេះឡើយព្រោះពេលខ្លះត្រូវធ្វើការនៅក្រោមដើមឈើក៏មាន។

លោកវេជ្ជបណ្ឌិតគឹមសុង បានឲ្យដឹងទៀតថា កម្មវិធីនេះប្រព្រឹត្តទៅបានក៏ព្រោះតែមានការសហការជាមួយអង្គការAH-NEP អង្គការ SIYOAN BMA អង្គការ FERK និងព្រះសហគមន៍កាតូលិកភូមិភាគភ្នំពេញ។ ឆ្លៀតក្នុងឱកាសនោះលោកក៏បានថ្លែងអំណរគុណដល់ដៃគូសហការទាំងអស់ដែលមកពីប្រទេសអាឡឺម៉ង់ បារាំង អូស្ត្រាលី និងអាមេរិក ហើយសូមកោតសរសើរដល់ក្រុមនិស្សិតផ្នែកវេជ្ជសាស្ត្រ ដែលបានស្ម័គ្រចិត្តមកជួយដោយសន្សំទាំងថវិកាក្នុងការចំណាយទៅលើសំបុត្រយន្តហោះ និងចំណាយផ្សេងៗទៀតដោយខ្លួនឯង។

នេះជាលើកទីមួយដែលព្រះសហគមន៍បានរួមសហការគ្នាជាមួយក្រុមគ្រូពេទ្យទាំងនេះ ហើយនឹងមានបន្តនៅឆ្នាំក្រោយទៀតតែពេលវេលាជាក់លាក់មិនអាចកំណត់បានទេ ព្រោះ សកម្មភាពនេះក៏អាស្រ័យលើស្ថានភាពជាក់ស្តែងនៅក្នុងប្រទេសកម្ពុជាផងដែរ។

*ដោយ ដាលីស*

# បុណ្យព្រះជាម្ចាស់លើកព្រះនាងម៉ារីឡើងស្ថានបរមសុខ នៅចំការទៀង

កាលពីថ្ងៃទី១៩ខែសីហាឆ្នាំ២០១៧ កន្លងទៅ ព្រះសហគមន៍កាតូលិក សន្តីម៉ារីញញឹម ចំការទៀង ស្ថិតនៅភូមិចំការទៀង ខេត្តកែវ បានប្រារព្ធពិធីបុណ្យព្រះជាម្ចាស់លើកព្រះនាងម៉ារី ឡើងស្ថានបរមសុខ។

កម្មវិធីនេះធ្វើឡើងក្រោមអធិបតីភាពលោកអូលីវីយេ អភិបាលព្រះសហគមន៍កាតូលិកភូមិភាគភ្នំពេញ លោកបូជាចារ្យតំណាងគ្រីស្តក្នុងមណ្ឌលសកម្មភាពព្រះសហគមន៍កាតូលិកតាកែវ យុវជន អ្នកស្វែងយល់ ប្រមាណជិត៣០០នាក់។

ក្នុងខណៈនោះលោកអភិបាលអូលីវីយេមានប្រសាសន៍ថា ថ្ងៃនេះយើងនឹកឃើញព្រះនាងជាមាតារបស់ព្រះយេស៊ូ ដែលជាអ្នកបម្រើដ៏ស្មោះត្រង់របស់ព្រះជាម្ចាស់។ លោកថា ព្រះនាងបានឆ្លើយតបនូវតម្រូវការរបស់អ្នកឯទៀតៗ ដោយសេចក្តីស្រឡាញ់ព្រះនាងក៏ឆ្លើយតបទៅនឹងព្រះជាម្ចាស់គ្រប់ពេលវេលា។

លោកអូលីវីយេបានបន្ថែមទៀតថា មិនត្រឹមតែប៉ុណ្ណោះព្រះនាងបានផ្តល់កម្លាំងដល់សាវ័កឯទៀតៗឲ្យប្រកាសដំណឹងល្អតាមរយៈព្រះវិញ្ញាណដ៏វិសុទ្ធ គង់សណ្ឋិតលើព្រះនាងនិងក្រុមសាវ័ក។ លោកបន្តថា ព្រះនាងម៉ារីជាគ្រីស្តបរិស័ទមុនគេបង្អស់ដែលឡើងស្ថានបរមសុខធ្វើដំណើររួមជាមួយព្រះម្ចាស់ ហើយព្រះជាម្ចាស់បានបំពាក់សេចក្តីស្រឡាញ់ អំណរសប្បាយ និងចិត្តដ៏វិសុទ្ធដែលនាំព្រះនាងម៉ារីទទួលជីវិតអស់កល្បជានិច្ច។

ក្រោយពីចូលអភិបូជា អ្នកចូលរួមទាំងចូលរួមទស្សនាការសម្តែងសិល្បៈ រឿងមង្គលការនៅភូមិកាណា ដែលសម្តែងដោយក្រុមសិល្បៈព្រះសហគមន៍កាតូលិកសន្តីម៉ារីញញឹមចំការទៀង។

*ដោយ យុន សំអាត*



# បងប្រុស ដាមីយ៉ាំង (១៩២៥?-១៩៧៧)

Frère Damien

## បព្វជិតនៃក្រុមបងប្រុសរបស់ព្រះញាតិវង្ស



លោកកើតប្រហែលឆ្នាំ ១៩២៥?។ លោកជាជនជាតិវៀតណាម ប៉ុន្តែនិយាយខ្មែរច្បាស់។ "លោកជាសមាជិកក្រុមគ្រួសារព្រះញាតិវង្ស នៅបាណាម។ តាំងពីវ័យក្មេងមក លោកយកចិត្តទុកដាក់ប្រៀនប្រដៅគ្រិស្តបរិស័ទខ្មែរយ៉ាងខ្លាំង មុនដំបុង នៅកំពង់គ បន្ទាប់មកនៅមាត់ក្រសាស់។ លោកព្យាយាមកសាងព្រះសហគមន៍នៅក្នុងភូមិទាំងពីរនោះ"។

លោកជាគ្រូអប់រំជំនឿ នៅព្រះសហគមន៍កំពង់គ។ លោកជាគំរូល្អសម្រាប់កូនសិស្ស និងអ្នកភូមិ។ លោកមានចិត្តដូចជាអ្នកគង្វាល និងមានលក្ខណៈចូលចិត្តអធិដ្ឋាន។ លោកតែងតែនាំសិស្សទៅព្រះវិហារ និងអធិដ្ឋានជានិច្ច។ លោកអប់រំជំនឿតាមរយៈការបំពេញសកម្មភាពឲ្យអ្នកភូមិដែរ ក៏ដូចជានាំសិស្សអធិដ្ឋានសម្រាប់បុណ្យសព និងការជួយចែករំលែកសុខទុក្ខអ្នកភូមិ។

លោកមានទំនាក់ទំនងល្អជាមួយអ្នកភូមិ ទោះបីជាមួយបងប្អូនពុទ្ធបរិស័ទ លោកក៏ចែករំលែក មានការទំនាក់ទំនង ធ្វើឲ្យអ្នកភូមិដែលជាកាតូលិកនិងពុទ្ធបរិស័ទមានការរាប់អានជាមួយគ្នាល្អ ហើយ អ្នកភូមិ និងកូនសិស្សក៏ស្រឡាញ់លោក ព្រោះលោកអប់រំកូនក្មេងឲ្យមានជំនឿ ជួនកាលលោកអប់រំ ជួយរៀបចំអាពាហ៍ពិពាហ៍ផងដែរ។

លោកក៏ត្រូវអង្គារដេញចេញពីក្រុងភ្នំពេញនៅថ្ងៃទី១៨ ខែមេសា ឆ្នាំ១៩៧៥ រួមជាមួយគ្រិស្តបរិស័ទ ឯទៀតៗដែរ។ ដោយឃើញលោកមានវ័យចំណាស់ អង្គការដាក់ទិសអោយចាំចំការចេកមួយនៅភូមិសំរៀង។ នៅពេលលោកជួបគ្រិស្តបរិស័ទណាម្នាក់ លោកតែងដាស់តឿនណែនាំគេ ឲ្យកាន់តាមជំនឿរបស់ខ្លួនដោយ ស្មោះត្រង់។ ជារៀងរាល់ថ្ងៃ លោកតែងសូត្រធម៌ឮខ្លាំងៗ។ ទោះបីយ៉ាងនេះក៏ដោយ ក៏គ្មានខ្មែរក្រហមណាហ៊ាន ធ្វើបាបលោកដែរ ព្រោះលោកចេះតែគំរាមពួកនោះ។ លោកចេះតែគូរគំនូរខ្វាត់ខ្វែងនៅលើដីរបៀបព័ទ្ធសីមា និងសូត្របាលី ដែលធ្វើឲ្យខ្មែរក្រហមខ្លាចញញើត មិនហ៊ានចូលជិត។ ប៉ុន្តែ នៅដំណាចឆ្នាំ ១៩៧៧ ពេលពួក និរតីឡើងកាន់អំណាច លោកដឹងខ្លួនថា លោកមុខជាត្រូវគេយកទៅសម្លាប់ជាមិនខាន ព្រោះលោកជាជនជាតិវៀតណាម។ តែលោកចង់ "ស្លាប់ស្របទៅតាមព្រះជាម្ចាស់"។

ពេលខ្មែរក្រហមហៅលោក លោកលុតជង្គង់អធិដ្ឋាន។ ខ្មែរក្រហមសម្លាប់លោក ហើយកប់សពលោក នៅក្រោមដើមស្វាយមួយដើម ក្បែរចំការចេកដែលលោកចាំ។


វិទ្យាល័យចំណេះទូទៅ និងបច្ចេកទេសឯកជន សន្តហ្វ្រង់ស្វ័រ

ក្នុងឆ្នាំសិក្សា ២០១៧-២០១៨ វិទ្យាល័យចំណេះទូទៅ និងបច្ចេកទេសឯកជន សន្តហ្វ្រង់ស្វ័រ នឹងជ្រើសរើសសិស្សទាំងពីរភេទ ឱ្យសិក្សាផ្នែកជំនាញបច្ចេកទេសកសិកម្មរយៈពេលបីឆ្នាំស្របតាមកម្មវិធីសិក្សាស្តង់ដាររបស់ ក្រសួងអប់រំ យុវជន និងកីឡា។

* ចាប់ទទួលពាក្យពីថ្ងៃជូនដំណឹងនេះ រហូតដល់ចុងខែកញ្ញា ឆ្នាំ២០១៧ *

**លក្ខខណ្ឌនៃការជ្រើសរើស**

* ត្រូវមានសញ្ញាបត្រមធ្យមសិក្សាបឋមភូមិ (ឌីប្លូម ថ្នាក់ទី ១០)
* ត្រូវមានអាយុយ៉ាងតិច ១៥ ឆ្នាំគិតត្រឹមថ្ងៃចូលរៀន
* ត្រូវមានសីលធម៌ល្អក្នុងការរស់នៅ

**ការសិក្សា**

* សិក្សាបច្ចេកទេសកសិកម្ម ២២ម៉ោង/សប្តាហ៍
* សិក្សាចំណេះដឹងទូទៅ ១៥ម៉ោង/សប្តាហ៍
* សិក្សាវិទ្យាសាស្ត្រកុំព្យូទ័រ ២ម៉ោង/សប្តាហ៍

**អត្ថប្រយោជន៍ដែលទទួលបាន**

* ទទួលបានសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិបច្ចេកទេស (បាក់ឌុប)
* អាចបន្តការសិក្សាទៅថ្នាក់ឧត្តមបាន
* ទទួលបានចំណេះ ជំនាញ បច្ចេកទេសកសិកម្មច្រើន

**ទីតាំង៖** ភូមិអង្គគគីរ ឃុំតាភេម ស្រុកត្រាំកក់ ខេត្តតាកែវ( ខាងក្រោយវិទ្យាស្ថាន សន្តប៉ូល)

**ទំនាក់ទំនង៖** ០១៧ / ០១៥ ៥៧៥ ៦៨៦ / ០១២ ៣១៤ ៤០៨ / ០៩០ ៩៩៣ ៣៩០

**ចំណាំ៖** សាលាមានអន្តេវាសិកដ្ឋាន សម្រាប់សិស្សទាំងពីរភេទមកពីឆ្ងាយ ស្នាក់នៅ ប្រកបដោយ សុវត្ថិភាព និងផាសុខភាព












# ពីធីលាបប្រេងឲ្យចាស់ជរានៅកំពង់ចាម


រូបថតពីហ្វេសបុក

ចាស់ជរា និងអ្នកជំងឺ៨នាក់ បានមកទទួលអគ្គសញ្ញាលាបប្រេងផ្តល់កំលាំង ធ្វើឡើងនៅព្រះសហគមន៍កំពង់ចាមក្រុងដែលស្ថិតនៅភូមិ១សង្កាត់វាលវង់ ក្រុងកំពង់ចាម ខេត្តកំពង់ កាលពីថ្ងៃទី០៧ ខែសីហា កន្លងទៅ ក្រោមអធិបតីភាពរបស់លោក អន់តូនីសាមី ស៊ូសៃរាជ្យជាអភិបាលប្រចាំភូមិភាគកំពង់ចាម។

តាមប្រសាសន៍របស់លោកអភិបាល អន់តូនីបានឲ្យដឹងថា ការលាបប្រេងនេះគឺមិនមែនសំដៅទៅលើជីវិតចុងក្រោយរបស់ពួកគាត់ដែលចូលដល់វ័យចាស់ជរាឬកំពុងមានជំងឺនោះទេ។ តែអ្វីដែលសំខាន់គឺព្រះសហគមន៍ចង់បញ្ជាក់ថា ការលាបប្រេងគឺជាការផ្តល់កម្លាំងបន្ថែមពីព្រះជាម្ចាស់ គឺយើងចង់លើកទឹកចិត្ត ផ្តល់កម្លាំងកាយចិត្ត និងការយកចិត្តទុកដាក់ចំពោះចាស់ជរា និងអ្នកជំងឺ ឲ្យគេមានសេចក្តីសង្ឃឹមនៅក្នុងជីវិតរស់នៅបន្តទៅមុខដោយជាប់ជាមួយវត្តមានរបស់ព្រះជាម្ចាស់ជានិច្ច។

អគ្គសញ្ញាលាបប្រេងឲ្យអ្នកជំងឺមានគោលដៅផ្តល់អំណោយទានពិសេសដល់គ្រីស្តបរិស័ទដែលជួបប្រទះនឹងទុក្ខលំបាកដោយសារជំងឺធ្ងន់ធ្ងរ ឬដោយជរាពាធ។ ពេលវេលាគួរសម ដើម្បីទទួលប្រេងដ៏វិសុទ្ធនេះ គឺនៅពេលដែលគ្រីស្តបរិស័ទជិតស្លាប់ ដោយសារគេឈឺឬចាស់ជរា។ រាល់ពេលដែលគ្រីស្តបរិស័ទមានជំងឺជាទម្ងន់ គេអាចទទួលប្រេងដ៏វិសុទ្ធ។ បើជំងឺជុនដាបទៅៗគេអាចទទួលប្រេងម្តងទៀត ទោះបីគេបានទទួលម្តងហើយក៏ដោយ។ (ដក់ស្រងចេញពីសៀវពីលទ្ធិនៃគ្រីស្ត-សាសនាតាមព្រះសហគមន៍កាតូលិក លេខ ១៥២៧-១៥២៩)។

លោកអភិបាលបានបន្ថែមទៀតថា៖ ព្រះសហគមន៍កំពុងតែរិះគិតរួមជាមួយគ្នាថាកម្មវិធីលាបប្រេងនេះគួរតែធ្វើរយៈពេលប្រាំមួយខែម្តងរឺយ៉ាងណា? ព្រោះនេះគឺជាលើកទីមួយនៅក្នុងព្រះសហគមន៍ដែលមានកម្មវិធីអធិដ្ឋាននិងលាបប្រេងឲ្យពួកគាត់បែបនេះ។

លោកថា អ្នកដែលមកទទួលការលាបប្រេងនេះគឺមានអាយុចន្លោះពី៤០ ដល់៧០ឆ្នាំ។ ហើយការធ្វើបែបនេះគឺព្រះសហគមន៍ចង់យកចិត្តទុកដាក់ជាខ្លាំងជាមួយចាស់ជរា អ្នកក្រីក្រ អ្នកជំងឺដែលមិនសូវមានអ្នកចាប់អារម្មណ៍អំពីជីវិតរបស់ពួកគាត់។ លោកបន្តថា យើងក៏ចង់បង្ហាញថា ទោះបីជាពួកគាត់ចាស់ទ្រុឌទ្រោមយ៉ាងណា មានការលំបាកដោយសារជំងឺក្នុងខ្លួនយ៉ាងណាក៏ព្រះសហគមន៍មិនបានបោះបង់គាត់ចោលដែរគឺនៅចាំផ្តល់កម្លាំងឲ្យចិត្តជានិច្ច។

លោកអភិបាលក៏បានរំលឹកដល់គ្រីស្តបរិស័ទទាំងអស់ថា សូមឲ្យយើងចេះយកចិត្តទុកដាក់ចំពោះគ្នាទៅវិញទៅមក ជាពិសេសសម្រាប់អ្នកជំងឺ និងចាស់ជរា មនុស្សទូទៅក្នុងសង្គម ចេះចែករំលែកសេចក្តីស្រលាញ់ចំពោះគ្នាដូចព្រះយេស៊ូដែលបានស្រលាញ់មនុស្សលោកដោយមិនប្រកាន់អ្វីទាំងអស់៕

*ដោយៈ រឿន ស្រីម៉ាច*

# ព្រះសហគមន៍កោះរកាបង្ហាញផ្លូវយុវជននិងកុមារ អោយចេះចាប់អារម្មណ៍នឹងតំបន់ទេសចរណ៍ប្រវត្តិសាស្ត្រ

យុវជនរួមនិងកុមារចំនួន ប្រមាណ ៨២នាក់ដែលកំពុងទទួលការអប់រំជំនឿ បានទទួលការលើកទឹកចិត្ត ពីព្រះសហគមន៍កាតូលិកសន្ត ហ្វ្រង់ស្វ័រ និងសន្តីក្លារ៉ាអាស៊ីស៊ីដែលស្ថិតនៅក្នុង ភូមិកោះរកាក្រៅ ឃុំកោះរកា ស្រុកកំពង់សៀម ខេត្តកំពង់ចាម ក្នុងដំណើរកំសាន្ត សិក្សាពេលពេញមួយថ្ងៃ នៅតំបន់ទេសចរណ៍ប្រវត្តិសាស្ត្រមួយកន្លែងក្នុងខេត្តត្បូងឃ្មុំ កាលពីថ្ងៃទី១០ សីហា ឆ្នាំ២០១៧។

លោកផានបូរី ជាបូជាចារ្យនៅព្រះសហគមន៍កាតូលិកោះរកា មានប្រសាសន៍ថា កម្មវិធីនេះតូច តែមានអត្ថន័យ និងមានសារៈសំខាន់សម្រាប់អ្នកចូលរួម។ លោកថា ជាទូទៅយុវជនក៏ដូចជាកុមារភាគច្រើនមិនសូវចាប់អារម្មណ៍តំបន់ទេសចរណ៍ប្រវត្តិសាស្ត្រនៅក្នុងប្រទេសរបស់ខ្លួននោះទេ ហើយប្រសិនបើពួកគេទៅលេងក៏គ្រាន់តែជាការសប្បាយ ឬថតរូបលេងមួយពេល តែគេមិនដឹងអំពីប្រវត្តិនៃប្រាសាទ ឬប្រវត្តិកន្លែងទេសចរណ៍មួយនោះទេ។ ហេតុនេះព្រះសហគមន៍បាននាំពួកគេទៅទស្សនានៅប្រាសាទហ្លួងព្រះស្តេចដែលមានរូបសំណាក់ស្តេចកនតាំងនៅទីនោះ។ លោកបូជាចារ្យបន្តថា មានយុវជនពីនាក់ដែលសិក្សាផ្នែកប្រវត្តិសាស្ត្រនៅសកលវិទ្យាល័យ បានជួយពន្យល់ និងណែនាំពួកគេ ឲ្យបានដឹងខ្លះៗអំពីប្រវត្តិប្រាសាទនោះ ថានណាជាអ្នកកសាង? ហើយក៏សាងឡើងដើម្បីអ្វី? ហើយហេតុអ្វីប្រាសាទនោះតាំងទីលំនៅក្នុងខេត្តត្បូងឃ្មុំ? លោកបូរីបន្ថែមថា ក្នុងនាមលោកជាអ្នកណែនាំពិតជាសប្បាយចិត្តនៅពេលដែលបានឃើញកុមាររួមទាំងយុវជន មានការចាប់អារម្មណ៍អំពី ប្រវត្តិសាស្ត្រយ៉ាងយកចិត្តទុកដាក់បែបនេះ បើទោះបីជាមិនមែនជាការសិក្សាឲ្យបានស៊ីជម្រៅ តែវាក៏បានបង្ហាញ និងបើកគំនិតខ្លះៗសម្រាប់គេដែរ។ លោកសង្ឃឹមថា យុវជន ឬប្រជាជនយកចិត្តទុកដាក់ និងឲ្យតម្លៃទៅលើប្រាសាទបុរាណ ឬតំបន់ទេសចរណ៍ប្រវត្តិសាស្ត្រដែលជាស្នាដៃដូតាបន្សល់ទុកឲ្យកូនខ្មែរជំនាន់ក្រោយ កាន់តែខ្លាំងថែមទៀត។ លោកផ្តាំថា បើមិនទាន់ដឹងទេ សូមសិក្សាឈ្វេងយល់ខ្លះៗអំពីប្រវត្តិសាស្ត្រខ្មែរ ប្រវត្តិនៃប្រាសាទនីមួយៗក្នុងប្រទេសកម្ពុជាយើង និងសូមចូលរួមថែរក្សានូវកេរដំណែលដ៏ល្អមួយទាំងអស់គ្នា។

ក្នុងដំណើរកម្សាន្តនោះក៏មានកម្មវិធីអធិដ្ឋានរួមគ្នាដើម្បីអរព្រះគុណព្រះជាម្ចាស់សម្រាប់អំណោយទានគ្រប់យ៉ាងរួមទាំងស្នារព្រះហស្តជាច្រើន មានទាំងខ្យល់ដង្ហើមនិងជីវិតរស់នៅប្រចាំថ្ងៃផងដែរ។

*ដោយ រឿន ស្រីម៉ាច*


រូបថតពីហ្វេសបុក

# កុមារជាង១០០នាក់ បានទទួលការបំប៉នចំណេះដឹងទូទៅ បន្ថែម លើមុខ វិទ្យាភាសាខ្មែរ និង អង់គ្លេស

ព្រះសហគមន៍កាតូលិក ព្រះវិហារសន្ត យ៉ូសែប ភូមិក្ដុលលើ ដែលស្ថិតនៅក្នុងភូមិក្ដុលលើ ឃុំទ្រា ស្រុកក្រូចឆ្មារ ខេត្តត្បូងឃ្មុំ បានបើកថ្នាក់បំប៉នចំណេះដឹងទូទៅ ដល់កុមារជាសិស្សថ្នាក់ទី១ ដល់ទី៧។ ថ្នាក់បំប៉ននេះបានបើកចាប់ពីដើមខែសីហាមក ដោយបានទទួលកុមារចំនួនជាង១០០នាក់ឲ្យចូលរៀន លើមុខវិទ្យាភាសាខ្មែរ និងភាសាអង់គ្លេស។ តាមប្រសាសន៍របស់លោកបូជាចារ្យ លូកា បូឡេល្លើជាបូជាចារ្យទទួលខុសត្រូវនៅព្រះសហគមន៍ក្ដុលលើបានឲ្យដឹងថា ព្រះសហគមន៍ បានបើកថ្នាក់បំប៉ន ចំណេះដឹងទូទៅដល់កុមារ ចាប់ពីថ្នាក់ទី១ ដល់ថ្នាក់ទី៧ ក្នុងអំឡុងពេលវិសម្សកាលក្នុងឆ្នាំនេះ។ លោកបន្តថា កម្មវិធីនេះប្រព្រឹត្តទៅគឺមានការចូលរួមយ៉ាងសកម្មពីសំណាក់យុវជននឹងយុវនារីក្នុងព្រះសហគមន៍កាតូលិកក្ដុលលើ។ ពួកគេបែងចែកតាមថ្នាក់ផ្សេងៗតាមកំរិត តាមវេន គឺវេនពេលព្រឹក និងវេនពេលល្ងាច។

លោកបូជាចារ្យបន្ថែមថា ពេលបង្រៀនដល់កុមារទាំងនោះ គឺមិនគ្រាន់តែរៀនប៉ុណ្ណោះទេក្នុងនោះក៏មានការលេងល្បែងកម្សាន្ត ការអានរឿងនិទាន និងការធ្វើពលកម្មកខ្លះៗក្នុងព្រះវិហារ។ លោកបូជាចារ្យបានប្រាប់ពីមូលហេតុដែលបើកថ្នាក់បំប៉ុននេះ ព្រោះព្រះសហគមន៍មើលឃើញថា កុមារៗនិងយុវជនយុវនារី មានពេលវេលាទំនេរច្រើនក្នុងពេលសម្រាកពីការសិក្សាមួយរយៈ។ ពេលទំនេរៗកុមារមិនបានចាប់អារម្មណ៍ក្នុងការសិក្សានោះទេ គឺពួកគេយកពេលវេលាដើរលេង ឬធ្វើអ្វីផ្សេងៗដែលគ្មានប្រយោជន៍ច្រើន។ ហេតុនេះព្រះសហគមន៍បង្កើត ថ្នាក់សិក្សានេះ ដើម្បីឲ្យយពួកគេមានពេលវេលានិងទីកន្លែងសមរម្យទទួលនូវចំណេះដឹងទុកត្រៀមសម្រាប់ពេលចូលរៀននៅសាលារដ្ឋ វិញនាពេលខាងមុខ។ ម៉្យាងទៀតព្រះសហគមន៍កាតូលិកចង់ឲ្យយុវជនយុវនារីចេះចែករំលែកសេចក្ដីស្រលាញ់ក្នុងកិច្ចការផ្សេងៗ គឺឲ្យគេលះបង់ពេលវេលាផ្ទាល់ខ្លួនខ្លះៗដើម្បីជួយបង្រៀនក្មេងៗទាំងនោះល្អជាងយកពេលវេលាទំនេរពីការសិក្សាទៅអង្គុយចុចទូរស័ព្ទ ឬដើរលេងឥតប្រយោជន៍។ រាងរាល់ឆ្នាំព្រះសហគមន៍ក្ដុលលើតែងតែបើកថ្នាក់បំប៉នចំណេះដឹងទូទៅនេះ ដើម្បីឲ្យមានឱកាស់បានទទួលបានការរៀនសូត្របន្ថែម។ លោកបូជាចារ្យ ជាអ្នកទទួល ខុសត្រូវព្រះសហគមន៍នេះ មានសង្ឃឹមយ៉ាងមាំថា អ្វីដែលព្រះសហគមន៍ផ្ដល់ឲ្យពួកគេដែលជាទំពាំងស្នងឫស្សី គឺជាទ្រព្យសម្បិត្តដ៏សំខាន់ទៅថ្ងៃអនាគត។ បើទោះបីជាវាមិនមែនជាលុយកាក់ ឬរបស់អ្វីផ្សេង តែវាគឺជាចំណេះដឹងដ៏មានតម្លៃដែលមិនអាចទិញដូរបាន។ នៅពេលអនាគតកុមារទាំងនោះ និងបន្តការរៀនសូត្ររហូតដល់មានកាងារល្អនៅក្នុងសង្គមជាកុមារល្អ ជាយុវជនល្អ និងជាប្រជាពលរដ្ឋល្អ។ លោកក៏សូមអំពាវនាវឲ្យអាណាព្យាបាលទាំងអស់ជួយជំរុញ ផ្ដល់កម្លាំងចិត្តឲ្យកូនៗបន្តការសិក្សារៀនសូត្រទៅមុខបើទោះបីជាគ្រួសារក្រីក្រ ឬជួបបញ្ហាអ្វីក៏ដោយ យ៉ាងហោចណាស់ក៏គេអាចមានសមត្ថភាពអានអក្សរ យល់ការដឹងខុសដឹងត្រូវ និងមានសម្ថតភាពក្នុងការធ្វើការងារផ្សេងៗដើម្បីជួយខ្លួនឯងបាន។ ប្រសិនបើអាណាព្យាបាលបញ្ឈប់ការសិក្សារបស់ពួកគឺប្រៀបដូចបំផ្លាញអនាគតរបស់កូនខ្លួន។

ដោយ ឿន ស្រីម៉ាច


ថតដោយ លោក លូកា

# សិក្ខាសាលាស្ដីអំពីបរិស្ថានសម្រាប់យុវជននៅក្រុងកំពង់ចាម

យុវជនយុវនារីប្រមាណជាង១០០ នាក់ មកពីបណ្ដាព្រះសហគមន៍នានាក្នុងភូមិភាគកំពង់ចាមចូលរួមសិក្ខាសាលាមួយស្ដីអំពី "បរិស្ថាន" ដែលមានរយៈមួយថ្ងៃ នៅព្រះវិហារក្រុងកំពង់ចាម ដែលស្ថិតនៅក្នុងភូមិ១ ឃុំវាលវង់ ក្រុងកំពង់ចាម ខេត្តកំពង់ចាម កាលពីថ្ងៃ១២ ខែសីហា ឆ្នាំ២០១៧ កន្លងទៅ។

តាមប្រសាសាន៍របស់លោក សែ សាត ជាបូជាចារ្យទទួលខុសត្រូវនៅព្រះសហគមន៍ ក្រុងកំពង់ចាមបានឲ្យដឹងថា កម្មវិធីសិក្ខាសាលាស្ដីអំពី បរិស្ថាននេះ គឺមានការចូលរួមពីសំណាក់អង្គការជេស្វីតសឺវីសកម្ពុជាផ្នែកបរិស្ថាន។ លោកបន្តថា អ្វីដែលជាគោលបំណងសំខាន់ក្នុងកម្មវិធីសិក្ខាសាលានេះ គឺចង់ឲ្យយុវជនយុវនារីទាំងអស់ចេះចាប់អារម្មណ៍ជាមួយនឹងបរិស្ថានដែលនៅជុំវិញខ្លួន ចេះស្រលាញ់ និងថែរក្សាយល់ដឹងឲ្យកាន់តែច្បាស់អំពីអត្ថប្រយោជន៍នៃបរិស្ថានជាពិសេសគឺឲ្យពួកគេដឹងថា ទង្វើអ្វីខ្លះដែលធ្វើឲ្យប៉ះពាល់ដល់បរិស្ថាន។

លោកបូជាចារ្យសាតបានបន្តថា អ្វីៗទាំងអស់គឺ ជាស្នាព្រះសហ្ដរបស់ព្រះជាម្ចាស់។ ដើមឈើ និងព្រៃព្រឹក្សានានាគឺជាធនធានធម្មជាតិ ដោយហេតុនេះការកាប់បំផ្លាញព្រៃឈើ គឺជារឿងមួយដែលខុស ព្រោះវាអាចប៉ះពាល់ដល់ជីវិតរស់នៅរបស់មនុស្ស និងសត្វទាំងក្នុងសម័យនេះ និងពេលអនាគតទៅមុខ។ ហេតុនេះកម្មវិធីសិក្ខាសាលានេះ គឺផ្ដល់សារៈសំខាន់ក្នុងការដាស់តឿនយុវជនយុវនារីទាំងអស់ ឲ្យចេះស្រលាញ់បរិស្ថាន ដូចជាមិនគួរបោះចោលសំរាមតាមទីសាធារណៈ ឬក្នុងស្ទឹងបឹងបួរ ទន្លេផ្សេងៗ កុំបំពុលផ្សេងដែលមានជាតិពុលក្នុងបរិស្ថាន កុំកាប់បំផ្លាញដើមឈើមិនគួរបន្ទោបង់តាមទីសាធារណៈ។ល។

លោកសាតបន្ថែមទៀតថា យុវជនគឺជាទំពាំងស្នងឫស្សី ហេតុនេះលោកសង្ឃឹមថាបន្ទាប់ពីបញ្ចប់កម្មវិធីសិក្ខាសាលានេះទៅពួកគេនឹងយល់កាន់តែច្បាស់ អំពីតម្លៃនៃបរិស្ថានធម្មជាតិ ហើយចូលរួមកាត់បន្ថយនូវសកម្មភាព ដែលនាំឲ្យប៉ះពាល់ដល់បរិស្ថានជាពិសេសការប្រើប្រាស់ថង់ផ្លាស្ទិក និងដបទឹកសុទ្ធដែលជាការពេញនិយមប្រើប្រាស់យុវជន។

បន្ទាប់ពីសិក្ខា សាលាយុវជនតាមព្រះសហសគមន៍នីមួយៗ បានរួមគំនិតគ្នាដើម្បីរៀបចំគម្រោងផែនការអនុវត្តប្រចាំថ្ងៃ ដើម្បីចូលរួមថែរក្សាបរិស្ថានតាមសមត្ថភាពដែលអាចធ្វើទៅបាន ដោយចូលរួមកាត់បន្ថយការចោលសំរាម ការប្រើប្រាស់ថងផ្លាស្ទិកដបទឹកសុទ្ធ និងជួយណែនាំទៅមិត្តភក្តិនិងអ្នកនៅជុំវិញខ្លួន ឲ្យចូលរួមស្រលាញ់ និងថែរក្សាបរិស្ថានផងដែរ៕

ដោយ ឿន ស្រីម៉ាច


ថតដោយ កញ្ញា សោភា

# អ្នកប្រើប្រាស់ថង់ប្លាស្ទិកនៅកេនយ៉ា អាចជាប់គុក៤ឆ្នាំ

អាជ្ញាធរនៅក្នុងប្រទេសកេនយ៉ា បានប្រកាសអនុវត្តនូវច្បាប់ដ៏តឹងរឹងបំផុតប្រឆាំងនឹងអ្នកដែលប្រើប្រាស់ថង់ប្លាស្ទិកដើម្បីការពារបរិស្ថាន ដោយអ្នកណាដែលល្មើសអាចនឹងត្រូវជាប់ពន្ធនាគារ ឬពិន័យជាប្រាក់ដ៏ច្រើនសន្ធឹកសន្ធាប់។

បណ្តាញសារព័ត៌មានបរទេសបានរាយការណ៍ថា ការហាមប្រាមលើការប្រើប្រាស់ថង់ប្លាស្ទិកនេះបានចូលជាធរមានកាលពីថ្ងៃច័ន្ទទី២៨ ខែសីហា ក្នុងការប្រឹងប្រែងដើម្បីពន្យឺតការបំពុលបរិស្ថាន ដោយអ្នកប្រើប្រាស់អាចនឹងត្រូវ ផាកពិន័យរហូតដល់ ៣៨.០០០ ដុល្លារនិងកាត់ទោសឲ្យជាប់ពន្ធនាគាររហូតដល់ទៅ ៤ ឆ្នាំ។

តាមការប៉ាន់ប្រមាណរបស់កម្មវិធីបរិស្ថានរបស់អង្គការសហប្រជាជាតិបានឲ្យដឹងថា បណ្តាផ្សារទំនើបនៅប្រទេសកេនយ៉ាបានចែកចាយថង់ប្លាស្ទិកចំនួនប្រមាណជា ១០០ លានជារៀងរាល់ឆ្នាំ ហើយបន្ទាប់ពីច្បាប់នេះបានចូល ជាធរមានក្រោយការពន្យាពេលមួយរយៈមកនោះ លោក អេរិក សូលហេអ៊ីម នាយកនៃអង្គការកម្មវិធីបរិស្ថានរបស់អង្គការសហប្រជាជាតិ បានស្វាគមន៍ចំពោះការហាមឃាត់នេះថាជាជំហានដ៏សំខាន់មួយដើម្បីបញ្ចប់ការបំពុលដោយប្លាស្ទិក។

# បណ្តាមេដឹកនាំក្រុមហ៊ុននិងធនាគារវៀតណាមចំនួន៥១នាក់ត្រូវបាននាំខ្លួនទៅតុលាការ

អាជ្ញាធរវៀតណាមកាលពីថ្ងៃទី២៨ ខែសីហា បានកោះហៅមនុស្ស និងបុគ្គលិកធនាគាររាប់រយនាក់ឲ្យចូលខ្លួនមកតុលាការនៅទីក្រុងហាណូយ ដើម្បីវិនិច្ឆ័យទោសមេដឹកនាំក្រុមហ៊ុនរដ្ឋ និងស្ថាប័នធនាគារធំៗចំនួន ៥១ រូប ដែលកំពុងតែមានពិរុទ្ធរឿងក្លែងបន្លំប្រាក់ពីធនាគារ ជាពិសេសគឺធនាគារ អូសៀន (Ocean Bank)។

ក្នុងចំណោមចុងចោទដែលមានពិរុទ្ធទាំង៥១នាក់នេះ គឺមានក្រុមអតីតសមាជិកនៃក្រុមហ៊ុនប្រេងរដ្ឋ ប៉េត្រូវៀតណាម ធនាគារកណ្តាល និងធនាគារសំណង់វៀតណាម ដែលត្រូវបានយកមកកាន់កាប់វិញដោយរដ្ឋាភិបាលវៀតណាមនៅឆ្នាំ២០១៥ បន្ទាប់ពីបានប្រឈមនឹងការខាតបង់ប្រាក់ជាបន្តបន្ទាប់មកនោះ។

បណ្តាញ ព័ត៌មានបរទេសបានរាយការណ៍ថា មនុស្សជិត៧០០នាក់ ដែលរួមទាំងក្រុមមេធាវីជាង៥០នាក់ និងមនុស្សរាប់រយនាក់ដែលទទួលផលប្រយោជន៍ពីការប្រើប្រាស់លុយមិនត្រឹមត្រូវនោះ ក៏ត្រូវបានកោះហៅមកតុលាការ។

នៅក្នុងចំណោមពួកមេដឹកនាំដែលមានពិរុទ្ធទាំងនោះមួយចំនួនត្រូវបានចោទប្រកាន់បន្ថែមទៀតពីបទក្លែងបន្លំយកប្រាក់ ដែលជាការចោទប្រកាន់បន្ថែមទៅលើការរំលោភបំពានច្បាប់អំពីការផ្តល់ប្រាក់កម្ចី និងរំលោភច្បាប់រដ្ឋអំពីការគ្រប់គ្រងសេដ្ឋកិច្ច ដែលបានបង្កឱ្យមានផលវិបាកធ្ងន់ធ្ងរដល់ប្រទេសជាតិ។ ករណីចោទប្រកាន់ថ្មីនេះ ត្រូវបានធ្វើឡើងចំពោះចុងចោទថ្មីចំនួន៤នាក់ ដែលរួមទាំងលោកផាំ កុង ដាញ់ អតីត ប្រធានធនាគារសំណង់វៀតណាម ដែលបានកំពុងជាប់គុករយៈពេល៣០ឆ្នាំ បន្ទាប់ពីតុលាការបានរកឃើញទោសកំហុសរបស់លោកកាលពីឆ្នាំមុន ពីបទដក លុយ ខុសច្បាប់ជាង៤០៤លានដុល្លារ៕

# អតីតនាយករដ្ឋមន្ត្រីថៃភៀសខ្លួនចេញពីប្រទេសគេចពីរឿងក្តីករណីគម្រោងការទិញស្រូវ

លោកស្រី យីងឡាក ស៊ីណាវ៉ាត់ អតីតនាយករដ្ឋមន្ត្រីថៃស្ត្រីទីមួយ នៅក្នុងប្រទេសថៃ បានភៀសខ្លួនគេចចេញពីប្រទេសនេះ កាលពីចុងខែសីហាពេលគឺនៅមុនពេលប្រកាសសាលក្រមរបស់តុលាការអំពីករណីធ្វេសប្រហែសការងាររបស់លោកស្រីដែលជាប់ពាក់ព័ន្ធនឹងគម្រោងទិញស្រូវអង្ករពីកសិករដ៏ចម្រូងចម្រាស់។

បន្ទាប់ពីភៀសខ្លួនមានការវិភាគជាច្រើនដែលធ្វើឡើងដោយប្រព័ន្ធផ្សព្វផ្សាយ និងសាធារណជននៅក្នុងប្រទេសថៃ អំពីមធ្យោបាយ ដែលលោកស្រីអាចចាកចេញពីប្រទេស បើទោះបីជាលោកស្រី កំពុងតែជាប់នៅក្នុងការតាមដាន ដ៏ជិតដល់ពីសំណាក់រដ្ឋាភិបាលយោធាថៃ។ ដោយខ្លះនៅក្នុងចំណោមនោះ បានផ្សព្វផ្សាយថា លោកស្រី បានភៀសខ្លួនមកកម្ពុជាមុនពេលទៅសិង្ហបុរី ហើយហោះទៅកាន់ទីក្រុងឌូបៃ ជាកន្លែងដែលលោកស្រី បានជួប លោក ថាក់ស៊ីន ស៊ីណាវ៉ាត់ ដែលកំពុងតែភៀសខ្លួននៅទីនោះ។

ជុំវិញការភៀសខ្លួននេះ រដ្ឋមន្ត្រីការបរទេសថៃបាននិយាយកាលពីថ្ងៃទី២៩ ខែសីហាថា អាជ្ញាធរយោធាថៃមិនមានផែនការភ្លាមៗក្នុងការលុបចោលលិខិតឆ្លងដែនរបស់លោកស្រីយីងឡាក់ទេ បន្ទាប់ពីលោកស្រីបានរត់ភៀសខ្លួននោះ។

លោកស្រី យីងឡាក់ ស៊ីណាវ៉ាត់ បានខកខានមិនបានបង្ហាញខ្លួននៅតុលាការកាលពីថ្ងៃទី២៥ ខែសីហា ដោយបានធ្វើឱ្យក្រុមអ្នកគាំទ្ររាប់ពាន់នាក់របស់លោកស្រីនៅតុលាការកំពូលនោះមានការភ្ញាក់ផ្អើលខ្លាំង ដោយសមាជិកជាន់ខ្ពស់របស់គណបក្សបាននិយាយថា លោកស្រីបានរត់គេចខ្លួនទៅកាន់ទីក្រុងឌូបៃ។

លោកស្រី យីងឡាក់ ស៊ីណាវ៉ាត់ កាន់លិខិតឆ្លងដែនថៃ២ គឺលិខិតឆ្លងដែនធម្មតាមួយ និងមួយទៀតជាលិខិតឆ្លងដែនការទូត ហើយលោកស្រី ត្រូវបានគេជឿថាកាន់លិខិតឆ្លងដែនទី៣ផងដែរ គឺលិខិតឆ្លងដែនបរទេស។

លោក ដុន ប្រាមុតវីណៃ រដ្ឋមន្ត្រីការបរទេសថៃ បាននិយាយប្រាប់ក្រុមអ្នកយកព័ត៌មានថា ការស្នើសុំដកលិខិតឆ្លងដែនលោកកស្រី យីងឡាក់ មិនទាន់ទៅដល់ក្រសួងការបរទេសនៅឡើយទេ។ ក្រសួងមិនទាន់ចាត់ការលើករណីនេះនៅឡើយទេ"។

លោកស្រីយីងឡាក់ ស៊ីណាវ៉ាត់ ត្រូវបានបង្ខំឱ្យចុះចេញពីអំណាចពីរបីថ្ងៃនៅមុនការធ្វើរដ្ឋប្រហារឆ្នាំ២០១៤ បន្ទាប់ពី តុលាការបានរកឃើញទោសកំហុសរបស់លោកស្រីពីបទរំលោភអំណាច។ លោកស្រីអាចជាប់គុក១០ឆ្នាំ បើសិនលោកស្រីត្រូវបានរកឃើញទោសកំហុសអំពីការគ្រប់គ្រងគម្រោងទិញស្រូវអង្ករមិនត្រឹមត្រូវ ដែលបានធ្វើបាត់បង់ថវិការដ្ឋ ៨ពាន់លានដុល្លារ។

# ប្រទេសឥណ្ឌូនេស៊ីជួបប្រទះបញ្ហាគាំងម៉ាស៊ីនដកប្រាក់អេធីអឹមរាប់ពាន់គ្រឿង

ម៉ាស៊ីនដកប្រាក់អេធីអឹម និងម៉ាស៊ីនបង់ប្រាក់អេឡិចត្រូនិករាប់ពាន់គ្រឿងនៅក្នុងប្រទេសឥណ្ឌូនេស៊ីបានដាច់ការប្រើប្រាស់កាលពីចុងខែសីហា ដោយសារតែការដាច់ចរន្តអគ្គិសនីពីផ្កាយរណប ដែលជាកម្មសិទ្ធិរបស់ក្រុមហ៊ុន តេឡេខំឥណ្ឌូនេស៊ី។

លោក អាឡិច ស៊ីណាហ្គា នាយកប្រតិបត្តិក្រុមហ៊ុនតេឡេខំនេះបានប្រាប់អ្នកសារព័ត៌មានបរទេសថា ទីតាំងលើដីប្រមាណ ១៥.០០០ កន្លែងនៅទូទាំងប្រទេសឥណ្ឌូណេស៊ី បានរងផលប៉ះពាល់ដោយសារបញ្ហានៅលើផ្កាយរណប តេឡេខំទីមួយដែលជាប្រភពនៃសេវាកម្មនៃទីភ្នាក់ងាររដ្ឋាភិបាល ធនាគារ ស្ថានីយទូរទស្សន៍ និងក្រុមហ៊ុនដទៃទៀត។

លោក ចាហា សេធីអាតម៉ាដចា នាយកប្រតិបត្តិធនាគារ ប៊ីស៊ីអេ ដែលជាធនាគារធំបំផុតរបស់ឥណ្ឌូនេស៊ី បានឲ្យដឹងថា មានម៉ាស៊ីនអេធីអឹម ប្រហែល ៥.៧០០ គ្រឿងរបស់ធនាគារបានរងនូវផលប៉ះពាល់ដោយការដាច់ចរន្តអគ្គិសនី ឬស្មើនឹង ៣០ ភាគរយនៃប្រតិបត្តិការសរុបរបស់ធនាគារ។ លោកបាននិយាយបន្តថា ការតភ្ជាប់អ៊ីធឺណេតនៅតាមសាខាដាច់ស្រយាលមួយចំនួនរបស់ធនាគារត្រូវបានប៉ះពាល់ផងដែរ។

# ធម្មទេសនារបស់លោកអភិបាលអូលីវីយេ
# អភិបូជាក្នុងដំណើរទស្សនៈកិច្ចជាមួយនិស្សិតសាលាសន្តយ៉ូស្វីននៅប្រទេសម៉ាឡេស៊ី
# ថ្ងៃទី៣០ កក្កដា ២០១៧



អត្ថបទទី១៖ ១ពង្សក្សត្រ ៣,៥.៧-១២
អត្ថបទទី២៖ រម ៨,២៨-៣០
ដំណឹងល្អ៖ មថ ១៣,៤៤-៥២

បងប្អូនជាទីស្រឡាញ់!

ខ្ញុំជឿថាយប់មិញ យើងបានធ្វើបទ-ពិសោធន៍អំពីព្រះរាជ្យរបស់ព្រះជាម្ចាស់។ ព្រះរាជ្យរបស់ព្រះជាម្ចាស់ មិនមែនជាពាក្យមួយដែលយើងនិយាយទូទៅ ប៉ុន្តែយើងបានឃើញជាក់ស្តែង នៅពេលដែលយើងឃើញជាងដប់ម៉ឺននាក់ដែលមកពីគ្រប់ទីកន្លែង មកពីម៉ាឡេស៊ី មកពីសឹង្ហបុរី មកពីថៃ មកពីឥណ្ឌូនេស៊ី មកពីប្រទេសកម្ពុជាជាដើម។ យើងឃើញបងប្អូនដែលជាគ្រីស្តបរិស័ទ បងប្អូនដែលមកពីសាសនាដទៃ ដែលណែនាំឲ្យយើងយល់ថា **ពិតមែនព្រះយេស៊ូបានណែនាំឲ្យយើងជួបជុំគ្នា ឲ្យយើងចូលរួមនៅក្នុងមហាគ្រួសារតែមួយ។**

អម្បាញ់មិញ យើងបានស្តាប់គម្ពីរដំណឹងល្អ **ព្រះរាជ្យរបស់ព្រះជាម្ចាស់ប្រៀបបីដូចជាពេជ្រមួយ ជាកំណប់មួយដែលមានតម្លៃលើសលប់** ដោយសារតម្លៃនេះយើងមិនអាចរាប់បានទេ។ ពីយប់មិញបទពិសោធន៍ដែលយើងមានជាមួយបងប្អូនទាំងអស់ អភិបូជាដែលយើងថ្វាយនៅពេលនេះដែរ ជាបទពិសោធន៍មួយដែលយើងរាប់មិនបាន ប៉ុន្តែយើងយល់ឃើញថា ពិតមែនព្រះជាម្ចាស់ស្រឡាញ់យើង ហើយយើងកំពុងធ្វើបទពិសោធន៍អំពីសេចក្តីស្រឡាញ់នេះ។

យើងបានឃើញចំណងជើង **"សូមធ្វើជាសាវ័ក នៃសេចក្តីសង្ឃឹម"**។ ប៉ុន្តែនៅពេលយើងថាធ្វើជាសាវ័ក ឲ្យយើងមើលឃើញដល់ព្រះនាងម៉ារី ដោយសារព្រះនាងម៉ារីជាសាវ័កមុនគេបង្អស់។ នៅក្នុងប្រវត្តិសាស្ត្រនៃការសង្គ្រោះ គឺព្រះនាងម៉ារី ដែលបានឆ្លើយមុនគេបង្អស់ "ចាស! ខ្ញុំធ្វើជាមាតានៃព្រះជាម្ចាស់បាន"។ ព្រះនាងម៉ារី អាចធ្វើបានដោយសារ៖

**ទីមួយ** ព្រះនាងម៉ារី ស្តាប់ព្រះបន្ទូលរបស់ព្រះជាម្ចាស់។

**ទីពីរ** ព្រះនាងម៉ារីសុខចិត្ត ធ្វើតាមព្រះហឫទ័យរបស់ព្រះជាម្ចាស់ មិនត្រឹមតែស្តាប់ ប៉ុន្តែធ្វើតាមអ្វីដែលព្រះនាងម៉ារីបានស្តាប់និងអនុវត្តន៍។ នៅក្នុងការអនុវត្តព្រះនាងម៉ារី បម្រើ និងស្រឡាញ់។ បម្រើព្រះយេស៊ូ ស្រឡាញ់ព្រះយេស៊ូ បម្រើបងប្អូនឯទៀតៗ ស្រឡាញ់បងប្អូនឯទៀតៗ។ ពីរសប្តាហ៍ទៀត យើងគោរពព្រះនាងម៉ារីឡើងស្ថានបរមសុខ ជាពេលវេលាមួយដែលព្រះនាងម៉ារី ចូលទៅក្នុងព្រះហឫទ័យស្រឡាញ់របស់ព្រះជាម្ចាស់តែម្តង។ ជាពេលវេលាមួយដែលព្រះនាងម៉ារី ទៅជាអង្គតែមួយជាមួយសេចក្តីស្រឡាញ់របស់ព្រះជាម្ចាស់។ សម្រាប់យើង ជាឱកាសមួយដើម្បីគិត **តើយើងធ្វើដូចម្តេចដើម្បីទៅជា ព្រះហឫទ័យស្រឡាញ់ ដើម្បីធ្វើជាព្រះបេះដូងស្រឡាញ់របស់ព្រះយេស៊ូលើផែនដីនេះ?**

នៅពេលដែលយើងនិយាយអំពីសាវ័កនៃសេចក្តីស្រឡាញ់ នៃសេចក្តីសង្ឃឹម យើងអាចពិនិត្យមើលព្រះនាងម៉ារីម្តងទៀត ដោយសារព្រះនាងម៉ារីបានថែរក្សាសេចក្តីសង្ឃឹមជានិច្ច។ នៅពេលដែលព្រះនាងម៉ារីជិតដល់ពេលឆ្លងទន្លេ ព្រះនាងម៉ារីអត់មានកន្លែងនៅ ហើយប្រសិនបើយើងគិត បងប្អូនដែលមានផ្ទៃពោះហើយ ដែលធ្លាប់ឆ្លងទន្លេ ពេលអត់មានកន្លែងនៅដើម្បីឆ្លងទន្លេពិបាកណាស់។ យើងមានមណ្ឌលសុខភាព មានមន្ទីរពេទ្យ ក៏ប៉ុន្តែព្រះនាងម៉ារីអត់មានអីសោះ។ ប៉ុន្តែព្រះនាងម៉ារីបានរកឃើញកន្លែងមួយ និងព្រះនាងម៉ារីមានអំណរសប្បាយដោយសារឃើញកូនរបស់គាត់ កើតមកដោយមានសុខ-ភាពល្អ។ នៅពេលព្រះនាងម៉ារីសម្រាលកូនហើយ ប្រហែលប្រាំបីថ្ងៃ ធ្វើដំណើរទៅណាសារ៉ែតមិនបាន ព្រះនាងម៉ារីចេញដំណើរទៅប្រទេសអេស៊ីប។ ព្រះនាងម៉ារីទៅជាជនភៀសខ្លួនមុនគេបង្អស់ ជាមួយលោកយ៉ូសែប ជាមួយទារកយេស៊ូ។ តែព្រះនាងម៉ារីមិនបាត់បង់ក្តីសង្ឃឹមទោះបីគាត់ទៅប្រទេសមួយដែលគាត់មិនស្គាល់ ដូចយើងបានស្តាប់បទពិសោធន៍របស់បងប្អូននៅប្រទេសម៉ាឡេស៊ី ជាកម្មករដែលមកពីប្រទេសនានា។

ព្រះនាងម៉ារីនៅកាណាក៏ដូចគ្នាដែរ! គេអស់ស្រាដើម្បីញ៉ាំ ពេលអស់ស្រាមានន័យថា ពិធីមង្គលការលែងសប្បាយអស់ហើយ។ ប៉ុន្តែព្រះនាងម៉ារី មិនអស់សង្ឃឹមទេ ព្រះនាងម៉ារីមានសេចក្តីសង្ឃឹមទៀតដោយថែរក្សា ដោយយកចិត្តទុកដាក់ ដោយទទួលខុសត្រូវ ដោយថាសូមស្តាប់កូនរបស់ខ្ញុំ នៅពេលគាត់និយាយធ្វើតាមគាត់ទៅ។

នៅទីបំផុត នៅពេលព្រះនាងម៉ារីនៅក្បែរឈើឆ្កាង នៅពេលនោះសម្រាប់អ្នកជាមាតា ជាបទពិសោធន៍មួយដែលពិបាកបំផុត ដែលមើលកូនកំពុងស្លាប់ និងព្រះនាងម៉ារីនៅក្បែរឈើឆ្កាងដោយការពារថែរក្សាសេចក្តីសង្ឃឹម។ ដោយសារព្រះនាម៉ារី បានដឹងថា ព្រះជាម្ចាស់បានជ្រើសរើសព្រះនាងម៉ារី ព្រះជាម្ចាស់បានគង់នៅជាមួយព្រះនាងម៉ារី និងមិនអាចបោះបង់ចោលទាំងនាងម៉ារី ទាំងព្រះយេស៊ូដែរ។

ហេតុនេះហើយ យើងត្រូវតែបន្តធ្វើដំណើរនៅក្នុងពិភពលោកនេះ ដើម្បីធ្វើជាសាក្សី នៃសេចក្តីសង្ឃឹម ដោយសារ **ប្រសិនបើយើងមិនធ្វើ តើអ្នកណាធ្វើបាន?** ប្រសិនបើយើងទៅជាសាក្សីនៃសេចក្តីសង្ឃឹម នរណាធ្វើបាន? នៅពេលខ្ញុំស្តាប់បងប្អូនធ្វើបទពិសោធន៍ប៉ុន្មានថ្ងៃមុន ដែលមានព្រះសហគមន៍ធ្វើការស្វាគមន៍កម្មករដែលមកពីប្រទេសនានា ដែលស្វាគមន៍ជនភៀសខ្លួនដែលអត់មានកន្លែងត្រឹមត្រូវនៅក្នុងសង្គម ខ្ញុំគិតថាពិតមែនព្រះសហគមន៍របស់យើងជាទីតាំងមួយយ៉ាងពិសេស ដើម្បីទទួលការកក់ក្តៅ ដើម្បីទទួលការគោរព និងដើម្បីទទួលសេចក្តីសង្ឃឹមជានិច្ច។

ខ្ញុំជឿថា ព្រះសហគមន៍របស់យើងត្រូវទៅជា សញ្ញាសម្គាល់ពិសេសសម្រាប់សង្គមបច្ចុប្បន្ននេះ។ កាលពីយប់មិញ យើងបានផ្ញើជីវិតទាំងស្រុងទៅលើព្រះរាជ្យវង្សដ៏វិសុទ្ធ ក្រុមគ្រួសារដ៏វិសុទ្ធ ទៅលើព្រះនាងម៉ារី សន្តយ៉ូសែប និងព្រះយេស៊ូ សម្រាប់ម៉ាឡេស៊ី សម្រាប់ប្រទេសយើង សម្រាប់ទ្វីបអាស៊ីយើងទាំងអស់ ដើម្បីឲ្យគ្រួសារទាំងឡាយអាចរកឃើញសេចក្តីសុខសាន្ត។

ថ្ងៃនេះ យើងអធិដ្ឋានទូលអង្វរព្រះជាម្ចាស់តាមរយៈ សន្តីអាណា តាមរយៈ តាមរយៈសន្តយ៉ូហានគីម ដើម្បីបង្កើតពិភពថ្មី គឺពិភពរបស់ព្រះជាម្ចាស់។ អាមែន៕

# រូបភាពសកម្មភាពរបស់ព្រះសហគមន៍



ការិយាល័យយុវជនភូមិភាគភ្នំពេញ បានរៀបចំសកម្មភាព
បោះជុំរុំក្មេងជំទង់ នៅកសិដ្ឋានភ្នំវល្លិ



បោះជុំរុំកុមារ នៅព្រះសហគមន៍កាតូលិក ទំពូង ស្ថិតក្នុងព្រះសហគមន៍
កាតូលិក ភូមិភាគបាត់ដំបង




វេទិកា អន្តរសាសនាថ្នាក់ជាតិនៅកម្ពុជា "ពិធីសូត្រធម៌ អធិដ្ឋាន និងបញ្ជូនសារដើម្បីប្រយុទ្ធប្រឆាំងអំពើជួញ
ដូរមនុស្ស និងបញ្ចប់ទាសភាពសម័យទំនើប" កោះពេជ្រ ថ្ងៃទី៣០ ខែសីហា ឆ្នាំ២០១៧។





ជារៀងរាល់ឆ្នាំក្នុងថ្ងៃទី០១ ខែកញ្ញា ព្រះសហគមន៍ កាតូលិកបាត់ដំបង តែងតែប្រារព្ធពិធីដាំកូនឈើ ដោយមានការរៀបចំដោយលោកអភិបាល គីគេ
ហ្វីការេដូ ព្រមទាំងមានការចូលរួមពីព្រះសង្ឃ និងក្រុមការងារមួយចំនួនរបស់ព្រះសហគមន៍ ព្រមទាំងគ្រីស្តបរិស័ទផងដែរ។









មណ្ឌលសកម្មភាពតាកែវបានមកសូត្រផ្គាំនៅអរិយក្សត្រ



បុគ្គលិកនៃការិយាល័យផ្នែកផ្សព្វផ្សាយព័ត៌មានកាតូលិក ហៅថា ស៊ីអេសស៊ី បានធ្វើទស្សនកិច្ចសិក្សា
គម្រោងអភិវឌ្ឍន៍របស់ព្រះសហគមន៍កាតូលិកនៅខេត្តតាកែវ។

Radio Veritas Asia
Khmer Service
RADIO VERITAS ASIA-KHMER SERVICE

# វិទ្យុវេរីតាស់អាស៊ីខេមរភាសា

## សំលេងពីព្រះសហគមន៍កាតូលិកកម្ពុជា

### ផ្សាយតាមរលកធាតុអាកាស FM

| | | |
|---|---|---|
| ភ្នំពេញ | : FM 104 Mhz | ម៉ោង ៥:០០- ៦:០០ រាល់ថ្ងៃ |
| បាត់ដំបង | : FM 91.0 Mhz | ម៉ោង ៧:០០- ៨:០០ រាល់ថ្ងៃ |
| សៀមរាប | : FM 98.75 Mhz | ម៉ោង ៥:០០- ៦:០០ រាល់ថ្ងៃ |
| កំពង់ធំ | : FM 102.5 Mhz | ម៉ោង ៧:០០- ៨:០០ រាល់ថ្ងៃ |
| កំពង់ចាម | : FM 100.5 Mhz | ម៉ោង ៧:០០- ៨:០០ រាល់ថ្ងៃ |
| ព្រះសីហនុ | : FM 100.5 Mhz | ម៉ោង ៦:០០- ៧:០០ រាល់ថ្ងៃ |
| កំពត | : FM 93.25 Mhz | ម៉ោង ៥:០០- ៦:០០ រាល់ថ្ងៃ |

### ផ្សាយតាមរលកធាតុអាកាសខ្លី (SW)

ជាភាសាខ្មែររយៈពេល ៣០ នាទីរាល់ថ្ងៃពីម៉ោង ៥:០០-៥:៣០នាទីល្ងាច
តាមរលកធាតុអាកាសខ្លី ១១៨៥០ គីឡូហឺតស៍ ត្រូវនឹងកម្ពស់ ២៥,៣២ ម៉ែត្រ។

### តាមប្រព័ន្ធអ៊ីនធឺណែត ២៤ម៉ោង

លោកអ្នកអាចស្តាប់កម្មវិធីវិទ្យុវេរីតាស់អាស៊ីជាភាសាខ្មែរ ២៤ម៉ោង តាមរយៈទូរស័ព្ទ **Smart Phone** ដែលប្រើប្រព័ន្ធ **Android** ឬប្រព័ន្ធ **IOS** ដោយគ្រាន់តែចូលទៅកាន់ **Play Store** ឬ **App Store** វាយពាក្យ **Radio Varitas Asia** រួច **Download** កម្មវិធីនោះដោយស្វែងរកប៊ូតុង **(Khmer Live Audio)** ។

Radio Varitas Asia
Khmer Live audio

ឬ តាមរយៈវេបសាយ៖ http://rvakhmer.com